ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# របាយការណ៍

# បូកសរុបសកម្មភាព និងលទ្ធផលការងារ បង្ការ ទប់ស្កាត់និង បង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ឆ្នាំ២០១២ និងទិសដៅឆ្នាំ២០១៣




គណៈកម្មាធិការជាតិដឹកនាំ ប.ជ.រ.ព.ភ

# អារម្ភកថា

សម្តេច ទ្រង់ ឯកឧត្តម លោកជំទាវ លោក លោកស្រី ជាទីគោរពរាប់អាន

អស់រយៈពេលបីឆ្នាំកន្លងមកនេះ គណៈកម្មាធិការជាតិដឹកនាំ ការបង្រ្កាបអំពើជួញដូរមនុស្ស ការរត់ពន្ធ ការធ្វើអាជីវកម្មពលកម្មលើមនុស្ស និងអាជីវកម្មផ្លូវភេទលើស្ត្រី និងកុមារ ហៅកាត់ (គ.ប/ជ.រ.ព.ភ) បានដឹកនាំយន្តការជាតិពហុវិស័យទទួលខុសត្រូវលើការពង្រឹងទំនាក់ទំនងសហប្រតិបត្តិការជាមួយគ្រប់ផ្នែកពាក់ព័ន្ធ ដើម្បីអនុវត្តរាល់បទដ្ឋានគតិយុត្តិជាតិ និងអន្តរជាតិនានា ធ្វើសកម្មភាពប្រឆាំងការជួញដូរមនុស្សនិងបទល្មើសពាក់ព័ន្ធនៅកម្ពុជា ។ រៀងរាល់ឆ្នាំ លេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិ ក៏ដូចជាលេខាធិការដ្ឋានតាមបណ្តារាជធានីខេត្ត បានអនុវត្តភារកិច្ចយ៉ាងសកម្ម តាមការកំណត់ និងធ្វើឲ្យសម្រេចទិសដៅដែលបានគ្រោងទុកប្រចាំឆ្នាំ ។

ដោយឡែក ក្នុងឆ្នាំ២០១២នេះ ផ្អែកលើផែនការសកម្មភាពជាតិ ប.ជ.រ.ព.ភ ២០១១-២០១៣ លេខាធិការដ្ឋានថ្នាក់ជាតិ បានបង្កើនល្បឿនក្នុងការអនុវត្តយុទ្ធសាស្ត្រយ៉ាងសកម្ម ដោយបានបង្កើតក្រុមការងារអន្តរវិស័យមួយបន្ថែមទៀត ដើម្បីទទួលបន្ទុកដោះស្រាយបញ្ហាទេសន្តរប្រវេសន៍ ដែលជាឫសគល់មួយនៃការជួញដូរមនុស្ស និងការកេងប្រវ័ញ្ចគ្រប់រូបភាព ដោយហេតុថា ទេសន្តរប្រវេសន៍ឬចំណាកស្រុកឆ្លងប្រទេសបច្ចុប្បន្នមានភាពប្រថុយប្រថានច្រើន មិនតាមប្រព័ន្ធស្របច្បាប់ ហើយមិនសូវមានគោលដៅច្បាស់លាស់ ដែលផ្តល់ឱកាសឲ្យជនល្មើសកេងប្រវ័ញ្ចបានងាយស្រួល ។ ទោះបីជាមានជនរងគ្រោះបានផ្តល់បទពិសោធន៍ និងរឿងរ៉ាវដ៏សម្បូរបែប ដែលជាការដាស់តឿនក្រើនរំលឹកកុំឲ្យអ្នកដទៃដើរតាមគន្លងនៃភាពរងគ្រោះយ៉ាងណាក៏ដោយ ក៏នៅតែមានអ្នករងគ្រោះជាបន្តបន្ទាប់ គួរឲ្យបារម្ភ ។

ឆ្លងតាមលទ្ធផលនៃការតាមដានត្រួតពិនិត្យសកម្មភាពលេខាធិការដ្ឋានរាជធានី ខេត្ត បានបង្ហាញឲ្យឃើញថា យើងត្រូវការខំប្រឹងប្រែងបន្តទៀត មិនអាចធ្វេសប្រហែសបានឡើយ ។ រាជធានី ខេត្តមួយចំនួន បានអនុវត្តតាមការណែនាំបានល្អប្រសើរ ដោយយកចិត្តទុកដាក់ក្នុងការរៀបចំ និងពង្រឹងរចនាសម្ព័ន្ធ កិច្ចសហការរវាងភាគីពាក់ព័ន្ធ ទាំងក្នុងរដ្ឋាភិបាល ទាំងអង្គការមិនមែនរដ្ឋាភិបាលជាតិ អន្តរជាតិ ទីភ្នាក់ងារអង្គការសហប្រជាជាតិ និងផ្នែកឯកជន ព្រមទាំងខេត្តជាប់ព្រំដែនក្នុងគោលដៅប្រឆាំងការជួញដូរមនុស្ស និងការកេងប្រវ័ញ្ចកម្លាំងពលកម្ម និងផ្លូវភេទ ។ តែខេត្តមួយចំនួន ត្រូវការការជួយណែនាំ និងពង្រឹងបន្ថែមទៀត ដើម្បីអាចមានលទ្ធភាពបង្ការ ទប់ស្កាត់បទល្មើសជួញដូរមនុស្ស ការពារជនរងគ្រោះ បង្ក្រាប និងផ្តន្ទាទោសជនល្មើសបានប្រកបដោយប្រសិទ្ធិភាព ។

កិច្ចការចម្បងដែលគណៈកម្មាធិការជាតិដឹកនាំ ប.ជ.រ.ព.ភ បានចាត់ទុកជាអាទិភាព គឺការពង្រឹងកិច្ចសហប្រតិបត្តិការ ។ ក្នុងរយៈពេលបីឆ្នាំកន្លងមកនេះ គណៈកម្មាធិការជាតិ បានព្យាយាមប្រមូលគ្រប់កិច្ចខិតខំប្រឹងប្រែងរបស់គ្រប់ស្ថាប័ន អង្គភាព សង្គមស៊ីវិល ផ្នែកឯកជន ដែលជាប្រតិបត្តិករ ដើម្បីចូលរួមជាកម្លាំងសរុបវាយសម្រុកដើម្បីយកជោគជ័យទៅលើបទល្មើសជួញដូរមនុស្ស ដែលកំពុងតែវិវត្តន៍ និងសាយភាយនៅក្នុងតំបន់ និងក្នុងពិភពលោក ។ **"បើយើងមិនអាចធ្វើការរួមគ្នា សហការគ្នា និងឯកភាពគ្នាដើម្បីធ្វើកិច្ចការនេះបានទេ នោះមានន័យថា យើងទុកឱកាសឲ្យជនល្មើសរំលោភបំពាន និងកេងចំណេញលើសភាពការណ៍ដោយងាយស្រួល ឬថា យើងមិនមានឆន្ទៈចង់លុបបំបាត់ការជួញដូរមនុស្សនោះទេ"។**

យើងដឹងហើយថា សកម្មភាពបទល្មើសពាក់ព័ន្ធអំពើជួញដូរមនុស្ស មានភាពស្មុគស្មាញជាងបទល្មើសព្រហ្មទណ្ឌដទៃទៀត ទាំងរូបភាព សកម្មភាព បណ្ដាញជនល្មើស និងទាំងធាតុផ្សំនៃបទល្មើស.. ដែលទាមទារឲ្យស្ថាប័នអនុវត្តន៍ច្បាប់ចាំបាច់ត្រូវពង្រឹងសមត្ថភាពអនុវត្តសកម្មភាពផ្អែកលើច្បាប់ជាតិ ច្បាប់អន្តរជាតិ ជំនាញឯកទេស និងយល់ច្បាស់អំពី ឫសគល់បញ្ហា ល្បិចកលនិងបណ្ដាញជនល្មើស ដើម្បីឆ្លើយតបទៅនឹងបញ្ហាជួញដូរមនុស្ស ។

ច្បាប់ជាតិ បទដ្ឋានច្បាប់អន្តរជាតិ ឬលិខិតតុបករណ៍អន្តរជាតិសំខាន់ៗ ដែលពាក់ព័ន្ធ ទៅនឹងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស គឺជាការកំណត់ក្របខណ្ឌសម្រាប់ការអនុវត្ត ឆ្លើយតបផ្នែកយុត្តិធម៌ព្រហ្មទណ្ឌ ចំពោះអំពើជួញដូរមនុស្សនៅក្នុងប្រទេស ទ្វេភាគី តំបន់ និងអន្តរជាតិ ដែលតម្រូវឲ្យប្រទេសនានាផ្ដល់នូវកិច្ចសហប្រតិបត្តិការ ឬវិធានការដ៏ទូលំទូលាយឲ្យគ្នាទៅវិញទៅមក ដើម្បីសម្របសម្រួលដំណើរការស៊ើបអង្កេត ចាប់ខ្លួន រឹបអូស ការផ្ដន្ទាទោស និងការធ្វើបត្យាប័នទាក់ទងទៅនឹងបទល្មើសជួញដូរមនុស្ស ។ ក្នុងនោះ ព្រះរាជាណាចក្រកម្ពុជាបានផ្ដល់សច្ចាប័នទៅលើលិខិតតុបករណ៍អន្តរជាតិសំខាន់ៗ ទាំងនោះផងដែរ ដើម្បីជាបង្អែកក្នុងការឆ្លើយតបទៅនឹងបញ្ហាជួញដូរមនុស្ស ។

ក្នុងនាមគណៈកម្មាធិការជាតិដឹកនាំ ប.ជ.រ.ព.ភ ខ្ញុំសូមថ្លែងអំណរគុណដល់ថ្នាក់ដឹកនាំ និងមន្ត្រីជំនាញ គ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ សង្គមស៊ីវិលក្នុងស្រុក អន្តរជាតិ ទីភ្នាក់ងារអង្គការសហប្រជាជាតិ យន្តការអនុវត្តទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ជាពិសេសលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិដឹកនាំ ប.ជ.រ.ព.ភ ដែលជាសេនាធិការ ដ៏មានប្រសិទ្ធិភាពក្នុងការដឹកនាំធ្វើសកម្មភាពដោយផ្ទាល់ ធ្វើឲ្យសម្រេចបាននូវជោគជ័យ និងលទ្ធផលជាផ្លែផ្កាជាច្រើនកន្លងមកលើគ្រប់សកម្មភាព ក្នុងការបង្ក្រាបអំពើជួញដូរមនុស្សនៅក្នុងប្រទេសកម្ពុជា ព្រមទាំងពង្រឹង និងពង្រីកកិច្ចសហប្រតិបត្តិការជាតិ ទ្វេភាគីថ្នាក់អនុតំបន់ ថ្នាក់តំបន់ និងអន្តរជាតិបានយ៉ាងទូលំទូលាយ ។ ទន្ទឹមនោះ ក្នុងនាមជាប្រធានគណៈកម្មាធិការជាតិដឹកនាំ ប.ជ.រ.ព.ភ ខ្ញុំសូមលើកទឹកចិត្តបន្ថែមទៀតឲ្យផ្ដោតការយកចិត្តទុកដាក់ អនុវត្តយុទ្ធសាស្ត្រជាតិ និងយន្តការដែលមានស្រាប់នៃក្រុមការងារទាំង ០៧ ដែលជាគ្រឹះដ៏រឹងមាំក្នុងការបង្ការ ទប់ស្កាត់បទល្មើស ការការពារជនរងគ្រោះ ការអនុវត្តច្បាប់ ការផ្ដន្ទាទោសជនល្មើសពាក់ព័ន្ធរឿងក្ដីជួញដូរមនុស្ស កិច្ចការពារកុមារ ការងារទេសន្តរប្រវេសន៍ និងកិច្ចសហប្រតិបត្តិការអន្តរជាតិ ។ ស្របជាមួយគ្នានោះដែរ យើងគប្បីបន្តយកចិត្តទុកដាក់ធ្វើការត្រួតពិនិត្យតាមដាន និងវាយតម្លៃការអនុវត្ត ដើម្បីមានមូលដ្ឋានត្រឹមត្រូវ ក្នុងការកែលំអ បំពេញបន្ថែមចំណុចខ្វះចន្លោះក្នុងក្របខណ្ឌនៃការអនុវត្ត និងក្នុងក្របខណ្ឌគោលនយោបាយ និងច្បាប់នានា ។

ជាទីបញ្ចប់នេះ ខ្ញុំសូមឧទ្ទិសបួងសួង ដល់គុណបុណ្យព្រះរតនត្រ័យ បារមីវត្ថុសក្ដិសិទ្ធិក្នុងលោក ទេវតាឆ្នាំថ្មី ព្រមទាំងព្រះបារមីនៃព្រះបរមរតនកោដ្ឋ សូមព្រះមេត្តាប្រោះព្រំ ប្រសិទ្ធិពរជ័យក្នុងឱកាសចូលឆ្នាំថ្មីប្រពៃណីជាតិ ឆ្នាំម្សាញ់ បញ្ចស័ក ព.ស ២៥៥៧ នេះ សូមជោគជ័យ សិរីមង្គល វិបុលសុខគ្រប់ប្រការ កើតមានដល់យើងទាំងអស់គ្នា ព្រមទាំងសម្ដេច លោកជំទាវ ឯកឧត្ដម លោក លោកស្រី នាងកញ្ញា និងបងប្អូនប្រជាពលរដ្ឋខ្មែរគ្រប់រូប កុំបីឃ្លៀងឃ្លាតឡើយ ។

រាជធានីភ្នំពេញ ថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ ២០១៣

**ប្រធានគណៈកម្មាធិការជាតិដឹកនាំ ប.ជ.រ.ព.ភ**

ស ខេង

# មាតិកា

**ទំព័រ**


**អារម្ភកថា** ..........

**I-សាវតា និងស្ថានភាពទូទៅ** .......... ១-៣

**II-លទ្ធផលការងារ ប.ជ.រ.ព.ក** .......... ៣-៣២

ក-ការរៀបចំច្បាប់-បទដ្ឋាន និងគោលនយោបាយ .......... ៣-៤

ខ-ការងារដឹកនាំ សម្របសម្រួល .......... ៤-១១

គ-ការអនុវត្តយុទ្ធសាស្ត្រប្រឆាំងការជួញដូរមនុស្ស .......... ១១-៣០

១-ការងារបង្ការ-ទប់ស្កាត់ .......... ១១-១៨

១.១-ការផ្សព្វផ្សាយអប់រំបង្ការ .......... ១១-១៥

១.២-ការអនុវត្តវិធានការបង្ការទប់ស្កាត់ .......... ១៥-១៨

២-ការងារការពារ ស្តារនីតិសម្បទា សមាហរណកម្ម និងមាតុភូមិនិវត្តន៍ .......... ១៨-២០

២.១-ការងារការពារ ស្តារនីតិសម្បទាជនរងគ្រោះ .......... ១៨

២.២-ការធ្វើសមាហរណកម្ម និងតាមដាន .......... ១៨

២.៣-ការងារទទួលពលករពីអាជ្ញាធរបរទេស .......... ១៨

២.៣.១-តាមរយៈអាជ្ញាធរបរទេស .......... ១៨

២.៣.២-តាមរយៈក្រសួងការបរទេស .......... ១៨-១៩

២.៣.៣-ការទទួលជនរងគ្រោះ និងងាយរងគ្រោះ .......... ២០

៣-ការងារអនុវត្តច្បាប់ .......... ២០-២១

៤-ការងារកិច្ចការយុត្តិធម៌ .......... ២១-២១

៥-ការងារសហប្រតិបត្តិការអន្តរជាតិ .......... ២២-២៧

៦-ការងារកិច្ចការកុមារ .......... ២៨

៧-ការងារទេសន្តរប្រវេសន៍ .......... ២៨-៣០

ឃ-ការលើកកម្ពស់សមត្ថភាព .......... ៣០-៣២

១-ការបណ្តុះបណ្តាល .......... ៣០-៣១

២-សិក្ខាសាលា .......... ៣១-៣២

III-**ការប្រៀបធៀបសកម្មភាព** (រយៈពេល០៣ឆ្នាំ ............ ៣២-៣៩
IV-**ការតាមដានត្រួតពិនិត្យ** ............ ៣៩-៤០
V-**ការស្និដ្ឋានវាយតម្លៃ** ............ ៤០-៤៣
ក-ចំណុចខ្លាំង ............ ៤០-៤១
ខ-ចំណុចសេសសល់ និងភាពប្រឈម ............ ៤១-៤២
គ-សន្និដ្ឋាន និងវាយតម្លៃ ............ ៤២-៤៣
V-**ទិសដៅ** ............ ៤៣-៤៤
ឧបសម្ព័ន្ធ
សកម្មភាពផ្សេងៗរបស់លេខាធិការដ្ឋាន នៃគណកម្មាធិការជាតិដឹកនាំ ប.ជ.រ.ព.ភ

# របាយការណ៍បូកសរុបសកម្មភាព និងលទ្ធផល
# ការងារបង្ការ ទប់ស្កាត់ និងបង្ក្រាបអំពើជួញដូរមនុស្ស
# និងអំពើធ្វើអាជីវកម្មផ្លូវភេទ ឆ្នាំ២០១២
# និងទិសដៅ ឆ្នាំ២០១៣

(គិតចាប់ពីថ្ងៃទី២៦/១២/១១ - ២៥/១២/១២)

## I. សាវតា និងស្ថានភាពទូទៅ

គណៈកម្មាធិការជាតិដឹកនាំការបង្ក្រាបអំពើជួញដូរ ការរត់ពន្ធ ការធ្វើអាជីវកម្មពលកម្ម លើមនុស្ស និងអាជីវកម្មផ្លូវភេទលើស្ត្រីនិងកុមារ ហៅកាត់ថា គ.ជ/ប.ជ.រ.ព.ភ ដឹកនាំដោយ ឯកឧត្តម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បានបំពេញភារកិច្ចយ៉ាងសកម្មតាមការកំណត់ អស់រយៈពេលបីឆ្នាំកន្លងមកហើយ ។ គណៈកម្មាធិការជាតិនេះ មានភារកិច្ចទទួលខុសត្រូវប្រឆាំងការជួញដូរមនុស្ស និងបទល្មើសពាក់ព័ន្ធ ពង្រឹងការអនុវត្តច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ព្រមទាំងពង្រឹងទំនាក់ទំនងសហប្រតិបត្តិការក្នុង ការអនុវត្តរាល់បទដ្ឋានគតិយុត្តរបស់ជាតិ និងអន្តរជាតិនានាដែលពាក់ព័ន្ធ ដើម្បីកាត់បន្ថយ ឈានទៅលុបបំបាត់ការជួញដូរមនុស្ស ។

គណៈកម្មាធិការជាតិនេះ ជាយន្តការជាតិពហុវិស័យដែលប្រមូលផ្តុំគ្រប់កិច្ចខិតខំប្រឹងប្រែងនានារបស់ក្រសួងស្ថាប័នក្នុងរាជរដ្ឋាភិបាលនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ រួមជាមួយអង្គការសង្គមស៊ីវិលក្នុងស្រុក អង្គការអន្តរជាតិ ទីភ្នាក់ងារអង្គការសហប្រជាជាតិ និងផ្នែកឯកជន ដើម្បីធ្វើសកម្មភាពព្រមៗគ្នាតាមមុខសញ្ញារៀងៗខ្លួន ផ្អែកតាមទិសដៅសកម្មភាពជាតិដែលបានកំណត់រៀងរាល់ឆ្នាំ ។

គណៈកម្មាធិការជាតិ ប.ជ.រ.ព.ភ បានអនុម័តផែនការសកម្មភាពជាតិ ឆ្នាំ២០១១-២០១៣ ដើម្បីធ្វើជាផែនទីបង្ហាញផ្លូវឲ្យអនុវត្តយុទ្ធសាស្ត្រចម្រុះពហុវិស័យ ដោយប្រើប្រាស់នូវកម្លាំងសរុប ធនធានសរុប និងវិធានការសរុប បង្កើនប្រសិទ្ធភាពក្នុងការបង្ការទប់ស្កាត់ ការការពារ និងគាំទ្រជនរងគ្រោះ ការអនុវត្តច្បាប់ និងការផ្តន្ទាទោសជនល្មើស រួមផ្សំនិងការពង្រឹងភាពជា ដៃគូ ពង្រឹងការអនុវត្តភារកិច្ច និងការទទួលខុសត្រូវរបស់ក្រសួងស្ថាប័ននិងអង្គភាពពាក់ព័ន្ធ ធានាបាននិរន្តភាពការងារសម្រាប់អនុវត្តឆ្លើយតបទៅនឹងបញ្ហាជួញដូរមនុស្ស ។

ទន្ទឹមនឹងនេះ លេខាធិការដ្ឋានដែលជាសេនាធិការរបស់គណៈកម្មាធិការជាតិ បានធ្វើឲ្យសម្រេចនូវលទ្ធផល និងសមិទ្ធផលជាច្រើន ទាំងនៅថ្នាក់ជាតិ ទាំងថ្នាក់ក្រោមជាតិក្នុងកិច្ចការប្រឆាំងការជួញដូរមនុស្ស និងអំពើពាក់ព័ន្ធ ។ កិច្ចខិតខំប្រឹងប្រែងនេះ ទទួលបានការទទួលស្គាល់ពីមជ្ឈ ដ្ឋានជាតិ និងអន្តរជាតិ ព្រមទាំងការវាយតម្លៃពីសហរដ្ឋអាមេរិកឲ្យប្រទេសកម្ពុជាស្ថិតនៅលំដាប់ថ្នាក់លេខ២ក្នុងសកម្មភាពប្រឆាំងការជួញដូរមនុស្ស រយៈពេល០៣ឆ្នាំជាប់ៗគ្នា (គឺឆ្នាំ២០១០-២០១១ និង ២០១២) ។ លទ្ធផលគួរឲ្យមោទនៈនេះ បានបញ្ជាក់អំពីឆន្ទៈ ការទទួលខុសត្រូវ និងការប្តេជ្ញាចិត្ត របស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការប្រឆាំងនឹង អំពើជួញដូរមនុស្ស។

នៅក្នុងឆ្នាំ២០១២នេះ គណៈកម្មាធិការជាតិដឹកនាំ ប.ជ.រ.ព.ភ បានផ្តោតការយកចិត្តទុកដាក់ ជម្រុញ និងបំពេញបន្ថែមចំណុចខ្វះចន្លោះក្នុងក្របខណ្ឌនៃការអនុវត្ត និងក្នុងក្របខណ្ឌគតិយុត្តិមួយ ចំនួនដូចជា៖

- ✓ បានបង្កើតក្រុមការងារចុះតាមដានត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តភារកិច្ចរបស់ ក្រុមការងារនៅថ្នាក់ជាតិ និងលេខាធិការដ្ឋានថ្នាក់ក្រោមជាតិ
- ✓ បង្កើតក្រុមការងារទេសន្តរប្រវេសន៍ដើម្បីទទួលបន្ទុកដោះស្រាយ ពង្រឹងការគ្រប់គ្រង និងលើកកម្ពស់ការអនុវត្តគោលនយោបាយជាតិ លើកកម្ពស់សុវត្ថិភាព សិទ្ធិ និងផលប្រយោជន៍ពលករទេសន្តរប្រវេសន៍ និង
- ✓ ចុះទស្សនកិច្ចសិក្សាតាមបណ្តាក្រុមហ៊ុនជ្រើសរើសពលករក្នុងប្រទេស និងធ្វើទស្សន កិច្ចសិក្សានៅប្រទេសម៉ាលេស៊ី អំពីរបៀបរបបការងារ ការទទួលខុសត្រូវ គោលនយោបាយ-ច្បាប់ការពារពលករនៅក្រៅប្រទេស ជាដើម ។

ការសិក្សាទាំងអស់នេះ បានជួយឲ្យលេខាធិការដ្ឋានបានស្វែងយល់ និងកំណត់បានយ៉ាងជាក់លាក់នូវភាពប្រឈម និងចំណុចខ្វះខាតទាំងឡាយជុំវិញសកម្មភាពប្រឆាំងការជួញដូរមនុស្សរបស់ស្ថាប័នអនុវត្ត ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ និងរកឃើញមូលហេតុជាគន្លឹះ ដែលនាំឲ្យមានលំហូរពលករទេសន្តរប្រវេសន៍តាមប្រព័ន្ធមិនស្របច្បាប់ ភាពរងគ្រោះរបស់ពលករ និងឈានទៅដល់ការរៀបចំគោលការណ៍គ្រឹះ វិធានការនិងយុទ្ធសាស្ត្រចម្បងៗ ក្នុងការគ្រប់គ្រង និងឆ្លើយតបដោយសមស្រប និងមានប្រសិទ្ធភាពនៅពេលខាងមុខ។

ជាទូទៅ ស្ថានភាពពាក់ព័ន្ធទៅនឹងអំពើជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ ការរត់ពន្ធមនុស្ស និងការជួញដូរមនុស្សឆ្លងដែន នៅតែមានភាពស្មុគ្រស្មាញ បត់បែន និងជ្រកក្រោមរូបភាពស្របច្បាប់ ផ្សេងៗ ដើម្បីជនល្មើសអាចឆក់ឱកាសកេងប្រវ័ញ្ចលើប្រជាពលរដ្ឋបានងាយ ស្រួល ឧទាហរណ៍៖ ការធ្វើអាជីវកម្មផ្លូវភេទតាមរូបភាពជាសេវាកំសាន្ត រូបភាពភ្ជាប់ពាក្យឬអាពាហ៍ពិពាហ៍ ការនាំស្ត្រីចេញទៅក្រៅប្រទេសតាមទិដ្ឋាការទេសចរណ៍តែក្នុងគោលដៅរកគូស្រករ ឬលក់កម្លាំងពលកម្ម ឬកេងប្រវ័ញ្ចផ្លូវភេទ ឬសុំទាន...ជាដើម ។

ដោយសារតែប្រជាពលរដ្ឋមួយចំនួនមានបំណងប្រាថ្នាក្នុងការស្វែងរកកម្រៃ ឬលាភការនៅបរទេស ធ្វើឲ្យជនល្មើសអាចប្រើប្រាស់ឱកាសនេះ ដើម្បីកេងប្រវ័ញ្ចបានយ៉ាងងាយស្រួល និងដោយស្របច្បាប់ ។ ពលករខ្លះបានរងគ្រោះ ព្រោះតែជាប់បំណុលមេខ្យល់ ឬថៅកែ ឬក្រុមហ៊ុន ដើម្បីជាមធ្យោបាយបានចេញទៅក្រៅប្រទេសតាមបំណងប្រាថ្នារបស់ខ្លួន រួចហើយត្រូវធ្វើការដោះបំណុលថៅកែ ឬក្រុមហ៊ុនទាំងនោះ ដោយត្រូវកាត់ប្រាក់បៀវត្សរ៍ទាំងស្រុងជាច្រើនខែ និងអាចរងទារុណកម្ម លើផ្លូវកាយ ផ្លូវចិត្ត ការរំលោភផ្លូវភេទ ឬខ្លះត្រូវបានគេលក់ពលកម្មបន្តពីថៅកែមួយទៅថៅកែមួយ ពីប្រទេសមួយទៅប្រទេសមួយ ជាពិសេស ឲ្យទៅធ្វើការលើទូកនេសាទឯនាយសមុទ្រជាដើម។ មួយចំនួនទៀត ទោះបីជាទៅតាមរយៈក្រុមហ៊ុនស្របច្បាប់ ដែលនាំពលករទៅធ្វើការនៅក្រៅប្រទេសក៏ដោយ ក៏នៅតែមានករណីរងគ្រោះដោយការរំលោភ បំពានសិទ្ធិ ផលប្រយោជន៍ និងសេចក្តីថ្លៃថ្នូររបស់ពលករ និងពលករខ្លះទៀត ដាច់ការទាក់ទង មកគ្រួសារ រហូតហួសរយៈពេលនៃកិច្ចសន្យានៅតែពុំទាន់ ឃើញត្រឡប់មកវិញ ក៏មាន...។

ទោះបីជាដឹងថាពលករមួយចំនួនធំបានទទួលប្រាក់កម្រៃល្អ និងធ្វើឲ្យគ្រួសារមានការប្រែប្រួលជីវភាពគួរឲ្យកត់សម្គាល់ក៏ដោយ ក៏យើងនៅមិនទាន់មានមោទនៈចំពោះកិច្ចការនេះនៅឡើយដែរ ព្រោះថានៅមិនទាន់មានការគ្រប់គ្រងច្បាស់លាស់ ជាក់លាក់លើស្ថានភាពពិត ចំណូលពិត និងទំហំពិតរបស់ពលករដែលហូរចេញជារៀងរាល់ថ្ងៃ តាមរបៀបផ្សេងៗនោះនៅឡើយ ហើយការត្រៀមខ្លួនក្នុងការលើកកម្ពស់កម្រិតជំនាញ ដើម្បីទទួលបានប្រាក់កម្រៃខ្ពស់ ក៏មិនទាន់គួរជាទីពេញចិត្តនៅឡើយដែរ។

ស្ថានភាព និងរូបភាពនៃការជួញដូរមនុស្ស និងការកេងប្រវ័ញ្ចដែលបានរៀបរាប់ខាងលើនេះ មានពាក់ព័ន្ធយ៉ាងជ្រាលជ្រៅទៅនឹងកត្តាជាច្រើន ទាំងកត្តាខាងក្នុង ទាំងកត្តាខាងក្រៅ ដែលចាំបាច់ត្រូវបន្តយកចិត្តទុកដាក់ដោះស្រាយជាបន្ទាន់ ។

ភាពប្រឈមជាគន្លឹះគឺការផ្លាស់ប្តូរបទដ្ឋានក្នុងការរស់នៅ ទស្សនៈ ការទទួលខុសត្រូវ និងការប្រែប្រួលនូវគុណតម្លៃរបស់មនុស្ស គ្រួសារ និងសហគមន៍ ។ ជនរងគ្រោះខ្វះការយល់ដឹងជាសាកល អំពីបញ្ហាជួញដូរមនុស្ស និងផលវិបាកនានា ដោយគិតឃើញតែផលចំណេញ តែមិនគិតពីបញ្ហាប្រឈមទាំងឡាយដែលនឹងអាចកើតមាន ហើយបណ្តោយទៅតាមការអូសទាញ និងការរៀបចំរបស់ជនល្មើសដោយគ្មានការពិចារណា ។ ជនល្មើសងាយស្រួលក្នុងការកេងប្រវ័ញ្ចជាទីបំផុត ព្រោះតែការធ្វេសប្រហែសឲ្យលង់ខ្លួនក្នុងទង្វើខុសច្បាប់របស់ខ្លួន ឧទាហរណ៍៖ ការឆ្លងដែនខុសច្បាប់ នៅលួចលាក់ធ្វើការក្នុងប្រទេសគេដោយខុសច្បាប់ ឬប្រើប្រាស់ទិដ្ឋាការទេសចរណ៍ដើម្បីគោលដៅអាពាហ៍ពិពាហ៍ ឬរកការងារធ្វើ ជាដើម ។

ក្នុងឆ្នាំ២០១២ បញ្ហាទេសន្តរប្រវេសន៍ការងារត្រូវបានចាត់ចូលជាអាទិភាពមួយ ក្នុងការងារពាក់ព័ន្ធនឹងសកម្មភាពប្រឆាំងការជួញដូរមនុស្ស និងការកេងប្រវ័ញ្ចគ្រប់រូបភាព ។ ជាការកត់សម្គាល់ ពលករ ពលការិនី បានធ្វើចំណាកស្រុកឆ្លងដែនច្រើនជាងឆ្នាំមុនៗ ជាពិសេសក្នុងតំណាក់កាល ក្រោយគ្រោះទឹកជំនន់រាំរ៉ៃក្នុងប្រទេសថៃឆ្នាំ២០១១ ។ ប្រជាពលរដ្ឋនាំគ្នាឆ្លងដែនដោយខុសច្បាប់តាមច្រករបៀងព្រំដែនគោកទៅប្រទេសថៃ ទោះបីជាមានវិធានការអប់រំ ទប់ស្កាត់ វិធានការបង្ក្រាបនៅក្នុងប្រទេស និងវិធានការចាប់បញ្ជូនមកវិញរបស់ភាគីថៃក៏ដោយ ក៏នៅតែមានអ្នកប្រថុយលួចឆ្លងដែនដោយខុសច្បាប់ទៅរកការងារធ្វើនៅទីនោះជារៀងរាល់ថ្ងៃ ព្រោះនៅតែមាននិយោជក ដែលចង់ប្រើប្រាស់ពលករប្រភេទនេះ ។ កត្តាសំខាន់ដែលជម្រុញ និងអូសទាញឲ្យប្រជាពលរដ្ឋកម្ពុជានាំគ្នាពពាក់ពពូនទៅ ធ្វើការងារនៅប្រទេសថៃដូច្នេះ គឺមកពីមានកត្តាទាំងសងខាង ដូចពាក្យចាស់លោកថា “ ***ទំពក់វាទៅ ទើបញ្ញើវាមក*** ” ។

ដើម្បីដោះស្រាយបញ្ហាទាំងអស់នេះ គណៈកម្មាធិការជាតិដឹកនាំ ប.ជ.រ.ព.ភ បានលើកទិសដៅដោះស្រាយ ដែលទាមទារឲ្យមានការចូលរួមពីគ្រប់ផ្នែកពាក់ព័ន្ធ ទាំងក្នុងប្រទេស ទាំងជាមួយប្រទេសពាក់ព័ន្ធជាទ្វេភាគី និងពហុភាគី និងត្រូវស្វែងរកការគាំទ្រពីប្រទេសនានាក្នុងតំបន់ និងពីអន្តរជាតិ ។

## II- លទ្ធផលការងារ ប.ជ.រ.ព.ភ

នៅក្នុងឆ្នាំ២០១២ កន្លងទៅនេះ គណៈកម្មាធិការជាតិ និងថ្នាក់ក្រោមជាតិ ប.ជ.រ.ព.ភ បានបន្តអនុវត្តយ៉ាងយកចិត្តទុកដាក់នូវទិសដៅភារកិច្ចរបស់ខ្លួនតាមការគ្រោងទុក ដោយមានការចូលរួមកាន់តែសកម្មពីមន្ត្រីអនុវត្ត ពីបណ្តាក្រសួង ស្ថាប័ន មន្ទីរ និងអង្គភាពពាក់ព័ន្ធនិងអង្គការមិនមែនរដ្ឋាភិបាលជាតិ អន្តរជាតិ និងទីភ្នាក់ងារសហប្រជាជាតិទាំងឡាយកាន់តែច្រើន រហូតសម្រេចបានលទ្ធផលដូចខាងក្រោម ៖

### ក- ការរៀបចំច្បាប់-បទដ្ឋាន និងគោលនយោបាយ

នៅក្នុងឆ្នាំ២០១២ កន្លងនេះមានលិខិតបទដ្ឋានចំនួន០៩ចេញដោយ ៖

- គណៈកម្មាធិការជាតិដឹកនាំ ប.ជ.រ.ព.ភ ចំនួន០៤ ៖

NATIONAL COMMITTEE TO LEAD S.T.S.L.S

១. សេចក្ដីសម្រេចលេខ០៤៥ ស.ស.រ ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១២ ស្ដីពីការបង្កើតក្រុមការងារពិនិត្យកែសម្រួលអនុក្រឹត្យលេខ១៨៣អនក្រប.ក ស្ដីពីការកំណត់បែប បទ និងនីតិវិធី នៃការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស ។

២. សេចក្ដីសម្រេចលេខ០១០ ស.ស.រ ចុះថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០១២ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមការងារទេសន្តរប្រវេសន៍របស់លេខាធិការដ្ឋាននៃគណៈ កម្មាធិការជាតិដឹកនាំ ប.ជ.រ.ព.ភ ។

៣. សេចក្ដីសម្រេចលេខ០៨/១២ ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ២០១២ ស្ដីពីការកែសម្រួលសមាសភាពលេខាធិការដ្ឋានជាតិជូនលោកជំទាវ ឧត្ដមសេនីយ៍ឯក **យក់ សុខា** អគ្គស្នងការរងនគរបាលជាតិ ជាអនុប្រធានអចិន្ត្រៃយ៍ និងជាប្រធានក្រុមការងារអនុវត្តច្បាប់នៃលេខាធិការដ្ឋានជាតិប.ជ.រ.ព.ភ ។

៤. សេចក្ដីសម្រេចលេខ០៤/១២ ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១២ ស្ដីពីការតែងតាំងប្រធានសមាគម និងអគ្គលេខាធិការទីភ្នាក់ងារជ្រើសរើសពលករកម្ពុជា ជាសមា ជិកក្រុមការងារទប់ស្កាត់ និងក្រុមការពារស្តារនីតិសម្បទា សមាហរណកម្ម និង មាតុភូមិនិវត្តន៍ ។

- លេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិដឹកនាំ ប.ជ.រ.ព.ភ ចំនួន០២ ៖

១. លិខិតជម្រាបជូនដល់លេខាធិការដ្ឋានរាជធានី-ខេត្តទាំង២៤ ណែនាំឲ្យមានកិច្ច ប្រជុំពិនិត្យ ការអនុវត្តសកម្មភាពការងារ និងជម្រុញការកសាងផែនការសកម្មភាពសម្រាប់អនុវត្ត ឱ្យស្របតាមផែនការសកម្មភាពជាតិឆ្នាំ២០១១-២០១៣ ។

២. សេចក្ដីសម្រេចលេខ០៤២ ស.ស.រ ចុះថ្ងៃទី១១ ខែតុលា ឆ្នាំ២០១២ ស្ដីពីការបង្កើតក្រុមការងារតាមដានត្រួតពិនិត្យតាមរាជធានី-ខេត្ត ដើម្បីចុះឲ្យដល់កន្លែងអនុវត្ត និងពង្រឹងការងារប.ជ.រ.ព.ភ នៅថ្នាក់ក្រោមជាតិ ។

- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា (០១ច្បាប់)៖

នីតិវិធីប្រតិបត្តិបទដ្ឋាន ស្ដីពីការផ្ដល់ការគាំទ្រផ្នែកសមាហរណកម្មដល់ជនរងគ្រោះជាបុរស ដោយអំពើជួញដូរមនុស្ស

- អគ្គស្នងការដ្ឋាននគរបាលជាតិ បានចេញសេចក្ដីជូនដំណឹង០១ ច្បាប់៖

សេចក្ដីជូនដំណឹងលេខ១៦០សណន ចុះថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០១១ ដើម្បីជម្រុញកងកម្លាំងនគរបាលជាតិឲ្យអនុវត្តសេចក្ដីណែនាំលេខ ០០៥សណន សំដៅបង្ការ-ទប់ស្កាត់ និងបង្ក្រាបបទល្មើសជួញដូរមនុស្ស ។

- គណៈកម្មាធិការដឹកនាំ ប.ជ.រ.ព.ភ ខេត្តបាត់ដំបង៖

ចេញលិខិតលេខ ១២១៤ខបប ចុះថ្ងៃ ទី១៨ ខែកញ្ញា ឆ្នាំ២០១២ ស្ដីពីសម្រង់ស្ថិតិកុមាររងគ្រោះ ដោយសារការជួញដូរ និងពលកម្មធ្ងន់ធ្ងរ ដែលមានអាយុក្រោម១៥ឆ្នាំនៅស្រុកកំរៀង ស្រុកភ្នំស្រុក និងស្រុកសំពៅលូន ។

## ខ- ការងារដឹកនាំសម្របសម្រួល:

ការងារដឹកនាំ និងសម្របសម្រួល សរុបមានចំនួន**១៩៧**លើក ដោយគណៈកម្មាធិការជាតិដឹកនាំប.ជ.រ.ព.ភ ចំនួន០៣លើក លេខាធិការដ្ឋានជាតិចំនួន**៣២**លើក ក្រសួងការងារបណ្ដុះបណ្ដាលវិជ្ជាជីវៈចំនួន១២លើក ក្រសួងទេសចរណ៍ចំនួន**០៣**លើក ក្រុមការងារCOMMITកម្ពុជាចំនួន

០៩លើក ក្រសួងសង្គមកិច្ចអតីតយុទ្ធជន និងយុវនីតិសម្បទាចំនួន០៤លើក ក្រុមការងារបង្ការទប់ស្កាត់ចំនួន០២លើក ក្រុមការងារអនុវត្តច្បាប់ចំនួន០៦លើក ក្រុមការងារកិច្ចការកុមារចំនួន០២លើក ក្រុមការងារសហប្រតិបត្តិការអន្តរជាតិចំនួន០២លើក ក្រុមការងារកិច្ចការយុត្តិធម៌ចំនួន០៦លើក ក្រុមការងារទេសន្តរប្រវេសន៍ចំនួន១៥លើក និងលេខាធិការដ្ឋានរាជធានី-ខេត្តចំនួន១១១លើក ។

តារាងការងារដឹកនាំសម្របសម្រួល

| ស្ថាប័នសម្របសម្រួល | សកម្មភាព | ស្ថាប័ន និងបុគ្គលពាក់ព័ន្ធ |
|---|---|---|
| គណៈកម្មាធិការជាតិដឹកនាំ ប.ជ.រ.ព.ភ ចំនួន ០៣លើក | ១.សន្និបាតបូកសរុបការងារប្រចាំឆ្នាំ ២០១១<br>២.កិច្ចប្រជុំចង្អៀត ដើម្បីពិភាក្សារកវិធានការដោះ ស្រាយ និងគ្រប់គ្រងលើបញ្ហាទេសន្តរប្រវេសន៍ ការងារ ។<br>៣.សិក្ខាសាលាប្រកាសក្រុមការងារទេសន្តរប្រវេសន៍ នៃ លេខាធិការដ្ឋានជាតិ ។ | -សមាជិកគណៈកម្មាធិការជាតិ សមាជិកលេខាធិការដ្ឋានជាតិ គណៈកម្មាធិការដឹកនាំ ប.ជ.រ.ព.ភ រាជធានីខេត្ត ស្ថានទូត និងអង្គការដៃគូជាតិ អន្តរជាតិ ។ |
| លេខាធិការដ្ឋានជាតិ ប.ជ.រ.ព.ភ<br>ចំនួន៣២លើក | ១.ដឹកនាំកិច្ចប្រជុំក្រុមការងារទាំង០៧ រៀបចំរបាយការណ៍ឆ្នាំ រៀបចំផែនការសកម្មភាព ២០១២ រៀបចំសន្និបាតបូកសរុបការងារ ប.ជ.រ.ព.ភ ០៣លើក។<br>២.ជួបពិភាក្សាការងារជាមួយថ្នាក់ដឹកនាំក្រសួងការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងក្រសួងកិច្ចការនារី ដើម្បីស្នើសុំចាត់តាំងមន្ត្រី ចូលក្នុងក្រុមការងារទេសន្តរប្រវេសន៍ នៃលេខាធិការដ្ឋានជាតិ (២លើក)។<br>៣.ប្រជុំតាក់តែងទស្សនទាននិងសេចក្តីសម្រេចបង្កើតក្រុមការងារទេសន្តរប្រវេសន៍ (០៣លើក)<br>៤.ប្រជុំរៀបចំផែនការសកម្មភាពសម្រាប់អនុវត្តឆ្នាំ២០១២-២០១៣ដល់បណ្តារាជធានី-ខេត្តទាំង២៤ (០១លើក)<br>៥.ចុះដល់រាជធានី-ខេត្តចំនួន០៧ (រាជធានីភ្នំពេញ ខេត្តបន្ទាយមានជ័យ កំពង់ចាម ស្វាយរៀង ព្រៃវែង សៀមរាប និងខេត្តកោះកុង)(០៧លើក)។<br>៦.ប្រជុំក្រុមការងារទេសន្តរប្រវេសន៍ រៀងរាល់ពីរខែម្តងតាមដានសកម្មភាព រៀបចំផែនការនិងឆ្លងរបាយការណ៍ក្រុម(០៣លើក)<br>៧.ត្រៀមសិក្ខាសាលាប្រកាសក្រុមការងារទេសន្តរប្រវេសន៍ និងឆ្លងរបាយការណ៍ទស្សន | -សមាជិកលេខាធិការដ្ឋានជាតិ ក្រុមការងារទាំង៧ អង្គការដៃគូ និងអ្នកពាក់ព័ន្ធ។<br>-ប្រធានលេខាធិការដ្ឋានដឹកនាំ ប.ជ.រ.ព.ភ រាជធានី-ខេត្ត និងសមាជិក។<br>-ប្រធានលេខាធិការដ្ឋានជាតិ, រដ្ឋមន្ត្រីក្រសួងកិច្ចការនារី និងរដ្ឋមន្ត្រីក្រសួង ស.អ.យ ។<br>-អាជ្ញាធរខេត្តបន្ទាយមានជ័យ ឧត្តរមានជ័យ ស្វាយរៀង និងអាជ្ញាធរថៃ ។<br>-ក្រសួងទេសចរណ៍, ICNP, CEOP ស្ថានទូតអង់គ្លេស ។<br>-ក្រសួងពាក់ព័ន្ធ, អង្គការ UN Women, OHCHR, CARAM, អង្គការ Winrock អន្តរជាតិ ។ |

| | | |
|---|---|---|
| | កិច្ចនៅម៉ាលេស៊ី(០៣លើក)<br>៨.ធ្វើទស្សនកិច្ចសិក្សាស្រាវជ្រាវរកយុទ្ធសាស្ត្រ និងរៀបចំការគ្រប់គ្រងពលករ ទេសន្តរប្រវេសន៍ ឲ្យមានសុវត្ថិភាព (០១លើក)។<br>៩.ចូលរួមជាវាគ្មិន សម្របសម្រួល និងបិទវគ្គសិក្ខាសាលា ស្តីពីការលើកកម្ពស់គុណភាពសេវាកម្មច្បាប់សម្រាប់កុមាររងគ្រោះដោយការជួញដូរ ការរំលោភបំពាន និងកេងប្រវ័ញ្ចន៍ផ្លូវភេទ ជាមួយក្រសួងយុត្តិធម៌ និងអង្គការទស្សនៈ ពិភពលោក (World Vision) (០១លើក)។<br>១០.ចូលរួមជាវាគ្មិន ក្នុងសិក្ខាសាលាបើកព្រឹត្តការណ៍សម្រាប់ការបោះពុម្ពសៀវភៅ ស្តីពីអនុសញ្ញាអន្តរជាតិលើការលើកកម្ពស់ការពារសិទ្ធិពលករចំណាកស្រុក និងគ្រួសារពួកគេ និងសិក្ខាសាលាថ្នាក់តំបន់ ស្តីពីការពង្រឹងសមត្ថភាពប្រយុទ្ធ ប្រឆាំងនឹងអំពើជួញដូរមនុស្ស (០១លើក)។<br>១១.ជាអធិបតីក្នុងការរៀបចំទិវាប្រឆាំងការជួញដូរមនុស្ស១២ធ្នូ ឆ្នាំ២០១២ នៅព្រំដែនថៃក្រុងប៉ោយប៉ែត ដោយមានការចូលរួមពីប្រជាពលរដ្ឋនិងភាគី ថៃប្រមាណ១៦០០នាក់ (០១លើក)។<br>១២.ចុះអនុស្សរណៈសម្រាប់កិច្ចសហការការងារជាមួយអង្គការវីនរ៉ក់ប្រចាំនៅកម្ពុជា ក្នុងការធ្វើសកម្មភាពCTIP II (០១លើក)។ | |
| ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ចំនួន១២លើក | ១.សិក្ខាសាលាសាលាពិគ្រោះយោបល់ ដើម្បីពិនិត្យពិភាក្សាលើសេចក្តីព្រាងMoU ស្តីពីការប្រើប្រាស់កម្លាំងពលកម្ម ស្ត្រីជំនួយការមេផ្ទះទៅធ្វើការនៅប្រទេសម៉ាលេស៊ី (៣លើក ៦ថ្ងៃ)<br>២. រៀបចំបទដ្ឋានអប្បបរមាសេវារកការងារឲ្យធ្វើនៅបរទេស រវាងទីភ្នាក់ងារជ្រើសរើស និងពលករ(៣លើក )<br>៣. ប្រជុំពិភាក្សា លើការរៀបចំប្រកាស ៣ ស្តីពី<br>✓ ការដាក់ឲ្យប្រើពាក្យគន្លឹះ (ក្នុងអនុក្រឹត្យលេខ ១៩០ ស្តីពីការគ្រប់ | សហការជាមួយ UN Women<br><br>សហការជាមួយ UN Women<br><br>សហការជាមួយ ILO-Triangle |

| | | |
|---|---|---|
| | គ្រងលើការបញ្ជូនពលករខ្មែរទៅធ្វើការនៅបរទេសតាមរយៈទីភ្នាក់ងារជ្រើសរើសឯកជន)<br>✓ ដំណើរការជ្រើសរើស និងការណែនាំតម្រង់ទិសពលករមុនចេញដំណើរ<br>✓ ទីភ្នាក់ងារជ្រើសរើសឯកជន<br>(សរុប ៦លើក) | |
| ក្រសួងទេសចរណ៍ ចំនួន០៣លើក | ១.ប្រជុំពិភាក្សាការងារ ស្តីពីការលើកកម្ពស់សុវត្ថិភាពកុមារក្នុងវិស័យទេសចរណ៍ ។<br>២.ប្រជុំពិភាក្សាការងាររៀបចំប្រកាសអន្តរក្រសួងស្តីពីការបែងចែកសមត្ថកិច្ចរវាងមន្ត្រីអធិការកិច្ចទេសចរណ៍ និងនគរបាលទេសចរណ៍<br>៣.ប្រជុំរៀបចំអនុក្រឹត្យ ស្តីពីការគ្រប់គ្រងមណ្ឌលកម្សាន្តទេសចរណ៍ សម្រាប់មនុស្សពេញវ័យ | -អង្គការ Child Wise, អ៊ិកផាតកម្ពុជា<br><br>ក្រសួង ស្ថាប័នពាក់ព័ន្ធ រាជធានី ខេត្តទាំង២៤ ផ្នែកឯកជន អង្គការNGOs |
| ក្រសួងសង្គមកិច្ចអតីតយុទ្ធជន និងយុវនីតិសម្បទាចំនួន០១លើក | ១.ប្រជុំស្តីពីកិច្ចការពារ និងសមាហរណកម្មកុមារ ស្ត្រីរងគ្រោះដោយអំពើជួញដូរមនុស្ស<br>២.បន្តកែសម្រួលលើសេចក្តីព្រាងគោលការណ៍សាងសង់មជ្ឈមណ្ឌលសំចតប៉ោយប៉ែត<br>៣.រៀបចំសេចក្តីព្រាងប្រកាសបទដ្ឋានអប្បបរមា សម្រាប់ការថែទាំជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទដែលស្នាក់នៅក្នុងមជ្ឈមណ្ឌល<br>៤. រៀបចំសេចក្តីព្រាងគោលការណ៍ណែនាំស្តីពីការអនុវត្តការកំណត់អត្តសញ្ញាណជាបឋមចំពោះជនរងគ្រោះដោយអំពើជួញដូរមនុស្ស ។ | -ក្រសួង សមត្ថកិច្ច និងអង្គការដៃគូ ។ |
| ក្រុមការងារ COMMIT ចំនួន០៩លើក | ១.ប្រជុំចែករំលែកបទពិសោធន៍ពាក់ព័ន្ធនឹងការងារប្រយុទ្ធប្រឆាំងនឹងអំពើជួញដូរមនុស្ស។<br>២.រៀបចំបទបង្ហាញកិច្ចប្រជុំមន្ត្រីជាន់ខ្ពស់ COMMITលើកទី៨ និងកិច្ចប្រជុំថ្នាក់អន្តររដ្ឋមន្ត្រីលើកទី៣ (២លើក)។<br>៣.ការស្រាវជ្រាវ ស្តីពីការធ្វើសមាហរណកម្ម «**គម្រោងមេអំបៅ**» របស់អង្គការចាប់ដៃ ។<br>៤.បង្ហាញអំពីបច្ចុប្បន្នភាពអនុស្សរណៈ នៃការយោគយល់គ្នារវាងរាជរដ្ឋាភិបាលកម្ពុជា-ម៉ាឡេស៊ី (២លើក)។ | -ក្រសួងពាក់ព័ន្ធ អង្គការ UNIAP និងអង្គការចាប់ដៃ |

| | | |
|---|---|---|
| | ៥.ពិភាក្សាលើសេចក្ដីព្រាងគោលការណ៍ណែនាំ ស្ដីពីកិច្ចសហប្រតិបត្តិការអន្តរជាតិ លើការស៊ើបអង្កេតនិងផ្ដន្ទាទោសករណីជួញដូរមនុស្ស (២លើក) | |
| ក្រុមការងារទប់ស្កាត់ចំនួន០២លើក | ១.ដើម្បីរៀបចំផែនការសកម្មភាពអនុវត្តឆ្នាំ ២០១២-២០១៣ ។<br>២.ប្រជុំប្រមូលសម្ភារៈផ្សព្វផ្សាយ និងការជ្រើសរើសឯកសារ ។ | -សមាជិកក្រុម |
| ក្រុមការងារកិច្ចការកុមារចំនួន០២លើក | ១.ត្រួតពិនិត្យការងារ និងកែសម្រួលផែនការសកម្មភាពសម្រាប់អនុវត្តឆ្នាំ២០១២-២០១៣ ។ | -សមាជិកក្រុមការងារកិច្ចការកុមារ |
| ក្រុមការងារអនុវត្តច្បាប់ចំនួន០៦លើក | ១.រៀបចំផែនការអនុវត្តក្នុងឆ្នាំ២០១២ និងជម្រុញការ អនុវត្តច្បាប់បង្ក្រាបអំពើជួញដូរមនុស្ស ។ | -សមាជិកក្រុមការងារអនុវត្តច្បាប់ |
| ក្រុមការងារសហប្រតិបត្តិការអន្តរជាតិចំនួន០២លើក | ១.ត្រួតពិនិត្យ និងកែសម្រួលផែនការសកម្មភាព សម្រាប់អនុវត្តឆ្នាំ២០១២-២០១៣ ។<br>២.ប្រជុំត្រៀមសម្រាប់ប្រជុំជាមួយភាគីម៉ាឡេស៊ីលើសេចក្ដីព្រាង MOU ក្នុងកិច្ចសហប្រតិបត្តិការ ។ | -សមាជិកក្រុមការងារសហប្រតិបត្តិការអន្តរជាតិ |
| ក្រុមការងារកិច្ចការយុត្តិធម៌ ចំនួន០៦លើក | ១.ត្រួតពិនិត្យ និងកែសម្រួលផែនការសកម្មភាព សម្រាប់អនុវត្តឆ្នាំ២០១២-២០១៣ (០១លើក)។<br>២.ដឹកនាំ និងសម្របសម្រួលកិច្ចពិភាក្សាអំពីច្បាប់ពាក់ព័ន្ធនឹងការរំលោភបំពាន និងការកេងប្រវ័ញ្ចផ្លូវភេទកុមារ (០២លើក)<br>៣.រៀបចំសេចក្ដីព្រាងប្រកាសរួមរវាងក្រសួងមហាផ្ទៃ និងក្រសួងទេសចរណ៍ ស្ដីពី «**សមត្ថកិច្ចរបស់ អធិការកិច្ចទេសចរណ៍ និងនគរបាលទេសចរណ៍**» ។(០១លើក)<br>៤.ចុះទៅខេត្តស្ទឹងត្រែងជួបជាមួយស្ថាប័នអនុវត្តច្បាប់ ដើម្បីធ្វើការវិភាគរឿងក្ដីពាក់ព័ន្ធនឹងអំពើជួញដូរ មនុស្ស ។(០១លើក)<br>៥.ដឹកនាំ និងសម្របសម្រួលកិច្ចប្រជុំបណ្ដាប្រទេសក្នុងមហាអនុតំបន់មេគង្គ ស្ដីពីកិច្ចសហប្រតិបត្តិការអន្តរជាតិប្រឆាំងការជួញដូរមនុស្សក្នុងវិស័យយុត្តិធម៌ព្រហ្មទណ្ឌ (០១លើក) | -សមាជិកក្រុមការងារកិច្ចការយុត្តិធម៌<br>-ក្រសួងទេសចរណ៍<br>-ក្រសួងមហាផ្ទៃ<br>-អង្គការUNODC<br>-អង្គការ ARTIP<br>-នគរបាល<br>-ព្រះរាជអាជ្ញា និងចៅក្រម ។ |
| ក្រុមការងារទេសន្តរ | ១. ប្រជុំដឹកនាំដំណើរការសកម្មភាពក្រុម | -សមាជិកក្រុម |

| | | |
|---|---|---|
| ប្រវេសន៍ចំនួន០៥លើក | ២.ត្រៀមទស្សនកិច្ចសិក្សាក្នុង និងក្រៅប្រទេស (០២លើក)<br>៣.ប្រជុំបូកសរុបដកពិសោធន៍ការងារទស្សកិច្ចសិក្សា (០២លើក) | -អង្គការUN Women<br>-អង្គការពាក់ព័ន្ធមួយចំនួន |
| លេខាធិការដ្ឋាន<br>រាជធានីភ្នំពេញ<br>ចំនួន០១លើក | ១.ដាក់វិធានការ ដើម្បីបង្ការ បង្ក្រាប ទប់ស្កាត់បទល្មើសពាក់ព័ន្ធនឹង ប.ជ.រ.ព.ភ | -មន្ទីរ អង្គភាព អាជ្ញាធរមូលដ្ឋានសង្កាត់ខណ្ឌ របស់សាលារាជធានីភ្នំពេញ ។ |
| លេខាធិការដ្ឋាន<br>ខេត្តកណ្តាល<br>ចំនួន១៣លើក | ត្រួតពិនិត្យ ការងារលេខាធិការដ្ឋានប្រចាំខែ ជម្រុញការងារបង្ការ-ទប់ស្កាត់បទល្មើសជួញដូរមនុស្ស និងពង្រឹងកិច្ចសហការជាមួយអាជ្ញាធរប្រទេសវៀតណាម (សរុប ១៣លើក) | -សមាជិកលេខាធិការដ្ឋានខេត្ត និងអាជ្ញាធរខេត្តជាប់ព្រំដែន ប្រទេសវៀតណាម ។ |
| លេខាធិការដ្ឋាន<br>ខេត្តកោះកុង<br>ចំនួន០៦លើក | ត្រួតពិនិត្យការងារលេខាធិការដ្ឋាន ជម្រុញការងារអនុវត្តផែនការ ការបង្ក្រាបបទល្មើស កិច្ចជួយសង្គ្រោះជនរងគ្រោះ និងពង្រឹងកិច្ចសហការ ជាមួយអាជ្ញាធរប្រទេសថៃ ដើម្បីទប់ស្កាត់បទល្មើសនាំឆ្លងដែនខុសច្បាប់ ។ | -សមាជិកលេខាធិការដ្ឋានខេត្ត អង្គការHCC និងអង្គការដៃគូមួយចំនួន ព្រមទាំងអាជ្ញាធរខេត្តជាប់ព្រំ ដែនប្រទេសថៃ ។ |
| លេខាធិការដ្ឋាន<br>ខេត្តបន្ទាយមានជ័យ<br>ចំនួន០៨លើក | ត្រួតពិនិត្យការងារលេខាធិការដ្ឋាន ជម្រុញការងារអនុវត្តផែនការ និងការបង្ក្រាបបទល្មើស កិច្ចជួយសង្គ្រោះជនរងគ្រោះ ការបង្ការ ទប់ស្កាត់ ពលករចំណាកស្រុក ប្រជុំពិភាក្សាត្រៀម និងរៀបចំវេទិកា១២ធ្នូ និងកិច្ចសហការជាមួយអាជ្ញាធរប្រទេសថៃ ដើម្បីទប់ស្កាត់បទល្មើសឆ្លងដែន ។ | -សមាជិកលេខាធិការដ្ឋានខេត្ត អង្គការBigC, IOM, ARM, KMR, DTP, CWCC, MPK, និងអង្គការដៃគូមួយចំនួន ព្រមទាំងអាជ្ញាធរខេត្តជាប់ព្រំដែន ប្រទេសថៃ ។ |
| លេខាធិការដ្ឋាន<br>ខេត្តសៀមរាប<br>ចំនួន១១លើក | ត្រួតពិនិត្យការងារលេខាធិការដ្ឋាន ដោះស្រាយបញ្ហាដែលបានកើតឡើងនៅក្នុងមូលដ្ឋាន និងផ្លាស់ប្តូរបទពិសោធន៍គ្នាទៅវិញទៅមក ។ | -សមាជិកលេខាធិការដ្ឋានខេត្ត ក្រុង ស្រុក អង្គការCWCC និងអង្គការដៃគូមួយចំនួន ។ |
| លេខាធិការដ្ឋាន<br>ខេត្តព្រះសីហនុ<br>ចំនួន០៧លើក | ត្រួតពិនិត្យការងារលេខាធិការដ្ឋាន ជម្រុញការងារបង្ការទប់ស្កាត់បទល្មើសជួញដូរមនុស្ស និងការ បង្ក្រាបបទល្មើស។ | -សមាជិកលេខាធិការដ្ឋានខេត្ត អង្គការម្លប់តាប៉ាង និងអង្គការ ដៃគូមួយចំនួន ។ |
| -លេខាធិការដ្ឋាន<br>ខេត្តស្វាយរៀង<br>ចំនួន១០លើក | - ត្រួតពិនិត្យការងារលេខាធិការដ្ឋានជម្រុញការងារអនុវត្តច្បាប់ ការបង្ការ ទប់ស្កាត់ ការរៀបចំវេទិកា ១២ធ្នូ និងកិច្ចសហការជាមួយអាជ្ញាធរប្រទេស វៀតណាម ។ | -សមាជិកលេខាធិការដ្ឋានខេត្ត អង្គការChildfun និងដៃគូមួយចំនួន ព្រមទាំងអាជ្ញាធរខេត្តជាប់ព្រំដែនវៀតណាម ។ |
| លេខាធិការដ្ឋាន<br>ខេត្តកំពង់ស្ពឺ | ត្រួតពិនិត្យការងារលេខាធិការដ្ឋាន ជម្រុញការអនុវត្តច្បាប់ ការបង្ក្រាបអំពើជួញដូរមនុស្ស កិច្ច | -សមាជិកលេខាធិការដ្ឋានខេត្ត |

| | | |
|---|---|---|
| ចំនួន០៥លើក | ការពារជនរងគ្រោះ និងការស្វែងរកដំណោះស្រាយបញ្ហាពលករធ្វើចំណាកស្រុក | |
| លេខាធិការដ្ឋានខេត្តព្រៃវែង ចំនួន០៥លើក | ត្រួតពិនិត្យការងារលេខាធិការដ្ឋាន ជម្រុញការអនុវត្តច្បាប់ ការបង្ក្រាបអំពើជួញដូរមនុស្ស កិច្ចការពារជនរងគ្រោះ និងការស្វែងរកដំណោះស្រាយបញ្ហាពលករធ្វើចំណាកស្រុក និងការរៀបចំវេទិកា ១២ធ្នូ ។ | -សមាជិកលេខាធិការដ្ឋានខេត្ត និងអង្គការដៃគូ ។ |
| លេខាធិការដ្ឋានខេត្តតាកែវ ចំនួន០៤លើក | ត្រួតពិនិត្យការងារលេខាធិការដ្ឋាន ជម្រុញការអនុវត្តច្បាប់ ការបង្ក្រាបអំពើជួញដូរមនុស្ស កិច្ចការ ពារជនរងគ្រោះ និងការទប់ស្កាត់បញ្ហាពលករធ្វើ ចំណាកស្រុក ។ | -សមាជិកលេខាធិការដ្ឋានខេត្ត |
| លេខាធិការដ្ឋានខេត្តព្រះវិហារ ចំនួន០៨លើក | ត្រួតពិនិត្យ ការងារលេខាធិការដ្ឋាន ជម្រុញការអនុវត្តច្បាប់ ការបង្ក្រាបអំពើជួញដូរមនុស្ស កិច្ចការ ពារជនរងគ្រោះ និងការផ្តន្ទាទោសជនល្មើស ។ | -សមាជិកលេខាធិការដ្ឋានខេត្ត |
| លេខាធិការដ្ឋាន ខេត្តកំពង់ឆ្នាំង ចំនួន០៧លើក | ត្រួតពិនិត្យ ការងារលេខាធិការដ្ឋាន ជម្រុញការអនុវត្តច្បាប់ ការបង្ក្រាបអំពើជួញដូរមនុស្ស កិច្ចការពារជនរងគ្រោះ និងការទប់ស្កាត់បញ្ហាពលករ ធ្វើចំណាក ស្រុក ។ | សមាជិកលេខាធិការដ្ឋានខេត្ត និងអង្គការដៃគូ |
| លេខាធិការដ្ឋានខេត្តក្រចេះ ចំនួន០៤លើក | ត្រួតពិនិត្យការងារលេខាធិការដ្ឋាន ជម្រុញការអនុវត្តច្បាប់ ការបង្ក្រាបអំពើជួញដូរមនុស្ស កិច្ចការ ពារជនរងគ្រោះ និងការទប់ស្កាត់ បញ្ហាពលករធ្វើចំណាកស្រុក ។ | -សមាជិកលេខាធិការដ្ឋានខេត្ត |
| លេខាធិការដ្ឋានខេត្តបាត់ដំបង ចំនួន០៤លើក | ត្រួតពិនិត្យ ការងារលេខាធិការដ្ឋាន និងជម្រុញការងារអនុវត្តផែនការ ការបង្ក្រាបបទល្មើសជួញដូរមនុស្ស ជួយសង្គ្រោះជនរងគ្រោះនិងទប់ស្កាត់បញ្ហាពលករធ្វើចំណាកស្រុក ។ | -សមាជិកលេខាធិការដ្ឋានខេត្ត |
| លេខាធិការដ្ឋានខេត្តកំពត ចំនួន០២លើក | ត្រួតពិនិត្យ ការងារលេខាធិការដ្ឋាន និងជម្រុញការងារអនុវត្តផែនការ ការបង្ក្រាបបទល្មើសជួញដូរមនុស្ស ជួយសង្គ្រោះជនរងគ្រោះនិងទប់ស្កាត់ បញ្ហាពលករធ្វើចំណាកស្រុក ។ | -សមាជិកលេខាធិការដ្ឋានខេត្ត |
| លេខាធិការដ្ឋានខេត្តកែប ចំនួន០១លើក | ត្រួតពិនិត្យ ការងារលេខាធិការដ្ឋាន និងជម្រុញការងារអនុវត្តផែនការ ការបង្ក្រាបបទល្មើសជួញដូរមនុស្ស ជួយសង្គ្រោះជនរងគ្រោះនិងទប់ស្កាត់ បញ្ហាពលករធ្វើចំណាក ស្រុក ។ | -សមាជិកលេខាធិការដ្ឋានខេត្ត |
| លេខាធិការដ្ឋាន | ត្រួតពិនិត្យ ការងារលេខាធិការដ្ឋាន និងជម្រុញ | -សមាជិកលេខាធិការដ្ឋាន |

| | | |
|---|---|---|
| ខេត្តប៉ៃលិន ចំនួន០៥លើក | ការងារអនុវត្តផែនការ ការបង្ក្រាបបទល្មើស ជួញដូរមនុស្ស ជួយសង្គ្រោះជនរងគ្រោះនិងទប់ស្កាត់ បញ្ហាពលករធ្វើចំណាក ស្រុក ។ | ខេត្ត អង្គការពុទ្ធសាសនាដើម្បីអភិវឌ្ឍន៍ ។ |
| លេខាធិការដ្ឋាន ខេត្តកំពង់ចាម ចំនួន០១លើក | ត្រួតពិនិត្យ ការងារលេខាធិការដ្ឋាន និងជម្រុញការងារអនុវត្តផែនការ ការបង្ក្រាបបទល្មើស ជួញដូរមនុស្ស ជួយសង្គ្រោះជនរងគ្រោះនិងទប់ស្កាត់ បញ្ហាពលករធ្វើចំណាក ស្រុក ។ | -សមាជិកលេខាធិការដ្ឋានខេត្ត |
| លេខាធិការដ្ឋាន ខេត្តពោធិ៍សាត់ ចំនួន០១លើក | ត្រួតពិនិត្យ ការងារលេខាធិការដ្ឋាន និងជម្រុញការងារអនុវត្តផែនការ ការបង្ក្រាបបទល្មើស ជួញដូរមនុស្ស ជួយសង្គ្រោះជនរងគ្រោះនិងទប់ស្កាត់ បញ្ហាពលករធ្វើចំណាក ស្រុក ។ | -សមាជិកលេខាធិការដ្ឋានខេត្ត |
| លេខាធិការដ្ឋាន ខេត្តកំពង់ធំ ចំនួន០៤លើក | ត្រួតពិនិត្យ ការងារលេខាធិការដ្ឋាន និងជម្រុញការងារអនុវត្តផែនការ ការបង្ក្រាបបទល្មើស ជួញដូរមនុស្ស ជួយសង្គ្រោះជនរងគ្រោះនិងទប់ស្កាត់ បញ្ហាពលករធ្វើចំណាក ស្រុក ។ | -សមាជិកលេខាធិការដ្ឋានខេត្ត |
| លេខាធិការដ្ឋាន ខេត្តរតនៈគីរី ចំនួន០១លើក | ត្រួតពិនិត្យ ការងារលេខាធិការដ្ឋាន និងជម្រុញការងារអនុវត្តផែនការ ការបង្ក្រាបបទល្មើស ជួញដូរមនុស្ស ជួយសង្គ្រោះជនរងគ្រោះនិងទប់ស្កាត់ បញ្ហាពលករធ្វើចំណាកស្រុក ។ | -សមាជិកលេខាធិការដ្ឋានខេត្ត |
| លេខាធិការដ្ឋាន ខេត្តស្ទឹងត្រែង ចំនួន០១លើក | ត្រួតពិនិត្យការងារលេខាធិការដ្ឋាន និងជម្រុញការងារអនុវត្តផែនការ ការបង្ក្រាបបទល្មើស ជួញដូរមនុស្ស ជួយសង្គ្រោះ ជនរងគ្រោះនិងទប់ស្កាត់ បញ្ហាពលករធ្វើចំណាកស្រុក ។ | -សមាជិកលេខាធិការដ្ឋានខេត្ត |
| លេខាធិការដ្ឋាន ខេត្តឧត្តរមានជ័យ ចំនួន០១លើក | ត្រួតពិនិត្យ ការងារលេខាធិការដ្ឋាន និងជម្រុញការងារអនុវត្តផែនការ ការបង្ក្រាបបទល្មើស ជួញដូរមនុស្ស និងកិច្ចជួយសង្គ្រោះជនរងគ្រោះនិងទប់ស្កាត់ បញ្ហាពលករធ្វើចំណាកស្រុក ។ | -សមាជិកលេខាធិការដ្ឋានខេត្ត |
| លេខាធិការដ្ឋាន ខេត្តមណ្ឌលគីរី ចំនួន០១លើក | ត្រួតពិនិត្យ ការងារលេខាធិការដ្ឋាន និងជម្រុញការងារអនុវត្តផែនការ ការបង្ក្រាបបទល្មើស ជួញដូរមនុស្ស ជួយសង្គ្រោះជនរងគ្រោះនិងទប់ស្កាត់ បញ្ហាពលករធ្វើចំណាក ស្រុក ។ | -សមាជិកលេខាធិការដ្ឋានខេត្ត |

**គ- ការងារអនុវត្តន៍យុទ្ធសាស្ត្រប្រឆាំងការជួញដូរមនុស្ស:**

**១- ការងារបង្ការ-ទប់ស្កាត់:**

**១.១- ការផ្សព្វផ្សាយ អប់រំ បង្ការៈ**

ក្នុងឆ្នាំ២០១២កន្លងទៅនេះៈ

- លេខាធិការដ្ឋានជាតិដឹកនាំ ប.ជ.រ.ព.ភ បានពិនិត្យទៅលើការងារផ្សព្វផ្សាយទាំងនៅថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ ដែលបានសហការជាមួយអង្គការដៃគូ ដូចជា USAID, UNIAP, Winrock International, World Vision Cambodia, UNODC, IOM, CWCC, HCC, APLE, ECPAT Cambodia, Chabdai, UN Women, Child Fund, មូលនីធិសូម៉ាលីម៉ម, សម្ព័ន្ធអង្គការជួយកុមារតាមព្រំដែន (BigC) និងអង្គការ MTV Exit ធ្វើការផ្សព្វផ្សាយ ជាសាធារណៈអំពីៈ
  - ច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ
  - កិច្ចការពារជនរងគ្រោះដោយអំពើជួញដូរមនុស្ស
  - ឧបាយកលជនល្មើស
  - ការធ្វើចំណាកស្រុក ដោយសុវត្ថិភាព
  - ភាពគ្រោះថ្នាក់ផ្សេងៗពីការធ្វើទេសន្តរប្រវេសន៍ការងារក្រៅប្រទេសដោយប្រថុយប្រថាន
  - ការលុបបំបាត់ទម្រង់ធ្ងន់ធ្ងរ នៃពលកម្មកុមារដើម្បីឲ្យកុមារបានចូលរៀនសូត្រ
  - ការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

  ឲ្យដល់មន្ត្រីពាក់ព័ន្ធ ជនបង្គោល និងប្រជាពលរដ្ឋ សរុបចំនួន **៥១៦,៣៩៧**នាក់ (ស្រី **២២១,១៧៧**នាក់) ។ ទន្ទឹមនឹងនោះ សម្ភារៈមានដូចជា ផ្ទាំងរូបភាពបិទតាមរ៉ឺម៉កម៉ូតូចំនួន ១៧៥គ្រឿង CDនិងDVD សៀវភៅរឿងអប់រំ ខិត្តប័ណ្ណ ប្រតិទិនចំនួន២.០០០សន្លឹក អាវយឺត ផ្ទាំងរូបភាព (ប៉ាណូ) ត្រូវបានផលិត ដាក់តាំងនិងផ្សព្វផ្សាយ ។

  ការផ្សព្វផ្សាយធ្វើឡើងក្នុងគោលបំណងផ្តល់ការយល់ដឹងជាសាធារណៈ តាមរយៈវិទ្យុ ទូរទស្សន៍ វេទិកានៃទិវា១២ធ្នូប្រឆាំងអំពើជួញដូរមនុស្ស ការប្រគំតន្ត្រីសម្រាប់យុវវ័យ និងកម្មវិធីផ្សេងៗទៀត ក្នុងនោះមាន ៖

- <u>ក្រសួងអប់រំ យុវជន និងកីឡាៈ</u>
  - បានផលិត និងចាក់ផ្សាយឈុតរឿងខ្លីៗ ស្តីពីសិទ្ធិទទួល ការអប់រំ និងពលកម្មកុមារ (កុមារបំរើតាមផ្ទះ) ក្នុងកម្មវិធីទូរទស្សន៍ជាតិកម្ពុជា និងបានថតចម្លងជាDVD ផ្តល់ជូនដល់គ្រប់ មន្ទីរការិយាល័យ រាជធានី-ខេត្ត ដើម្បីផ្សព្វផ្សាយទូទាំង ២៤ខេត្ត និងរាជធានី ។
  - បានធ្វើការផ្សព្វផ្សាយ លើកកម្ពស់ការយល់ដឹងការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទដល់មន្ត្រីថ្នាក់មន្ទីរចំនួន**៩៨នាក់ (ស្រី១៦នាក់)** មកពីខេត្តចំនួន០៥ (ក្រចេះ ស្ទឹងត្រែង រតនៈគីរី កំពង់ចាម និងមណ្ឌលគីរី ) ។
  - សិក្ខាសាលាពិគ្រោះយោបល់លើការទប់ស្កាត់ការបោះបង់សាលា ដើម្បីបង្ការទប់ស្កាត់ការជួញដូរមនុស្ស និងផ្សព្វផ្សាយច្បាប់ ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ដល់-មន្ទីរ ការិយាល័យក្រុង-ស្រុក ខណ្ឌ និងសាលារៀនមកពីខេត្តបាត់ដំបង, ប៉ៃលិន និង ខេត្តពោធិ៍សាត់ ក្រចេះ ស្ទឹងត្រែង រតនៈគីរី មណ្ឌលគីរី ស្វាយរៀង ព្រៃវែង កណ្តាល កំពង់ចាម (ចំនួន០៤លើក) ។

- <u>ក្រសួងកិច្ចការនារីៈ</u>

- បានចុះធ្វើសកម្មភាពផ្សព្វផ្សាយនៅថ្នាក់ភូមិ និងសហគមន៍ ស្តីពី ការទប់ស្កាត់អំពើជួញដូរមនុស្ស និងការធ្វើចំណាកស្រុកដោយប្រថុយប្រថាន នៅតាមភូមិចំនួន៣៦ ក្នុងស្រុកចំនួន០៣របស់ខេត្តព្រះវិហារ និងស្រុកបីក្នុងខេត្តបាត់ដំបង ដោយមានប្រជាពលរដ្ឋ **១.៥២០នាក់** (ស្រី**៧១៣នាក់**) ចូលរួម ។

- ក្រសួងទេសចរណ៍៖
  - បានសហការជាមួយអង្គការអ៊ិកផាតកម្ពុជា ផ្សព្វផ្សាយផ្ទាំងរូបភាពតាមរ៉ឺម៉កម៉ូតូកង់បីក្នុងរាជធានីភ្នំពេញ និងខេត្តព្រះសីហនុចំនួន**១២០**គ្រឿង ដែលមានសារអប់រំដល់ភ្ញៀវទេសចរ "Join us to Protect our Children, Welcome Responsible Tourists" ៖ ចូលរួមជាមួយយើងខ្ញុំ ដើម្បីការពារកុមារ សូមស្វាគមន៍អ្នកទេសចរ ដែលមានការទទួលខុសត្រូវ ។
  - បានរៀបចំផ្លាស់ប្តូរផ្ទាំងរូបភាពថ្មីសម្រាប់ធ្វើការផ្សព្វផ្សាយ តាមបណ្តោយផ្លូវជាតិលេខ៦ មួយកន្លែង ស្ថិតនៅក្នុងភូមិឈើទាល ឃុំផ្តៅ ស្រុកជើងព្រៃ ខេត្តកំពង់ចាម
  - សហការជាមួយលេខាធិការដ្ឋានគណៈកម្មាធិការជាតិ និងអង្គការឆាយវ៉ាយស៍ ដាក់តាំងរូបភាពប្រឆាំងការកេងប្រវ័ញ្ចផ្លូវភេទលើកុមារក្នុងសួនច្បារមាត់ទន្លេមុខព្រះបរមរាជវាំង
  - បានធ្វើការអប់រំ និងបណ្តុះបណ្តាលស្តីពី ការលើកកម្ពស់សុវត្ថិភាពកុមារក្នុងវិស័យទេសចរណ៍ ជូននិយោជិត ប្រតិបត្តិករទេសចរណ៍ មគ្គុទ្ទេសក៍ទេសចរណ៍ក្នុងឧស្សាហកម្មទេសចរណ៍ និងគណៈកម្មាធិការពិគ្រោះយោបល់ស្ត្រី និងកុមារបានចំនួន ១១វគ្គ នៅរាជធានី ខេត្ត ចំនួន៥ រួមមាន ៖ រាជធានីភ្នំពេញ ខេត្តសៀមរាប ខេត្តព្រះសីហនុ ខេត្តបាត់ដំបង និងខេត្តមណ្ឌលគីរីដោយមាន សិក្ខាកាមចូលរួម សរុបចំនួន**៦៨២នាក់** (ស្រី**២៩៤**នាក់) ។

- ក្រុមការងារCOMMIT កម្ពុជា និងអង្គការUNIAP៖
  - សហការជាមួយមណ្ឌលព័ត៌មានស្ត្រីកម្ពុជា អនុវត្តកម្មវិធីសន្ទនាតាមវិទ្យុ FM១០២ ស្តីពី «**ការជួញដូរមនុស្ស និងការធ្វើចំណាកស្រុក**» ដែលផ្តោតលើប្រធានបទ១៤ ក្នុងនោះមានការផ្សព្វផ្សាយបន្តផ្ទាល់រយៈពេលមួយម៉ោងក្នុងមួយសប្តាហ៍ និងចាក់ផ្សាយឡើងវិញ រយៈពេល៣០នាទី ។
  - សហការជាមួយក្រុមការងារកិច្ចការយុត្តធម៌ នៃលេខាធិការដ្ឋាន ប.ជ.រ.ព.ភ ផ្សព្វផ្សាយច្បាប់ចំនួន០៧លើក មានអ្នកចូលរួមសរុប ២៩០នាក់ ។

- អគ្គស្នងការដ្ឋាននគរបាលជាតិ៖
  - បានផ្សព្វផ្សាយច្បាប់ ស្តីពីការបង្រ្កាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ និងគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព ដល់អាជ្ញាធរមូលដ្ឋាន និងប្រជាពលរដ្ឋបានចំនួន**១៣,៥២៤នាក់** (ស្រី**៣,៥២៤នាក់**) ។

- អង្គការសកម្មភាពដើម្បីកុមារ(APLE)៖
  - ផ្សព្វផ្សាយផ្ទាំងរូបភាពតាមរ៉ឺម៉កម៉ូតូកង់បីនៅរាជធានី ភ្នំពេញ ខេត្តព្រះសីហនុ និងខេត្តសៀមរាបចំនួន៥៥គ្រឿង ដែលមានសារអប់រំ "**ចូរយកចិត្តទុកដាក់ការពារកុមារពីការបៀតបៀនផ្លូវភេទ**" ។

- អង្គការ MTV Exit៖

- ផ្សព្វផ្សាយរឿង « **ជាតិជាទាសករ** » ដើម្បីលើកកម្ពស់ការយល់ដឹង និងបង្កើនការទប់ស្កាត់អំពើជួញដូរមនុស្សនៅកម្ពុជា នៅរាជធានី-ខេត្តចំនួន០៧ គឺ: រាជធានី ភ្នំពេញ ខេត្តព្រៃវែង កំពង់ចាម បន្ទាយមានជ័យ កោះកុង ស្វាយរៀង និងខេត្តសៀមរាប ដោយមានប្រជាពលរដ្ឋចូលរួមចំនួន**១៩,១៩៣**នាក់។

- <u>លេខាធិការដ្ឋានដឹកនាំ ប.ជ.រ.ព.ភ ខេត្តស្វាយរៀង៖</u>
  - បានសហការជាមួយអង្គការ Child Fund បោះពុម្ព និងផ្តល់ជូនប្រក្រតិទិនឆ្នាំ២០១២ ចំនួន២,០០០សន្លឹក ដល់អាជ្ញាធរមូលដ្ឋាន ដើម្បីបិទផ្សព្វផ្សាយឱ្យប្រជាពលរដ្ឋយល់ដឹងពីការធ្វើចំណាកស្រុកដោយសុវត្ថិភាព ។
- <u>លេខាធិការដ្ឋានដឹកនាំ ប.ជ.រ.ព.ភ ខេត្តកោះកុង៖</u>
  - បានផលិតសៀវភៅផ្ទត់ និងCD ដើម្បីផ្សព្វផ្សាយ ដែលមានខ្លឹមសារអប់រំអំពីការធ្វើចំណាកស្រុកដោយសុវត្ថិភាព ។
- <u>គណៈកម្មាធិការដឹកនាំ ប.ជ.រ.ព.ភ ខេត្តចំនួន០៤៖</u>
  - ខេត្តបួនបានប្រារព្ធវេទិកាជាតិ១២ធ្នូប្រឆាំង នឹងអំពើជួញដូរមនុស្ស ដោយមានប្រជាពលរដ្ឋចូលរួមសរុបចំនួន**៣,៥៣៥**នាក់ ក្នុងនោះ ខេត្តបន្ទាយមានជ័យ បានរៀបចំជាមិទ្ទិញនៅតំបន់ព្រំដែនក្នុងក្រុងប៉ោយប៉ែត ដោយអនុញ្ញាតឲ្យមានការចូលរួមពីអាជ្ញាធរ និងប្រជាជនថៃប្រមាណ២០០នាក់ពីខេត្តស្រះកែវ ក្រោមអធិបតីភាពលោកជំទាវ ជូ ប៊ុនអេង ប្រធានលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិ ប.ជ.រ.ព.ភ ។

ចំនួនអ្នកចូលរួមសរុបមានដូចខាងក្រោម:

| ល.រ. | ខេត្ត | ចំនួនអ្នកចូលរួមសរុប | អ្នកចូលរួមជាស្ត្រី |
|---|---|---|---|
| ១. | បន្ទាយមានជ័យ | ១,៦០៥នាក់ | ៧១៤នាក់ |
| ២. | ស្វាយរៀង | ៦០០នាក់ | ២៨២នាក់ |
| ៣. | ព្រៃវែង | ៨០០នាក់ | - |
| ៤. | កោះកុង | ៥៣០នាក់ | - |
| | សរុប | ៣.៥៣៥នាក់ | |

ដោយឡែក លេខាធិការដ្ឋានប.ជ.រ.ព.ភ រាជធានីភ្នំពេញ ខេត្តកំពង់ចាម និងខេត្តសៀមរាប ក្រោមការឧបត្ថម្ភគាំទ្រពីអង្គការវិនរ៉ក់អន្តរជាតិ (Winrock International) បានធ្វើការចែកផ្សាយសម្ភារៈមួយចំនួន សម្រាប់ជាការប្រារព្ធទិវាប្រឆាំងការជួញដូរ មនុស្សនៅកម្ពុជា ក្នុងនោះសម្ភារៈដែលបានបែងចែកមានដូចខាងក្រោម ៖

| ល.រ. | រាជធានី ខេត្ត | ចំនួនអាវ | ចំនួនមួក | ចំនួនបដា | ចំនួនអ្នកចូលរួម |
|---|---|---|---|---|---|
| ១. | រាជធានីភ្នំពេញ | ២៥០ | ២៥០ | ០៤ផ្ទាំង | ២៥០នាក់ |
| ២. | កំពង់ចាម | ១២០ | ១២០ | ០២ផ្ទាំង | ២៥៦នាក់ (ស្ត្រី២០៤នាក់) |
| ៣. | សៀមរាប | ១២០ | ១២០ | ០៥ផ្ទាំង | ៥៦០នាក់ (ស្ត្រី២៥០នាក់) |

| | សរុប | ៩៩០ | ៩៩០ | ១១ផ្ទាំង | ១.៥៦៦នាក់ |
|---|---|---|---|---|---|

- គណៈកម្មាធិការដឹកនាំ ប.ជ.រ.ព.ភ និងលេខាធិការដ្ឋានរាជធានី-ខេត្ត បានរៀបចំ វេទិកាសាធារណៈ និងធ្វើការផ្សព្វផ្សាយច្បាប់ពាក់ព័ន្ធអំពើជួញដូរមនុស្ស និងកិច្ចការពារជនរងគ្រោះ គោលនយោបាយភូមិឃុំមានសុវត្ថិភាព និងសុវត្ថិភាព ចំណាកស្រុកទៅរកការងារធ្វើនៅក្រៅ ប្រទេសសរុបបានចំនួន**៤៧៩,៣២៧**នាក់ (ស្រី**២១៦,២៥៥**នាក់) ក្នុងនោះមាន ៖

តារាងវេទិកាសាធារណៈដែលរាជធានីខេត្តបានរៀបចំ៖

| **ល.រ** | **លេខាធិការដ្ឋានរាជធានី ខេត្ត** | **ចំនួនអ្នកចូលរួម** | **ចំនួនស្ត្រី** |
|---|---|---|---|
| ១. | រាជធានីភ្នំពេញ | ៥៦,៥០២នាក់ | ៨,៧១៦នាក់ |
| ២. | ខេត្តកណ្ដាល | ២១,៧១៦នាក់ | ១២,៨៧៨នាក់ |
| ៣. | ខេត្តស្វាយរៀង | ៩,៤៩៦នាក់ | ២,៦១២នាក់ |
| ៤. | ខេត្តសៀមរាប | ១៣,១០៦នាក់ | ៧,៩៦៤នាក់ |
| ៥. | ខេត្តកំពង់ឆ្នាំង | ៤,០២២នាក់ | ២,២០០នាក់ |
| ៦. | ខេត្តព្រះវិហារ | ៨៩,៩២៨នាក់ | ៤៩,៩៥៥នាក់ |
| ៧. | ខេត្តព្រះសីហនុ | ៤,៣៣៨នាក់ | ១,៧៤២នាក់ |
| ៨. | ខេត្តក្រចេះ | ៩៦៥នាក់ | ៥២៥នាក់ |
| ៩. | ខេត្តកំពង់ស្ពឺ | ៩,៥២១នាក់ | ៤,៨១១នាក់ |
| ១០. | ខេត្តបាត់ដំបង | ១២៥,៣២៨នាក់ | ៥៧,៩៧៤នាក់ |
| ១១. | ខេត្តកំពង់ធំ | ៤៧៨នាក់ | ១៨២នាក់ |
| ១២. | ខេត្តតាកែវ | ៤២០នាក់ | ៣៤០នាក់ |
| ១៣. | ខេត្តបន្ទាយមានជ័យ | ៧៤៦នាក់ | ២៦៩នាក់ |
| ១៤. | ខេត្តកំពត | ២,៤២១នាក់ | ១,៧១៩នាក់ |
| ១៥. | ខេត្តកែប | ១០,២៦០នាក់ | ៤,២៨៤នាក់ |
| ១៦. | ខេត្តប៉ៃលិន | ៩៦៤នាក់ | ២៤នាក់ |
| ១៧. | ខេត្តព្រៃវែង | ៤,០៩១នាក់ | ២,២៨៣នាក់ |
| ១៨. | ខេត្តកោះកុង | ១,១៧៣នាក់ | ៦៩៤នាក់ |
| ១៩. | ខេត្តពោធិ៍សាត់ | ១២១,៩៥៥នាក់ | ៦១,១០៨នាក់ |
| ២០. | ខេត្តមណ្ឌលគីរី | ១,៨៩៧នាក់ | ៩៧៥នាក់ |
| | សរុប | **៤៧៩,៣២៧**នាក់ | **២១៦,២៥៥**នាក់ |

**១.២- ការអនុវត្តវិធានការទប់ស្កាត់**

ពិនិត្យជារួម ក្នុងឆ្នាំ២០១២នេះ សមត្ថកិច្ចទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ បានរួមសហការជាមួយស្ថាប័នជំនាញ អង្គការពាក់ព័ន្ធ អនុវត្តការងារបង្ការទប់ស្កាត់មានលទ្ធផល ដូចខាងក្រោម ៖

- <u>ស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត:</u>
  - ល្បាតឃ្លាំមើលគោលដៅសង្ស័យប្រព្រឹត្តបទល្មើសសញ្ជារកម្មចំនួន២១០លើក លើ១២០ គោលដៅ
  - ណែនាំដល់បណ្ដាម្ចាស់អាជីវកម្មពាក់ព័ន្ធមិនឱ្យប្រព្រឹត្តអំពើសញ្ជារកម្មបានចំនួន៧១០ គោលដៅ ។
  - ប្រមូលនារីរកស៊ីផ្លូវភេទតាមផ្លូវសាធារណ:ធ្វើឲ្យប៉ះពាល់សណ្ដាប់ធ្នាប់ បានចំនួន ៩៥០ នាក់ ដោយប្រគល់ឲ្យមន្ទីរសង្គមកិច្ចរាជធានីភ្នំពេញធ្វើការអប់រំ និងស្ដារ នីតិសម្បទា ។
  - បានកំណត់មុខសញ្ញាដែលសង្ស័យថាជាមេខ្យល់ ឬជាមេខ្យល់មួយចំនួន ។
  - តាមដានបច្ចុប្បន្នភាពស្ថិតិ និងគ្រប់គ្រងប្រជាពលរដ្ឋខ្មែរ ដែលធ្វើចំណាកស្រុកស្វែងរកការងារដោយប្រថុយប្រថាន ដោយប្រៀបធៀបតួលេខប្រែប្រួលតាមខែក្នុងឆ្នាំ២០១២ មានដូចខាងក្រោម ។

តារាងប្រជាជនចំណាកស្រុកគិតតាមខែ៖

| ល.រ. | តួលេខគិតត្រឹមខែ | ចំនួនប្រ/រដ្ឋប្រែប្រួលតាមខែនីមួយៗ | ចំនួនស្ត្រី |
|---|---|---|---|
| ១. | មករា | ១៣០,១៣០នាក់ | ៥២,៥៦៥នាក់ |
| ២. | កុម្ភៈ | ១៣៦,៤៨២នាក់ | ៥៥,២៨៤នាក់ |
| ៣. | មិនា | ១៤៥,១៧៥នាក់ | ៦០,១៩១នាក់ |
| ៤. | មេសា | ១៤៥,៣៨៩នាក់ | ៦០,១១៨នាក់ |
| ៥. | ឧសភា | ១៦៩,២៣៩នាក់ | ៦៩,៣៣១នាក់ |
| ៦. | មិថុនា | ១៧៦,៩២២នាក់ | ៧៣,៤៩១នាក់ |
| ៧. | កក្កដា | ១៨១,០៨៨នាក់ | ៧៦,៤០៩នាក់ |
| ៨. | សីហា | ២០០,០៧៦នាក់ | ៨២,៩១៥នាក់ |
| ៩. | កញ្ញា | ២០៩,៨៧៩នាក់ | ៨៦,៣៤០នាក់ |
| ១០. | តុលា | ២០៧,០៦៤នាក់ | ៨៧,៦៩១នាក់ |
| ១១. | វិច្ឆិកា | ២២៧,២៥៣នាក់ | ៩៤,៩៤៦នាក់ |
| ១២. | ធ្នូ | ១៤២,០៦៥នាក់ | ៥៩,៨២០នាក់ |

*<u>សម្គាល់</u>៖ ចំនួននេះ មិនបានញែកចំនួនអ្នកដែលត្រឡប់ទៅមកទេ ពោលគឺគ្រាន់តែអាចប៉ាន់ប្រមាណពីទំហំនៃភាពចល័តចំណាកស្រុករបស់ប្រជាពលរដ្ឋប្រចាំខែប៉ុណ្ណោះ ។*

<u>ក្រាហ្វិកនៃចំណាកស្រុកតាមខែនីមួយៗ</u>



- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ៖
  - បានរំលឹក ដាស់តឿនដល់ទីភ្នាក់ងារជ្រើសរើសពលករស្របច្បាប់ អំពីចំណុចដែលគួរប្រុងប្រយ័ត្ន ដូចជា៖ ការជ្រើសរើសអនីតិជន ការរៀបចំឯកសារដោយក្លែងបន្លំជាដើម តាមរយៈកិច្ចប្រជុំ ២លើក ក្នុងឆ្នាំ២០១២។
  - សហការជាមួយអង្គការការងារអន្តរជាតិ គម្រោងត្រីកោណ (ILO-Triangle) រៀបចំកម្មវិធីអប់រំណែនាំតម្រង់ទិសពលករមុនពេលចេញដំណើរ
  - ចូលរួមជាវាគ្មិនក្នុងកម្មវិធីផ្សព្វផ្សាយតាមវិទ្យុ និងទូរទស្សន៍ ដើម្បីលើកកម្ពស់ការយល់ដឹងអំពីច្បាប់ បទបញ្ជា និងបទបញ្ញត្តិនានា ពាក់ព័ន្ធនឹងការធ្វើទេសន្តរប្រវេសន៍ការងារ
  - បានសហការជាមួយអង្គការ ILO និង Winrock International ផលិតស្ប៉ត់ ស្តីពីការពារសិទ្ធិរបស់ពលករទេសន្តរប្រវេសន៍ពីការកេងប្រវ័ញ្ចកម្លាំងពលកម្ម និងការជួញដូរមនុស្សសម្រាប់ផ្សព្វផ្សាយ និងលើកកម្ពស់ការយល់ដឹងជាសាធារណៈ។
- លេខាធិការដ្ឋាន នៃគណៈកម្មាធិការដឹកនាំ ប.ជ.រ.ព.ភ រាជធានី-ខេត្ត ៖

លេខាធិការដ្ឋានខេត្តចំនួន០៨ (បន្ទាយមានជ័យ បាត់ដំបង កំពង់ឆ្នាំង ស្ទឹងត្រែង កោះកុង ព្រះសីហនុ កំពង់ស្ពឺ និងខេត្តព្រះវិហារ) បានអប់រំ និងបង្ការទប់ស្កាត់ សរុបបានចំនួន ៦០,៣៤៧ នាក់ ស្រីចំនួន២៤,២៣០នាក់ ។

តារាងសកម្មភាពអប់រំបង្ការ

| ល.រ . | លេខាធិការដ្ឋានខេត្ត | សកម្មភាពទប់ស្កាត់ | ចំនួនរួម | ស្រី |
|---|---|---|---|---|
| ១. | បន្ទាយមានជ័យ | -ទប់ស្កាត់ ដោយអប់រំប្រជាពលរដ្ឋដែលត្រៀមធ្វើ ចំណាកស្រុកឆ្លងដែនខុសច្បាប់ទៅធ្វើការ នៅប្រទេសថៃ<br>-អប់រំពលករចំណាកស្រុកឆ្លងកាត់ព្រំដែនទៅធ្វើការព្រឹក និងត្រឡប់វិញល្ងាច | ៣,៣១៨នាក់<br><br>៥០,០៨២នាក់ | ១,២១៤នាក់<br><br>២១,២៨៦នាក់ |
| ២. | បាត់ដំបង | -ទប់ស្កាត់ ដោយអប់រំប្រជាពលរដ្ឋដែលត្រៀមធ្វើ ចំណាកស្រុកដោយខុសច្បាប់ទៅធ្វើការ នៅប្រទេសថៃ | ៦,៥៤៥នាក់ | ១,៦៥៥នាក់ |
| ៣. | កំពង់ឆ្នាំង | -ទប់ស្កាត់ ដោយអប់រំប្រជាពលរដ្ឋដែលត្រៀមធ្វើ ចំណាកស្រុកដោយប្រថុយប្រថានទៅធ្វើការនៅប្រទេសថៃ | ២៣០នាក់ | ៥៥នាក់ |
| ៤. | ស្ទឹងត្រែង | -ទប់ស្កាត់ ដោយអប់រំប្រជាពលរដ្ឋដែលត្រៀមធ្វើ ចំណាកស្រុកដោយខុសច្បាប់ទៅធ្វើការ នៅប្រទេសថៃ | ៦៨ នាក់ | |

| | | | | |
|---|---|---|---|---|
| ៥. | កោះកុង | -ទប់ស្កាត់ ដោយអប់រំប្រជាពលរដ្ឋដែលត្រៀមធ្វើ ចំណាកស្រុកដោយខុសច្បាប់ទៅធ្វើការ នៅប្រទេសថៃ | ៦០នាក់ | ១១នាក់ |
| ៦. | ព្រះសីហនុ | -ទប់ស្កាត់ ដោយអប់រំប្រជាពលរដ្ឋដែលត្រៀមធ្វើ ចំណាកស្រុកដោយប្រថុយប្រថានទៅធ្វើការនៅប្រទេសថៃ | ១៨នាក់ | |
| ៧. | កំពង់ស្ពឺ | -ទប់ស្កាត់ ដោយអប់រំប្រជាពលរដ្ឋដែលធ្វើចំណាក ស្រុកដោយប្រថុយប្រថាន | ២១នាក់ | ០៥នាក់ |
| ៨. | ព្រះវិហារ | -អប់រំ ប្រជាពលរដ្ឋ ដែលបបួលអ្នកភូមិឲ្យទៅធ្វើការជាមួយនៅក្រៅប្រទេសខុសច្បាប់ | ០៥នាក់ | ០៤នាក់ |
| | ៨ខេត្ត | សរុបប្រជាពលរដ្ឋទទួលបានការអប់រំ | ៦០,៣៤៧នាក់ | ២៤,២៣០នាក់ |

**២- ការងារការពារ-ស្តារនីតិសម្បទា សមាហរណកម្ម និងមាតុភូមិនិវត្តន៍:**

**២.១-ការងារការពារ-ស្តារនីតិសម្បទាជនរងគ្រោះ**

ក្នុងឆ្នាំ២០១២កន្លងទៅនេះ ស្ត្រីរកស៊ីផ្លូវភេទតាមទីសាធារណៈត្រូវបានសមត្ថកិច្ចប្រមូល យកមកណែនាំ និងសង្គ្រោះស្ត្រីរងគ្រោះដោយអំពើជួញដូរផ្លូវភេទតាមផ្ទះបន សរុបបានចំនួន ៤៧០នាក់ ក្នុងនោះមាន (រាជធានីភ្នំពេញចំនួន៤៥០នាក់ ខេត្តបាត់ដំបងចំនួន១៥នាក់ និងខេត្ត បន្ទាយមានជ័យចំនួន០៥នាក់) សមត្ថកិច្ចបានប្រគល់ឱ្យមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា តាមបណ្តារាជធានី-ខេត្ត ធ្វើការអប់រំ និងផ្តល់ប្រឹក្សា ព្រមទាំងប្រគល់ឱ្យអង្គការដៃគូ ដើម្បីទទួលបានសេវាស្តារនីតិសម្បទាបន្ត និងមួយចំនួនបានអប់រំឱ្យត្រឡប់ទៅលំនៅដ្ឋានវិញ ។

- បើប្រៀបធៀបទៅនឹងឆ្នាំ២០១១ ចំនួនស្ត្រីដែលប្រមូលបានពីតាមទីសាធារណៈ និងសង្គ្រោះចេញពីផ្ទះបនមានចំនួន៤៧០លើ៤៤០នាក់ មានការកើនឡើងចំនួន ៣០នាក់ ។

**២.២-ការធ្វើសមាហរណកម្ម និងតាមដាន:**

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា បានតាមដានជនរងគ្រោះ និងងាយ រងគ្រោះដែលធ្វើសមាហរណកម្មទៅគ្រួសារ និងសហគមន៍ក្នុងរាជធានី-ខេត្តចំនួន០៨ (រាជធានី ភ្នំពេញ ខេត្តកំពង់ធំ សៀមរាប កំពង់ស្ពឺ ស្វាយរៀង ព្រៃវែង បាត់ដំបង និងខេត្តបន្ទាយមានជ័យ) មានចំនួន១៩៩នាក់ ក្នុងនោះមាន: *រងគ្រោះដោយការជួញដូរផ្លូវភេទ៦១នាក់ រំលោភបំពាន ៦៩នាក់ ជួញដូរពលកម្ម៦៩នាក់* ។

**២.៣-ការងារទទួលពលករពីអាជ្ញាធរបរទេស:**

**២.៣.១- តាមរយៈអាជ្ញាធរបរទេស:**

ក្នុងឆ្នាំ២០១២នេះ ការទទួលពលករទេសន្តរប្រវេសន៍ពីអាជ្ញាធរបរទេស បើប្រៀបធៀបទៅនឹងឆ្នាំ២០១១ មានចំនួន១២៣,៦០៦លើ១១៨,៧៨១នាក់ គឺកើនឡើងចំនួន៤,៨២៥នាក់ ។ ការបញ្ជូន

គឺមកតាមខេត្តជាប់ព្រំដែនចំនួន០៦គឺ (ខេត្តបន្ទាយមានជ័យ បាត់ដំបង ប៉ៃលិន កោះកុង ស្ទឹងត្រែង ខេត្តស្វាយរៀង) សរុបមានចំនួន**១២៣,៦០៦**នាក់ (ស្រី**៣៧,៣៨៧**នាក់) ក្នុងនោះមានកុមារ **១១,៥៦៧**នាក់ (កុមារី**៤,៥៥៤**នាក់) ក្នុងនោះទទួលបានពី:

- អាជ្ញាធរប្រទេសថៃសរុបចំនួន**១២៣,២៦១**នាក់ ស្រីចំនួន**៣៧,២៣៤**នាក់
  កុមារចំនួន**១១,៤០២**នាក់ កុមារីចំនួន**៤,៤៧២**នាក់
- អាជ្ញាធរប្រទេសវៀតណាមសរុបចំនួន**២៥៩**នាក់ ស្រីចំនួន**១៥២**នាក់
  កុមារចំនួន**១៦៥**នាក់ កុមារីចំនួន**៨២**នាក់
- អាជ្ញាធរប្រទេសឡាវសរុបចំនួន**៨៦**នាក់ ស្រីចំនួន**០១**នាក់ ។

**<u>តារាងច្រកទទួលពលករ:</u>**

| ច្រកទ្វារ | ចំនួនរួម | ស្រី | កុមារ | កុមារី |
|---|---|---|---|---|
| អន្តរជាតិប៉ោយប៉ែត (បន្ទាយមានជ័យ) | ១០៣,១១២ | ៣០,៥៤២ | ៩,៨៩២ | ៤,១២៧ |
| អន្តរជាតិដូង ភ្នំដី(គីឡូម៉ែត្រ១៣) អូរអន្លក់, អូររំដួល (បាត់ដំបង) | ១៩,៣០២ | ៦,៣៤២ | ១,៣៦៤ | ៣៣៨ |
| អន្តរជាតិព្រំ (ប៉ៃលិន) | ១៧៦ | ២២ | | |
| អន្តរជាតិចាំយាម (កោះកុង) | ៦៧១ | ៣២៨ | ១៤៦ | ០៧ |
| អន្តរជាតិត្រពាំងក្រៀល (ស្ទឹងត្រែង) | ៨៦ | ០១ | | |
| អន្តរជាតិបាវិត, បុសមន (ស្វាយរៀង) | ២៥៩ | ១៥២ | ១៦៥ | ៨២ |
| **សរុប** | **១២៣,៦០៦** | **៣៧,៣៨៧** | **១១,៥៦៧** | **៤,៥៥៤** |

ក្នុងចំនួនពលករទេសន្តរប្រវេសន៍ខាងលើ មានមនុស្សចំនួន**៥០,៨៣៦នាក់** ត្រូវបានអាជ្ញា ធរថៃឃាត់ខ្លួនលើសពីរយៈពេល**០១ខែ**មុននឹងបញ្ជូនមកកម្ពុជាវិញ ។ សមត្ថកិច្ចក៏បានធ្វើការ សម្ភាសន៍ពលករបានមួយចំនួន ហើយក្តាប់បានអត្តសញ្ញាណជនដែលសង្ស័យថាជា**មេខ្យល់ចំនួន១៧នាក់** (ស្រី ០៦នាក់) ដើម្បីជាមូលដ្ឋានស្វែងរក និងគ្រប់គ្រងជំនាញ ។ ឯទេសន្តរប្រវេសន៍ទាំងនោះត្រូវបានអប់រំ ណែនាំឲ្យវិលត្រឡប់ទៅលំនៅដ្ឋានវិញ និងប្រុងប្រយ័ត្នចំពោះល្បិចកលជនខិលខូច ។

ដោយឡែក ជនរងគ្រោះដែលក្រសួងការបរទេស បានសហការជាមួយអាជ្ញាធរប្រទេសគោលដៅផ្សេងៗ និងអង្គការដៃគូមួយចំនួនសង្គ្រោះ និងបញ្ជូនមកប្រទេសកម្ពុជាវិញមានចំនួនៈ

**២.៣.២-<u>តាមរយៈក្រសួងការបរទេស និងកិច្ចសហប្រតិបត្តិការអន្តរជាតិ:</u>**

- អគ្គស្នងការដ្ឋាននគរបាលជាតិ បានទទួលពលករតាមរយៈ ក្រសួងការបរទេស និងកិច្ចសហប្រតិបត្តិការអន្តរជាតិ ដោយមានការសហការជាមួយអង្គការ IOM, CLEC, ADHOC, CARAM ជួយសង្គ្រោះពលករខ្មែរដែលបញ្ជូនត្រឡប់វិញពីប្រទេសខុសៗគ្នា និងក្នុងស្ថានភាពខុសៗគ្នា និងដែលសង្ស័យថាអាចរងគ្រោះដោយអំពើជួញដូរមនុស្សតាមរូបភាពផ្សេងៗនៅក្រៅប្រទេស ចំនួន **<u>២៣៨នាក់ (ស្រី១១៣នាក់)</u>** ដូចខាងក្រោមៈ

  -ប្រទេសកូរ៉េខាងត្បូង ចំនួន០៨នាក់

-ប្រទេសម៉ាឡេស៊ី ចំនួន១៣៥នាក់
-ប្រទេសឥណ្ឌូនេស៊ី ចំនួន៣៦នាក់
-ប្រទេសម៉ៃក្រូនេស្យា ចំនួន០៧នាក់
-ប្រទេសសេនេហ្គាល់ ចំនួន០៩នាក់
-ប្រទេសម៉ូរីទីស ចំនួន០២នាក់
-ប្រទេសចិន ចំនួន១៩នាក់
-ប្រទេសហ្វីជី ចំនួន០៣នាក់
-ប្រទេសជប៉ុន ចំនួន០៨នាក់
-ប្រទេសអាហ្វ្រិកខាងត្បូង ចំនួន០៥នាក់
-ប្រទេសថៃ ចំនួន០៦នាក់ ។

ក្នុងចំណោមពលករដែលរាជរដ្ឋាភិបាល សហការជាមួយសង្គការដៃគូពាក់ព័ន្ធបានជួយអន្តរាគមន៍ និងសង្គ្រោះបានពីប្រទេសខាងលើ សមត្ថកិច្ចនៃអគ្គស្នងការដ្ឋាននគរបាលជាតិបានធ្វើការសម្ភាសន៍ដើម្បីកំណត់អត្តសញ្ញាណជនរងគ្រោះពិតប្រាកដ និងធ្វើសមាហរណកម្មទៅគ្រួសារវិញ ។ មិនតែប៉ុណ្ណោះសមត្ថកិច្ចយើង បានកំណត់រកឃើញមុខសញ្ញាជនដែលសង្ស័យថាជាមេខ្យល់ក្នុងករណីពាក់ព័ន្ធ បានចំនួន ២០នាក់ ក្នុងនោះមាន ០៨នាក់ ត្រូវបានកសាងសំណុំរឿងបញ្ជូនទៅតុលាការ និង១២នាក់ទៀត សមត្ថកិច្ចកំពុងតែកសាងសំណុំរឿងដើម្បីបញ្ជូនទៅតុលាការបន្តទៀត ។

ចំពោះក្រុមហ៊ុន Giant Ocean International Fishery ដែលជាប់ពាក់ព័ន្ធនឹងការបញ្ជូនពលករទៅធ្វើការលើកប៉ាល់នេសាទសមុទ្រខុសពីប្រកាសក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ត្រូវបានសមត្ថកិច្ចបញ្ជូនសំណុំរឿងទៅសាលាដំបូងរាជធានីភ្នំពេញរួចហើយ ។ ជាមួយគ្នានេះដែរ អង្គការ ជប៉ុន ដែលបានបញ្ជូនពលករទៅធ្វើកម្មសិក្សានៅប្រទេសជប៉ុន ខុសលក្ខន្តិកៈនៃការបណ្តុះបណ្តាល ក៏ត្រូវបានបញ្ជូនសំណុំរឿងទៅសាលាដំបូងរាជធានីផងដែរ ។

**២.៣.៣-<u>ការងារទទួលជនរងគ្រោះ និងងាយរងគ្រោះ</u>**

មណ្ឌលសំចតខេត្តបន្ទាយមានជ័យបានដកស្រ្តី និងកុមារ ចេញពីក្នុងចំណោមជនទេសន្តរប្រវេសន៍ ក្រោយពីការកំណត់អត្តសញ្ញាណថាជាជនរងគ្រោះនិងងាយរងគ្រោះបានចំនួន ២០៥នាក់ (ស្រី៥៩នាក់) ក្នុងនោះមានកុមារ១៦២នាក់ (កុមារី៣៧នាក់) ។ ជនរងគ្រោះនិងងាយរងគ្រោះទាំងអស់ខាងលើត្រូវបានប្រគល់ឱ្យអង្គការដៃគូ ដោយបាននិងកំពុងស្វែងរកគ្រួសារ ធ្វើការប៉ាន់ប្រមាណស្ថានភាព ដើម្បីធ្វើសមាហរណកម្មទៅគ្រួសារវិញ ។

➢ បើប្រៀបធៀបតួលេខឆ្នាំ២០១១ ***ជនរងគ្រោះ និងងាយរងគ្រោះដែលយើងកំណត់ បានមានចំនួន២០៥នាក់លើ១៦៥នាក់ ដូច្នេះមានការ<u>កើនឡើងចំនួន៤០នាក់</u>*** ។

**៣- <u>ការងារអនុវត្តន៏ច្បាប់:</u>**

**ក. <u>កិច្ចសហប្រតិបត្តិការបង្ក្រាបបទល្មើសៈ</u>**

○ ក្នុងឆ្នាំ២០១២កន្លងទៅ ធៀបទៅនឹងឆ្នាំ២០១១ **ការបង្ក្រាបបទល្មើសដែលពាក់ព័ន្ធនឹង អំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ មានចំនួន១៣៣លើ១៩៤ករណី គឺ <u>ថយចុះចំនួន៦១ករណី</u> ចាប់ខ្លួនសង្ស័យ១៦៥លើ២៥៥នាក់ <u>ថយចុះចំនួន៩០នាក់</u>** ក្នុងនោះមាន

ជនបរទេសចំនួន១២នាក់ (សញ្ជាតិបារាំង០៤នាក់ ស្វីស០១នាក់ អង់គ្លេស០២នាក់ ជប៉ុន ០១នាក់ អាល់ស៊េរី០១នាក់ ថៃ០១នាក់ ចិន០១នាក់ និងអូស្ត្រាលី០១នាក់) ។

- ក្នុងប្រតិបត្តិការបង្ក្រាបករណីខាងលើ សមត្ថកិច្ច**សង្គ្រោះជនរងគ្រោះបានចំនួន៤៥៨នាក់** (មានអាយុក្រោម១៥ឆ្នាំ៩៣នាក់ អាយុ១៥-១៧ឆ្នាំ៦១នាក់ និងអាយុ១៨ឆ្នាំឡើង៣០៤នាក់) ជនរងគ្រោះ ទាំងអស់បានប្រគល់ឱ្យមន្ទីរសង្គមកិច្ចចំនួន១៨៩នាក់ អង្គការមិនមែនរដ្ឋាភិបាលចំនួន១៣នាក់ និងចំនួន២៥៦នាក់ទៀតប្រគល់ឱ្យគ្រួសារវិញ។
- ចំពោះបទល្មើសជួញដូរមនុស្ស សមត្ថកិច្ចបានធ្វើការស្រាវជ្រាវស៊ើបអង្កេត**មេខ្យល់** និងបណ្តាញជួញដូរមនុស្សចំនួន**៥២**នាក់ ឈានទៅបង្ក្រាបបានចំនួន**១៩ករណី** ចាប់ខ្លួន**១៨នាក់** និងកំពុងស្រាវជ្រាវរកអត្តសញ្ញាណមុខសញ្ញាជនសង្ស័យដែលកំពុង ធ្វើសកម្មភាពបោកបញ្ឆោត ពលរដ្ឋយកទៅលក់ដូរកម្លាំងពលកម្ម ឬ ធ្វើអាជីវកម្មផ្លូវភេទចំនួន **៣៦នាក់ទៀត** ។

➢ ***ក្នុងចំនួន១៣៣ករណីជនសង្ស័យ១៦៥នាក់(ស្រី៤៣នាក់) ដែលសមត្ថកិច្ចយើងបង្ក្រាបមាន:***

១-អំពើជួញដូរមនុស្សចំនួន៥៣ករណី ជនជាប់សង្ស័យចំនួន៧៥នាក់ (ស្រី១៨នាក់) ជនរងគ្រោះចំនួនជនរងគ្រោះ២៧៨នាក់ ។

២-អំពើធ្វើអាជីវកម្មផ្លូវភេទចំនួន៨០ករណី ជនជាប់សង្ស័យចំនួន៩០នាក់(ស្រី២៩នាក់) ជនរងគ្រោះចំនួនជនរងគ្រោះ២៧៨នាក់ ។

តារាងលទ្ធផលកិច្ចប្រតិបត្តិការបង្ក្រាបបទល្មើស និងសង្គ្រោះជនរងគ្រោះ

| បទល្មើស | ចំនួនករណី | ចំនួនជនសង្ស័យ | ចំនួនជនរងគ្រោះ | | | បញ្ជូនជនរងគ្រោះ | | |
|---|---|---|---|---|---|---|---|---|
| | | | ក្រោម១៥ឆ្នាំ | ១៥-១៧ឆ្នាំ | ១៨ឆ្នាំឡើង | មន្ទីរសង្គមកិច្ច | អង្គការ | គ្រួសារ |
| ជួញដូរមនុស្ស | ៥៣ករណី | ៧៥នាក់ | ២៦នាក់ | ៤៥នាក់ | ២០៧នាក់ | ១០០នាក់ | ១០នាក់ | ១៦៨នាក់ |
| អាជីវកម្មភេទ | ៨០ករណី | ៩០នាក់ | ៦៧នាក់ | ១៦នាក់ | ៩៧នាក់ | ៨៩នាក់ | ០៣នាក់ | ៨៨នាក់ |
| សរុប | ១៣៣ករណី | ១៦៥នាក់ | ៤៥៨នាក់ | | | ៤៥៨នាក់ | | |

## ៤- **ការងារកិច្ចការយុត្តិធម៌:**

នៅក្នុងឆ្នាំ២០១២ កន្លងទៅនេះ តាមទិន្នន័យដែលទទួលបាន [1] បានបង្ហាញថា សាលាដំបូងរាជធានី-ខេត្តទាំងអស់ បានធ្វើចំណាត់ការលើសំណុំរឿងបទល្មើសជួញដូរមនុស្ស ក្រោមច្បាប់ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ គិតពីថ្ងៃទី០១ ខែមករា ឆ្នាំ២០១២ ដល់ ថ្ងៃទី១៥ខែវិច្ឆិកា ឆ្នាំ២០១២ មានដូចខាងក្រោម៖

តារាងទិន្នន័យសំណុំរឿងក្តី ជួញដូរមនុស្ស និងអាជីវកម្មផ្លូវភេទក្នុងឆ្នាំ២០១២

[1] ទិន្នន័យទទួលបានពី ឯកឧត្តម ជីវ កេង ប្រធានសាលាដំបូងរាជធានីភ្នំពេញ និងជាប្រធានអង្គភាពអធិការកិច្ចនៃក្រុមប្រឹក្សាវិន័យ ឯកឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម

| សល់ពីឆ្នាំចាស់ | ចូលថ្មីក្នុងឆ្នាំ២០១២ | ជម្រះរួច | កំពុងចាត់ការ |
|---|---|---|---|
| ៥៦ សំណុំរឿង | ២៥៥ សំណុំរឿង | ២២៧ សំណុំរឿង | ៨៤ សំណុំរឿង |
| សរុបសំណុំរឿងក្តីបទល្មើសជួញដូរ ៣១១សំណុំរឿង | | សរុបសំណុំរឿងបានធ្វើចំណាត់ការ៣១១សំណុំរឿង | |

ករណីសំណុំរឿងខាងលើ សាលាដំបូងរាជធានី ខេត្ត បានធ្វើចំណាត់ការជម្រះរួចហើយ លើករណីជួញដូរមនុស្ស និងករណីអាជីវកម្មផ្លូវភេទ ជាលទ្ធផលគឺ៖

តារាងលទ្ធផលចំណាត់ការរបស់សាលាដំបូងរាជធានី-ខេត្ត ក្នុងឆ្នាំ ២០១២

| ជនល្មើស | | | | | ជនរងគ្រោះ |
|---|---|---|---|---|---|
| ត្រូវឃុំខ្លួន | មិនមានខ្លួន ឬនៅក្រៅឃុំ | ជាជនបរទេស | ត្រូវបាន ផ្តន្ទាទោស | ឲ្យរួចពី បទចោទ | ៣៧៨នាក់ |
| ២៨៩នាក់ | ១៣៨នាក់ | ១៣នាក់ | ៣០០នាក់ | ៤០នាក់ | |

## ៤- ការងារសហប្រតិបត្តិការអន្តរជាតិ

ក្នុងឆ្នាំ២០១២ កន្លងទៅនេះ យើងបានទៅចូលរួមកិច្ចប្រជុំ និងបំពេញកិច្ចសហប្រតិបត្តិ ការលើការងារផ្សេងៗតាមការអញ្ជើញនៃបណ្តាប្រទេសមួយចំនួន សរុប ៤៣លើក ក្នុងនោះមាន៖

លេខាធិការដ្ឋានគណៈកម្មាធិការជាតិប.ជ.រ.ព.ភ៖០៣លើក ក្រុមការងារCOMMITកម្ពុជា សហការជាមួយក្រុមការងារសហប្រតិបត្តិការអន្តរជាតិ នៃលេខាធិការដ្ឋានគណៈកម្មាធិការជាតិ ប.ជ.រ.ព.ភ ០៥លើក ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ០៥លើក ក្រសួងកិច្ចការនារី០២លើក ក្រសួងយុត្តិធម៌០១លើក ក្រសួងមហាផ្ទៃ០៩លើក ក្រសួងអប់រំយុវជននិងកីឡា ០៣លើក (ទស្សនកិច្ចសិក្សា) ក្រសួងទេសចរណ៍០១លើក ក្រុមការងារសហប្រតិបត្តិការអន្តរជាតិ០១លើក ខេត្តបន្ទាយមានជ័យ០៥លើក ខេត្តស្វាយរៀង០៤លើក ខេត្តបាត់ដំបង០១លើក ខេត្តកណ្តាល០១លើក ខេត្តព្រះវិហារ០១លើក និងខេត្តកោះកុង០១លើក ។

តារាងសកម្មភាពមានដូចខាងក្រោម ៖

| ក្រសួង-ស្ថាប័ន | សកម្មភាពសហប្រតិបត្តិការ | ទីកន្លែង |
|---|---|---|
| លេខាធិការដ្ឋាននៃ គ.ជ/ប.ជ.រ.ព.ភ៖ ០៣លើក | ១.ដឹកនាំប្រតិភូអន្តរក្រសួង ធ្វើទស្សនកិច្ចសិក្សា នៅប្រទេសម៉ាលេស៊ី៖ ០១លើក។ | កូឡាលំពួរ. ម៉ាឡេស៊ី |
| | ២.ចូលរួមធ្វើបទបង្ហាញស្តីពី ទស្សនទានជាសាកលស្តីពីការលុបបំបាត់ការជួញដូរ និងហិង្សាផ្លូវភេទលើ កុមារ៖ ០១លើក។ | ទីក្រុងរ៉ូម. អ៊ីតាលី |
| | ៣.ជួបពិភាក្សាការងារជាមួយអធិការបតី និងទីប្រឹក្សាជាន់ខ្ពស់ លោកប្រធានាធិបតី អូបាម៉ា សហរដ្ឋអាមេរិក ៖ ០១លើក | ក្នុងស្ថានទូតអាមេរិក រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា |
| -ក្រុមការងារ COMMIT កម្ពុជា និងលេខាធិការ | -ប្រជុំគណៈកម្មាធិការកណ្តាល COMMIT ដើម្បី ពិភាក្សាវាយតម្លៃការងារ និងអនុសាសន៍នានា។ | បាងកក. ប្រទេសថៃ(០២លើក) |

| | | |
|---|---|---|
| ដ្ឋាន គ.ជ/ប.ជ.រ.ព.ភ (ក្រុមការងារសហប្រតិបត្តិការអន្តរជាតិ) (០៥លើក) | -ដឹកនាំគណៈប្រតិភូអន្តរក្រសួង និងអង្គការពាក់ព័ន្ធ ដើម្បីប្រជុំពិនិត្យ កែសម្រួល អនុស្សរណៈនៃការយោគយល់គ្នា ជាមួយព្រះរាជាណាចក្រថៃ ស្តីពីកិច្ចសហការទ្វេភាគីក្នុង ការលុបបំបាត់អំពើជួញដូរ និងការជួយសង្គ្រោះជនរងគ្រោះ ដោយសារអំពើជួញដូរមនុស្ស ។<br>-បានដឹកនាំគណៈប្រតិភូអន្តរក្រសួង និងអង្គការ ដៃគូទៅចូលរួមក្នុងពិធីចុះហត្ថលេខាលើការកែ សម្រួលកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលកម្ពុជា និងរដ្ឋាភិបាលនៃសាធារណរដ្ឋសង្គមនិយមវៀត ណាម ស្តីពីកិច្ចសហប្រតិបត្តិការទ្វេភាគី ដើម្បី លុបបំបាត់អំពើជួញដូរមនុស្ស<br>- ចូលរួមប្រជុំមន្ត្រីមន្ត្រីជាន់ខ្ពស់ COMMIT កម្ពុជា លើកទី៨ និងកិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីលើក៣ក្រោម ប្រធានបទ«**ការរួមគ្នា និងកិច្ចសហការប្រកប ដោយនីរន្តរភាព**»<br>- ដឹកនាំកិច្ចពិភាក្សាទ្វេភាគីជាមួយប្រតិភូនៃរដ្ឋាភិបាលម៉ាលេស៊ី លើសេចក្តីព្រាងអនុស្សរណៈទ្វេភាគី កម្ពុជា-ម៉ាលេស៊ី ស្តីពីកិច្ចសហប្រតិបត្តិការប្រឆាំងការជួញដូរមនុស្ស | ក្រុងហូជីមិញ. វៀតណាម<br><br>-ទីក្រុងហាណូយ វៀតណាម<br><br>រាជធានីភ្នំពេញ. ព្រះរាជាណាចក្រកម្ពុជា |
| -ក្រសួងកិច្ចការនារី (០២លើក) | -ចូលរួមសិក្ខាសាលាលើកទី៣ ស្តីពីដំណោះ ស្រាយក្រុមការងារចម្រុះក្នុងកិច្ចការពារជនរង គ្រោះដោយអំពើជួញដូរមនុស្ស និងការចែក រំលែកបទពិសោធន៍ជាមួយប្រទេសក្នុងតំបន់ ។<br>-ចូលរួមសិក្ខាសាលា ស្តីពីការលើកកម្ពស់សមត្ថ-ភាពកិច្ចសហប្រតិបត្តិការប្រឆាំងការជួញដូរ មនុស្សរវាងប្រទេសក្នុងទ្វីបអាស៊ី ។ | -ខេត្ត Nakhonnayok . ប្រទេស ថៃ ។<br><br>-ប្រទេសជប៉ុន |
| -ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ (០៥លើក) | - សហការជាមួយ អង្គការ UN Women ក្រសួងមហាផ្ទៃ ក្រសួងកិច្ចការនារីរៀបចំសន្និសីទថ្នាក់តំបន់ស្តីពីឧបករណ៍សិទ្ធិមនុស្សរបស់ពលករទេសន្តរប្រវេសន៍ជាស្ត្រី<br>- រៀបចំវេទិកាអាស៊ាន ស្តីពីពលករទេសន្តរប្រវេសន៍ លើកទី៥<br>- ចូលរួមកិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីលើកទី៥ ស្តីពីការអនុវត្តអនុស្សរណៈនៃការយោគយល់គ្នា អំពីកិច្ចសហប្រតិបត្តិការ លើការប្រើប្រាស់កម្លាំងពលកម្ម<br>- ចូលរួមកិច្ចប្រជុំក្រុមការងារបច្ចេកទេស កម្ពុជា ថៃ ដើម្បីពិភាក្សា ស្តីពី ការកំណត់អត្តសញ្ញាណ និងផ្តល់លិខិតសម្គាល់ខ្លួនដល់ ពលករខ្មែរនៅប្រទេសថៃ -ការ | នៅរាជធានីភ្នំពេញ (៤-៥កញ្ញា ២០១២)<br><br>នៅទីក្រុងសៀមរាប អង្គរ<br><br>នៅទីក្រុងបាងកក (២៦ មករា ២០១២)<br><br>(០៧ ធ្នូ ២០១២) |

| | | |
|---|---|---|
| | ពន្លឿនការបញ្ជូនពលករខ្មែរតាមរយៈ ទីភ្នាក់ងារ ជ្រើសរើសឯកជន - ការងារប្រចាំថ្ងៃព្រឹកវិលល្ងាច និងតាមរដូវកាល<br>- ចូលរួមកិច្ចប្រជុំគណៈកម្មការចម្រុះលើកទី៨ ស្តីពីកិច្ចសហប្រតិបត្តិការទ្វេភាគី កម្ពុជា-ថៃ និងក្នុងការអនុវត្ត MoU ស្តីពីការប្រើប្រាស់កម្លាំងពលកម្ម | ទីក្រុងបាងកក (២៥-២៦ ធ្នូ ២០១២) |
| -ក្រសួងយុត្តិធម៌ (០១លើក) | -ដឹកនាំសម្របសម្រួលធ្វើសិក្ខាសាលារួមគ្នាស្តីពី កិច្ចសហប្រតិបត្តិការអន្តរជាតិ ករណីជួញដូរ មនុស្សក្នុងវិស័យយុត្តិធម៌ព្រហ្មទណ្ឌ ដែលមាន ការចូលរួមពីប្រទេសនៃមហាអនុតំបន់មេគង្គ កម្ពុជា ឡាវ ភូមា និងថៃ ។ | រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា |
| -ក្រសួងមហាផ្ទៃ (០៩លើក) | - នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការ ពារអនីតិជនចូលរួមក្នុងវគ្គបណ្តុះបណ្តាល និងសិក្ខា សាលាស្តីពី:<br>• កិច្ចការពារអំពើរត់ពន្ធជនទេសន្តរប្រវេសន៍ ការធ្វើទេសន្តរប្រវេសន៍ខុសច្បាប់ នៅអាស៊ីអាគ្នេយ៍ និងកិច្ចការពារអនីតិជនរងគ្រោះពីការជួញដូរមនុស្ស។ | ប្រទេសម៉ាឡេស៊ី (០២លើក) |
| | • កិច្ចសហប្រតិបត្តិការបង្ការទប់-ស្កាត់ បទល្មើសឆ្លងកាត់ព្រំដែនកម្ពុជា-វៀតណាម ។<br>• ចូលរួមបណ្តុះបណ្តាលការកំណត់ អត្តសញ្ញាណជនរងគ្រោះ និងកិច្ចសហប្រតិបត្តិការ អនុវត្តនីតិវិធីច្បាប់ ។<br>• កិច្ចសហការអនុវត្តនីតិច្បាប់ប្រឆាំងការធ្វើអាជីវកម្មផ្លូវភេទលើកុមារក្នុងវិស័យទេសចរណ៍ ។<br>• លើកម្ពស់ការផ្សារភ្ជាប់រវាងប្រទេសក្នុងទ្វីបអាស៊ីលើការងារប្រឆាំងការជួញដូរមនុស្ស។ | ប្រទេសវៀតណាម (០៣លើក) ។ |
| | • ការពង្រឹងសមត្ថភាពសហគមន៍អ្នកអនុវត្ត និងអ្នករៀបចំគោលនយោបាយ ឆ្លើយតបនឹងអំពើហឹង្សាប្រឆាំងនឹងស្ត្រី ។<br>• បណ្តុះបណ្តាលជំនាញ ប្រឆាំងនឹងបទល្មើសតាមប្រព័ន្ធកុំព្យូទ័រ ។ | ប្រទេសជប៉ុន(០២ លើក) |
| | • ការបង្កើតទំនាក់ទំនងក្នុងចំណោមបណ្តាប្រទេសអាស៊ានលើការជួញដូរមនុស្ស ។ | ប្រទេសហ្វីលីពីន(០១ លើក) |
| | • ការក្លែងឯកសារ និងការប្រឆាំងអំពើជួញដូរមនុស្សឆ្នាំ២០១២ ។ | ប្រទេសថៃ(០១លើក) |
| ក្រសួងអប់រំ យុវជន និងកីឡា | • ទស្សនកិច្ចសិក្សាដកពិសោធន៍លើការងារទប់ស្កាត់អំពើហិង្សាលើកុមារ (០៣លើក) | ប្រទេសម៉ាលេស៊ី<br>ប្រទេសអូស្ត្រាលោះ<br>ប្រទេសតង់ហ្សានី |

| | | |
|---|---|---|
| ក្រសួងទេសចរណ៍ | • ចូលរួមប្រជុំថ្នាក់តំបន់ (កម្ពុជា វៀតណាម ឡាវ ថៃ) ស្តីពី ការរៀបចំ និងដំណើរការរបស់គណៈកម្មាធិការសម្របសម្រួលគម្រោងកុមារភាព ។ | ទីក្រុងបាងកក ប្រទេសថៃ |
| -ខេត្តស្វាយរៀង | • ប្រជុំជាមួយភាគីវៀតណាមបង្កើនកិច្ច សហប្រតិបត្តិការការពារសន្តិសុខ សណ្តាប់ធ្នាប់តាមព្រំដែន ។<br>• សហការជាមួយអង្គការ CCPCR ទៅធ្វើទស្សនៈកិច្ចសិក្សាលើបញ្ហាឆ្លងដែនទៅសុំទាន និងរៀបចំផែនការធ្វើមាតុភូមិនិវត្តន៍ ។<br>• ប្រជុំជាមួយអាជ្ញាធរខេត្តឡុងអាន ស្តីពី កិច្ចសហប្រតិបត្តិការបង្ការ-ទប់ស្កាត់បទល្មើស ជួញដូរមនុស្សឆ្លងកាត់ព្រំដែនប្រទេសទាំងពីរ ។<br>• ប្រជុំជាមួយភាគីវៀតណាម ស្តីពីការងារប្រឆាំងការជួញដូរមនុស្ស និងកិច្ចការពារជនរងគ្រោះ និងចុះហត្ថលេខាបន្ថែមលើកិច្ចព្រមព្រៀង នៃកិច្ចសហប្រតិបត្តិការជាមួយគ្នា ។ | ទីបញ្ជាការកងទ័ពការពារព្រំដែន ប្រទេសវៀតណាម<br>-ខេត្តតៃនិញ ប្រទេសវៀត ណាម<br>-ខេត្តឡុងអាន ប្រទេស វៀតណាម<br>-ក្រុងហូជីមិញ ប្រទេសវៀត ណាម |
| -ខេត្តកណ្តាល | • ប្រជុំជាមួយភាគីវៀតណាម បូកសរុបការងារ សហប្រតិបត្តិការបង្ការ-ទប់ស្កាត់ ប្រឆាំងការ ជួញដូរស្ត្រី និងកុមាររួមគ្នារវាងខេត្តបី (កណ្តាល តាកែវ និងខេត្តអាងយ៉ាង) ។ | -ខេត្តអាងយ៉ាង ប្រទេស វៀតណាម |
| -ខេត្តបន្ទាយមានជ័យ | • ប្រជុំជាមួយអង្គការ UNIAPប្រចាំនៅប្រទេសថៃ អង្គការទស្សនៈពិភពលោក អយ្យការប្រចាំទីក្រុងបាងកក និងនគរបាលជំនាញ (កម្ពុជា ថៃ ភូមា និងប្រទេសឡាវ) ពិគ្រោះយោបល់ក្នុងការជួយ សង្គ្រោះជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដែលមាននៅក្នុងប្រទេសថៃ<br>• សហការជាមួយអង្គការសម្ព័ន្ធ BigC និងអង្គការសង្គមស៊ីវិលមួយចំនួន ប្រជុំជាមួយតំណាង អាជ្ញាធរខេត្តស្រះកែវ ដើម្បីរកវិធានការដោះស្រាយបញ្ហាពាក់ព័ន្ធនឹងអំពើជួញដូរមនុស្ស ។<br>• ពិភាក្សាជាមួយអាជ្ញាធរខេត្តស្រះកែវ រកវិធានការទប់ស្កាត់ និងគ្រប់គ្រងពលករកម្ពុជាដែល ចូលទៅធ្វើពលកម្មនៅប្រទេសថៃ ។<br>• ប្រជុំមួយភាគីថៃ ពិនិត្យលើអនុស្សរៈនៃការយោគយល់គ្នា ក្នុងការលុបបំបាត់អំពើជួញដូរមនុស្ស ។<br>• ពិភាក្សាលើករណីពិសេស របស់កុមារីអាយុ ៣ឆ្នាំម្នាក់ | -ប្រទេសថៃ<br>-ស្រះកែវ ប្រទេសថៃ<br>-បាងកក/ប្រទេសថៃ (០២លើក) ។ |

| | | |
|---|---|---|
| | ដែលរងគ្រោះដោយសារម្តាយបង្ខំ ឲ្យដើរសុំទាននៅក្នុងប្រទេសថៃ ។ | |
| -ខេត្តបាត់ដំបង | • ពិភាក្សាជាមួយអាជ្ញាធរខេត្តច័ន្ទបូរី ស្វែងរក វិធានការការពារ ទប់ស្កាត់ និងគ្រប់គ្រងពលករ កម្ពុជាទៅធ្វើការនៅប្រទេសថៃ ។ | -ខេត្តច័ន្ទបូរី ប្រទេសថៃ |
| -ខេត្តព្រះវិហារ | • ចូលរួមកិច្ចប្រជុំ ជាមួយអាជ្ញាធរប្រទេស ឡាវ ស្តីពីកិច្ចសហប្រតិបត្តិការតាមបណ្តោយព្រំ ដែន ដើម្បីទប់ស្កាត់ និងបង្ក្រាបបទល្មើសជួញដូរ មនុស្ស ។ | -ប្រទេសឡាវ |
| -ខេត្តកោះកុង | • ចូលរួមសិក្ខាសាលាជាមួយអាជ្ញាធរប្រទេសថៃ ដើម្បីបូកសរុប និងដកពិសោធន៍លើការងារ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ។ | -ប្រទេសថៃ |

<u>កិច្ចសហប្រតិបត្តការក្នុងក្របខ័ណ្ឌអាស៊ាន</u>

ដោយឡែក ក្នុងក្របខ័ណ្ឌអាស៊ាន ព្រះរាជាណាចក្រកម្ពុជាបានចូលរួមសកម្មភាពជាច្រើនក្នុងការប្រឆាំងបទល្មើសឆ្លងដែន ។

នៅក្នុងក្របខ័ណ្ឌអាស៊ាន SOMTC-កម្ពុជា មានភារកិច្ចឃ្លាំមើល វិភាគពត៌មាន លើកមតិយោបល់អំពីឧក្រិដ្ឋកម្មឆ្លងដែន ជូនអង្គប្រជុំថ្នាក់រដ្ឋមន្ត្រីអាស៊ាន (AMMTC) សំរេច និងណែនាំ។ឧក្រិដ្ឋកម្មឆ្លងដែនមាន: អំពើភេរវកម្ម ជួញដូរមនុស្ស ជួញដូរគ្រឿងញៀន រត់ពន្ធអាវុធ លាងលុយកខ្វក់ ប្លន់តាមលំហសមុទ្រ ឧក្រិដ្ឋកម្មសេដ្ឋកិច្ច និង ឧក្រិដ្ឋកម្មបច្ចេកវិទ្យា ។

ចំពោះការប្រឆាំងការជួញដូរមនុស្ស ក្នុងក្រប ខ័ណ្ឌ អាស៊ាន នាពេលបច្ចុប្បន្ន ប្រទេសហ្វីលីពីនជាប្រទេសនាំមុខ ។ ប្រទេសសមាជិកអាស៊ានឯទៀតរួមជាមួយកម្ពុជា ទទួលស្គាល់ការជួញដូរ មនុស្សជាបញ្ហាចំបងមួយ សំរាប់ជាតិ តំបន់ និងអន្តរជាតិ ។ ការជួញដូរមនុស្សជាពិសេសស្ត្រី និងកុមារដោយក្រុមឧក្រិដ្ឋកម្មមានការចាត់តាំង កំពុងរីកសាយ ហើយកំពុងបង្កឲ្យមានផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់សន្តិសុខជាតិ និងការអភិវឌ្ឍន៍មនុស្ស ព្រមទាំងធ្វើឲ្យនីតិវិធីផ្នែកច្បាប់ទន់ខ្សោយ ហើយគំរាមកំហែងដល់សុវត្ថិភាពសាធារណៈផង ។

ជាដំណោះស្រាយ សមាជិកអាស៊ានទាំងអស់ចាំបាច់បង្កើតសហប្រតិបត្តិការតំបន់ សំរាប់អនុវត្តន៍ក្របខ័ណ្ឌសាកលដែលមានស្រាប់ ក្នុងការទប់ស្កាត់ការជួញដូរមនុស្ស ព្រមទាំងការពារជនរងគ្រោះផង ។ ក្នុងន័យនេះ ការតាក់តែងសន្ធិសញ្ញាអាស៊ាន រួមជាមួយផែនការសកម្មភាពស្តីពីការជួញដូរមនុស្ស កំពុងប្រព្រឹត្តទៅតាមសេចក្តីសំរេចរបស់ SOMTC ទី១២ នៅទីក្រុងបាងកក ប្រទេសថៃដែលបានកំណត់ឲ្យប្រទេសហ្វីលីពីនជាប្រទេសនាំមុខ កោះប្រជុំក្រុមការងារជំនាញចំនួន ពីរលើកនៅឆ្នាំ២០១៣ សំរេចឲ្យបានតាមគោលការណ៍កំណត់ ដើម្បីបញ្ជូនឲ្យ AMMTC ណែនាំនៅប្រទេសឡាវ នៅឆ្នាំ ២០១៣ នេះ ហើយនឹងត្រូវអនុម័តដោយសន្និសីទកំពូលអាស៊ាននៅប្រទេសប្រ៊ុយណេនៅឆ្នាំដដែល ។

NATIONAL COMMITTEE TO LEAD S.T.S.L.S

ក្រសួងមហាផ្ទៃ និងUNODC បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងនៅថ្ងៃទី ៨ ខែ មេសា ឆ្នាំ ២០១០ ដើម្បីប្រយុទ្ធប្រឆាំងការរត់ពន្ធជនទេសន្តរប្រវេសន៍ និងបានបង្កើត ក្រុមការងារកម្ពុជាមួយដើម្បីធ្វើការងារនេះ ។ បន្ទាប់មក ក្រុមការងារកម្ពុជានិងតំណាង UNODC បានចូលរួមប្រជុំចំនួន ៣ លើក ដើម្បីតាក់តែងផែនការសកម្មភាព អនុវត្តកិច្ចព្រមព្រៀង ។ នៅឆ្នាំ២០១១ សិក្ខាសាលា ស្តីពីការយល់ដឹងអំពីការរត់ពន្ធជនទេសន្តរប្រវេសន៍ ត្រូវបានរៀបចំឡើង និងលើកភស្តុតាងអំពីការគ្រប់គ្រងជាន់ខ្ពស់ផ្នែកសហប្រតិបត្តិការ និងវិភាគយុទ្ធសាស្ត្រ និងស៊ើបអង្កេតការរត់ពន្ធជនទេសន្តរប្រវេសន៍ ។

ក្នុងឆ្នាំ ២០១២ ពីខែកញ្ញា ដល់ ខែវិច្ឆិកា មានវគ្គបណ្តុះបណ្តាលចំនួន ៤ វគ្គ ៖

វគ្គទី១៖ បញ្ចូលទិន្នន័យរត់ពន្ធទេសន្តប្រវេសន៍ ទៅក្នុងប្រព័ន្ធរបាយការណ៍ស្ម័គ្រចិត្ត ស្តីពីការរត់ពន្ធជនទេសន្តរប្រវេសន៍ និង ដំណើរការពាក់ព័ន្ធ ( Volontary Reporting System on Migrant Smuggling and Conduct Related (VRS-MSCR) នៅកម្ពុជា ។

វគ្គទី២៖ ស្រូបយកបទពិសោធន៍បន្ថែមអំពីប្រព័ន្ធ VRS- MSCR នៅប្រទេសថៃ ។

វគ្គទី៣៖ រៀននីតិវិធីធ្វើរបាយការណ៍ (នៅប្រទេសថៃ)

វគ្គទី៤៖ កិច្ចការវិភាគនិងប្រតិបត្តិការ(នៅកម្ពុជា) ។

នៅឆ្នាំ ២០១៣ ខាងមុខនេះ ក្រសួងមហាផ្ទៃ និង UNODC នឹងបើកអង្គពិគ្រោះយោបល់ និងទិសដៅទៅអនាគត ក្រោមអធិបតីភាព ឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ប្រធានគណៈកម្មាធិការជាតិ ប.ជ.រ.ព.ភ ។

តារាងសកម្មភាពរបស់ក្រុមការងារ អាស៊ាន ប្រឆាំងឧក្រិដ្ឋកម្មឆ្លងដែន ក្នុងឆ្នាំ២០១២

| ស្ថាប័ន | សកម្មភាពក្នុងសហគមន៍អាស៊ាន ប្រឆាំងបទល្មើសឆ្លងដែន | ផ្សេងៗ |
|---|---|---|
| ក្រសួងមហាផ្ទៃ: SOMTC-Cambodia នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន | • នៅក្នុងក្របខ័ណ្ឌអាស៊ាន SOMTC-Cambodia អនុវត្តភារកិច្ចឃ្លាំមើល វិភាគពត៌មាន លើកមតិយោបល់ អំពីឧក្រិដ្ឋកម្មឆ្លងដែន ជូន អង្គប្រជុំថ្នាក់រដ្ឋមន្ត្រីអាស៊ាន (AMMTC) សំរេច និងណែនាំ។<br>• ចូលរួមកិច្ចប្រជុំឧត្តមមន្ត្រីទទួលបន្ទុក ការប្រឆាំងឧក្រិដ្ឋកម្មឆ្លងដែន (Senior Official Meeting on Transnational Crime (SOMTC) ដែលប្រព្រឹត្តទៅក្នុងមួយឆ្នាំ និងកិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រី(AMMTC) ប្រព្រឹត្តទៅពីរឆ្នាំម្តង។<br>• ចូលរួមការតាក់តែងសន្ធិសញ្ញាអាស៊ាន រួមជាមួយផែនការសកម្មភាពស្តីពីការជួញដូរមនុស្ស | SOMTC-Cambodia និងមន្ត្រីជំនាញនៃនាយកដ្ឋានប្រឆាំងការ ជួញដូរមនុស្ស និងការពារអនីតិជន សហការចូលរួមយ៉ាងសកម្មចំនួន ៤ ឆ្នាំ តាក់តែងសន្ធិសញ្ញា និងផែនការសកម្មភាព។ |
| ក្រសួងមហាផ្ទៃ: និង UNODC បានចុះហត្ថលេខា លើកិច្ចព្រមព្រៀង នៅថ្ងៃទី ៨ ខែ | បើកវគ្គបណ្តុះបណ្តាល ចំនួន ៤ វគ្គ ៖<br>វគ្គទី១៖ ស្តីពីបញ្ចូលទិន្នន័យរត់ពន្ធទេសន្តប្រវេសន៍ ទៅក្នុងប្រព័ន្ធរបាយការណ៍ស្ម័គ្រចិត្ត ស្តីពីការរត់ពន្ធជនទេសន្តរប្រវេសន៍ និង ដំណើរការពាក់ព័ន្ធ ( Volontary Reporting System on | មន្ត្រីនគរបាលមកពីនាយកដ្ឋានអន្តោប្រវេសន្តន៍ ប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន, កិច្ចការបរទេស, ព្រំដែនគោក និង |

| | | |
|---|---|---|
| មេសា ឆ្នាំ ២០១០ ដើម្បីប្រយុទ្ធប្រឆាំងការរត់ពន្ធជនទេសន្តរប្រវេសន៍ | Migrant Smuggling and Conduct Related (VRS-MSCR) នៅកម្ពុជា ។<br>វគ្គទី២៖ រៀនសូត្របទពិសោធន៍បន្ថែមអំពីប្រព័ន្ធ VRS- MSCR នៅប្រទេសថៃ ។<br>វគ្គទី៣៖ រៀននីតិវិធីធ្វើរបាយការណ៍ (នៅប្រទេសថៃ)<br>វគ្គទី៤៖ កិច្ចការវិភាគនិងប្រតិបត្តិការ(នៅកម្ពុជា) | ប្រឆាំងភេរវកម្ម ។ |

៦- <u>ការងារកិច្ចការកុមារ</u>

ក្នុងឆ្នាំ២០១២កន្លងទៅនេះ ក្នុងកិច្ចការពារកុមារ យើងបានបំពេញកិច្ចសហប្រតិបត្តិការលើការងារអាទិភាពមួយចំនួនឆ្លើយតបទៅនឹងអនុសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិកុមារដែលមានលទ្ធផល សកម្មភាពមានដូចខាងក្រោម ៖

- <u>ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា:</u>
  - រៀបចំកិច្ចប្រជុំ ស្តីពីការផ្តល់សុពលភាពទៅលើការកែសម្រួលឯកសារ ស្តីពីប្រព័ន្ធត្រួតពិនិត្យតាមដានពលកម្មកុមារនៅប្រទេសកម្ពុជា ។
  - រៀបចំកិច្ចប្រជុំចំនួន០២លើក ស្តីពីការពិនិត្យលើផែនការសកម្មភាពដំណាក់កាលទី២ ក្នុងការលុបបំបាត់ទម្រង់ធ្ងន់ធ្ងរ នៃពលកម្មកុមារឆ្នាំ២០១៣-២០១៧ ។
- <u>ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ:</u>
  - ធ្វើសេចក្តីព្រាងឯកសារទស្សនទាន ក្នុងការផ្តួចផ្តើមរៀបចំសិក្សាស្រាវជ្រាវ ស្តីពីទេសចរណ៍ផ្លូវភេទលើកុមារ ។
  - ធ្វើសិក្ខាសាលាពិគ្រោះយោបល់ ស្តីពី **ក្របខណ្ឌច្បាប់ពាក់ព័ន្ធនឹងការប្រឆាំងទេសចរណ៍ផ្លូវភេទលើកុមារ** ។
  - សហការជាមួយអង្គការUNODC សិក្សាស្រាវជ្រាវ ស្តីពី **ទេសចរណ៍ផ្លូវភេទលើកុមារនៅកម្ពុជា** និងរៀបចំសិក្ខាសាលាថ្នាក់ខេត្ត ស្តីពីក្របខ័ណ្ឌច្បាប់ពាក់ព័ន្ធនឹងការប្រឆាំងទេសចរណ៍ ផ្លូវភេទលើកុមារ ។
  - សិក្ខាសាលាពិគ្រោះយោបល់ ស្តីពីការរៀបចំផែនទីចង្អុលបង្ហាញ និងប៉ាន់ប្រមាណសេវាសង្គមទាក់ទងនឹងកិច្ចការពារកុមាររងគ្រោះ ដោយសារការជួញដូរ នៅរាជធានី-ខេត្តចំនួន០៧ (រាជធានីភ្នំពេញ, ខេត្តសៀមរាប, បាត់ដំបង, ព្រះសីហនុ, កំពត, តាកែវ, និងខេត្តស្វាយរៀង) ។
- <u>ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ:</u>
  - ធ្វើជាវាគ្មិនផ្សាយក្នុងកម្មវិធីពន្លកថ្មី វិទ្យុសំឡេងប្រជាធិបតេយ្យ និងក្នុងកម្មវិធីសម្លេងសហជីពនៃវិទ្យុមហានគរ ជាសារឆ្លើយតបពាក់ព័ន្ធក្នុងការលុបបំបាត់ទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារ ។

- សហការជាមួយអង្គការ ILO អាជ្ញាធរមូលដ្ឋាន ដកហូតកុមារចេញពីទម្រង់ធ្ងន់ធ្ងរនៃពលកម្មបានចំនួន៥,២៧១នាក់ កុមារីចំនួន១,៩៩១នាក់ ចេញពីវិស័យសិប្បកម្មឡឥដ្ឋ ទូកនេសាទ និងចំការកៅស៊ូ ។

- <u>**លេខាធិការដ្ឋានជាតិ ប.ជ.រ.ព.ភ និងក្រសួងយុត្តិធម៌**</u>
  - ចូលរួមជាវាគ្មិន សម្របសម្រួល និងផ្តល់អនុសាសន៍ ក្នុងសិក្ខាសាលាស្តីពី ការលើកកម្ពស់គុណភាពសេវាកម្មច្បាប់សម្រាប់កុមាររងគ្រោះដោយការជួញដូរ ការរំលោភបំពាន និងកេងប្រវ័ញ្ចផ្លូវភេទ ដែលរៀបចំដោយអង្គការទស្សនៈពិភពលោក ។

**៧- <u>ការងារទេសន្តរប្រវេសន៍:</u>**

តាំងពីបានប្រកាសជាផ្លូវការក្រុមការងារទេសន្តរប្រវេសន៍ ដែលជាក្រុមការងារទី៧របស់លេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិ ប.ជ.រ.ព.ភ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់**ឯកឧត្តម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ** កាលពីថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០១២រួចមក ក្រុមការងារបានចាប់ផ្តើមធ្វើសកម្មភាពយ៉ាងសកម្ម ដើម្បីកំណត់រកបញ្ហា ឫសគល់ និង យុទ្ធសាស្ត្រនិងយុទ្ធវិធីក្នុងការកែលំអស្ថានភាពឲ្យប្រសើរឡើង ។

- លេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិ និងក្រុមការងារទេសន្តរប្រវេសន៍ បានបំពេញភារកិច្ចដូចខាងក្រោម៖
  - បានចុះធ្វើទស្សនកិច្ច និងសិក្សាលើគោលដៅក្រុមហ៊ុនជ្រើសរើសពលករចំនួន០៤ (អ៊ឹងឬទ្ធីគ្រុប, AJC កម្ពុជា, ហ្វីលីម៉ែរ, ក្រុមហ៊ុន Success Man Power ) ក្នុងគោលបំណងសិក្សាអំពីរបៀបរបបនៃការជ្រើសរើស បណ្តុះបណ្តាល និងបញ្ជូនពលករ ការគ្រប់គ្រង ទំហំនៃការទទួលខុសត្រូវ និងស្វែងរកចំណុចខ្វះខាតដែលត្រូវកែលំអ និងបំពេញបន្ថែម ដើម្បីកាត់បន្ថយភាពរងគ្រោះរបស់ពលករកម្ពុជាដែលត្រូវបញ្ជូនឲ្យទៅធ្វើការនៅក្រៅប្រទេស។
  - សមាជិកក្រុមការងារចំនួន២១នាក់ បានចុះធ្វើទស្សនៈកិច្ចសិក្សានៅប្រទេសម៉ាលេស៊ី ក្នុងគោលបំណងសិក្សាស្រាវជ្រាវជុំវិញបញ្ហាទេសន្តរប្រវេសន៍ការងារបំរើតាមផ្ទះ និងក្រុមហ៊ុន ក្នុងការគ្រប់គ្រងពលករ សំដៅរកឲ្យឃើញចំណុចវិជ្ជមាន និងអវិជ្ជមាន ដើម្បីមានវិធានការតម្រង់ទិស កែលំអ បញ្ចៀសបានពីបាតុភាពមិនប្រក្រតីផ្សេងៗ ធានាបាននូវការគោរពសិទ្ធិ និងភាពស្របច្បាប់ របស់ពលករនៅក្រៅប្រទេស ។
  - បានជួបពិភាក្សា ជាមួយគណៈកម្មាធិការទី៦ និងទី៨ នៃរដ្ឋសភា ដើម្បីផ្តល់ព័ត៌មានក៏ដូចជាពិភាក្សាលើគោលគំនិតក្នុងការគ្រប់គ្រងលំហូរទេសន្តរប្រវេសន៍
  - ប្រជុំបូកសរុបលទ្ធផលនៃការចុះធ្វើទស្សនៈកិច្ចសិក្សាទាំងក្នុង និងក្រៅប្រទេស ដើម្បីពិនិត្យលើចំណុចប្រឈម និងខ្វះចន្លោះពាក់ព័ន្ធនឹងបញ្ហាទេសន្តរប្រវេសន៍ការងារ និងមានមូលដ្ឋានគ្រប់គ្រាន់ក្នុងការរៀបចំយុទ្ធសាស្ត្រសម្របសម្រួលជម្រុញការគ្រប់គ្រងធានាបានសុវត្ថិភាពជូនពលករទេសន្តរប្រវេសន៍ ។
  - **ក្រសួងកិច្ចការនារី សហការជាមួយអង្គការ UN Women** បាន៖
    - ✓ ចុះសិក្សាស្រាវជ្រាវជាមួយទីភ្នាក់ងារជ្រើសរើសពលករចំនួន២៣ ដែលមានទីស្នាក់ការនៅក្នុងទីក្រុងភ្នំពេញពលករកំពុងត្រៀមចេញដំណើរចំនួន៦នាក់ ពីព័ត៌មានដែលទាក់ទងនឹងនីតិវិធីក្នុងការជ្រើសរើស ការបណ្តុះបណ្តាល ការបញ្ជូនពលករ បញ្ហា

ដែលកើតមានចំពោះក្រុមហ៊ុន ក៏ដូចជាចំពោះពលករ ចំណុចល្អ ចំណុចមិនទាន់ល្អ និងបញ្ហាប្រឈមនានា នៅគ្រប់តំណាក់កាលនៃការចាប់ផ្ដើម រហូតដល់ចំណុចចុងបញ្ចប់ និង

- ✓ ចងក្រងឯកសារបណ្ដុះបណ្ដាលស្ដីពី យេនឌ័រ និងទេសន្តរប្រវេសន៍សម្រាប់ប្រើប្រាស់នៅថ្នាក់ក្រោមជាតិ ។

- <u>ក្រសួងការងារបណ្ដុះបណ្ដាលវិជ្ជាជីវៈ</u>

បានសហការជាមួយក្រុមហ៊ុនចំនួន២៥ បណ្ដុះបណ្ដាល និងបញ្ជូនពលករចេញទៅធ្វើការងារនៅក្រៅប្រទេសបានចំនួន៣៩,៥០១នាក់ ស្រីចំនួន១០,៦៩២នាក់ តាមតារាងដូចខាងក្រោម៖

តារាងបញ្ជូនពលករទៅក្រៅប្រទេសតាមប្រព័ន្ធស្របច្បាប់ក្នុងឆ្នាំ២០១២

| ល.រ. | ប្រទេសគោលដៅ | ចំនួនពលករដែលបានបញ្ជូន | ចំនួនពលការិនី |
|---|---|---|---|
| ១. | ប្រទេសម៉ាឡេស៊ី | ១៨០នាក់ | ៧០នាក់ |
| ២. | ប្រទេសថៃ | ២៦.៣៩០នាក់ | ៩.៨៣៩នាក់ |
| ៣. | ប្រទេសជប៉ុន | ១០២នាក់ | ២៣នាក់ |
| ៤. | ប្រទេសកូរ៉េ(ត្បូង) | ៨.១៣២នាក់ | ១.៣០៤នាក់ |
| | **សរុប** | **៣៤.៨០៤នាក់** | **១១.២៣៦នាក់** |

ដោយឡែកពលករខុសច្បាប់ ដែលបាននឹងកំពុងបម្រើការងារនៅក្នុងប្រទេសថៃ ត្រូវបាន ក្រុមការងារអន្តរក្រសួង <u>ចេញលិខិតបញ្ជាក់អត្តសញ្ញាណជាពលករខ្មែរ (CI) ដើម្បីអាចទទួល បានការអនុញ្ញាតធ្វើការក្នុងប្រទេសថៃដោយស្របច្បាប់បានចំនួន **១៦៤.០៦៨នាក់**</u> នៃចំនួនពលករ ទេសន្តរប្រវេសន៍ខ្មែរ ដែលមានវត្តមានខុសច្បាប់ក្នុងប្រទេសថៃបានចុះបញ្ជីក្នុងក្រសួងការងារថៃ នៅ<u>សល់ ១៦៥.៦៥៤នាក់ទៀតដែលមិនទាន់ទទួលបានប័ណ្ណកំណត់អត្តសញ្ញាណ</u>នេះ ។

## ឃ- <u>ការលើកកម្ពស់សមត្ថភាព</u>

### ១. <u>ការបណ្ដុះបណ្ដាលៈ</u>

ក្នុងឆ្នាំ២០១២ កន្លងទៅពិនិត្យលើការងារបណ្ដុះបណ្ដាល ក្រសួងពាក់ព័ន្ធ និងខេត្តបានសហការជាមួយអង្គការដៃគូមួយចំនួន មានជាអាទិ IJM, World Vision, IoM, ARTIP, SISHA, UNODC, ICE, គម្រោង LEAP របស់ក្រសួងមហាផ្ទៃ ធ្វើការបណ្ដុះបណ្ដាលពង្រឹងសមត្ថភាពមន្ត្រីអនុវត្តច្បាប់ មន្ត្រីពាក់ព័ន្ធនិងប្រជាពលរដ្ឋ ស្ដីពីច្បាប់បង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ និង មាត្រាច្បាប់ពាក់ព័ន្ធមួយចំនួនក្នុងក្រមព្រហ្មទណ្ឌ យុទ្ធសាស្ត្រប្រឆាំងនឹងអំពើជួញដូរមនុស្ស ជំនាញស្រាវជ្រាវ និងការវិភាគទិន្នន័យដោយកម្មវិធីSPSS នីតិវិធីប្រើប្រាស់បទដ្ឋានប្រតិបត្តិការ សម្រាប់អង្គភាពឯកទេសប្រឆាំងការជួញដូរមនុស្ស កិច្ចការពារកុមារពីការកេងប្រវ័ញ្ចន៍ផ្លូវភេទ ក្នុងវិស័យទេសចរណ៍ និងការធ្វើដំណើរ ល្បិចកលជនល្មើស និងចរិកលក្ខណៈរបស់ជនដែលចូលចិត្តរំលោភបំពានផ្លូវភេទលើកុមារ ការបង្ការ-ទប់ស្កាត់ និងការធ្វើចំណាកស្រុកដោយសុវត្ថិភាព។ ដោយឡែកក្រសួងកិច្ចការនារីបានសហការជាមួយអង្គការUN Women បើកវគ្គបណ្ដុះបណ្ដាល ពង្រឹងសមត្ថភាពមន្ត្រីបង្គោលរបស់

ក្រសួងកិច្ចការនារី ក្រសួងមហាផ្ទៃ និងក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈស្តីពីយេនឌ័រ និងទេសន្តរប្រវេសន៍បាន៧វគ្គ សិក្ខាកាម១៨០នាក់ **ស្រី ៩៩នាក់** វគ្គមន្ត្រីថ្នាក់ក្រោមជាតិនៅខេត្តកំពង់ឆ្នាំងបានមួយវគ្គ សិក្ខាកាមចំនួន**៦៥នាក់ ស្រី២៧នាក់** ។

សរុបវគ្គបណ្តុះបណ្តាល បានចំនួន១១៨វគ្គ មានអ្នកចូលសរុបរួមចំនួន**៥.១៦៣**នាក់ (ស្រី**១,៨៤៧** នាក់) ក្នុងនោះមាន ៖

**តារាងវគ្គបណ្តុះបណ្តាលៈ**

| ស្ថាប័នអនុវត្ត | ចំនួនវគ្គ | ចំនួនសិក្ខាកាមសរុប | សិក្ខាកាមជានារី |
|---|---|---|---|
| ក្រសួងមហាផ្ទៃ | ៣៩ | ១ ២៣៧នាក់ | ២៣នាក់ |
| ក្រសួងកិច្ចការនារី | ០៩ | ៤៣៣នាក់ | ១៥៨នាក់ |
| ក្រុមការងារ COMMITកម្ពុជា | ០២ | ១៦១នាក់ | ៨៥នាក់ |
| ក្រុមការងារកិច្ចការយុត្តិធម៌ | ០២ | ៨០នាក់ | ៣៥នាក់ |
| ក្រសួងទេសចរណ៍ | ០៣ | ៧១នាក់ | ៣៥នាក់ |
| ក្រសួងអប់រំ យុវជន និងកីឡា | ០៨ | ៥២៥នាក់ | ៨២នាក់ |
| សាលាបណ្ឌិតសភានគរបាលកម្ពុជា | ០១ | ៧០នាក់ | ៧០នាក់ |
| កងរាជអាវុធហត្ថ | ០២ | ៧៨នាក់ | ៥១នាក់ |
| អង្គការសេកម្មភាពដើម្បីកុមារ | ១៩ | ១,២០៥នាក់ | ៥២២នាក់ |
| ខេត្តសៀមរាប | ០១ | ៤៣នាក់ | ២៦នាក់ |
| ខេត្តស្វាយរៀង | ០៨ | ២៥៥នាក់ | ៤២នាក់ |
| ខេត្តកំពត | ០២ | ៨៧នាក់ | ១៩នាក់ |
| ខេត្តបាត់ដំបង | ០១ | ១៥នាក់ | ០៣នាក់ |
| កណ្តាល | ០៤ | ២០៦នាក់ | ៧០នាក់ |
| ខេត្តតាកែវ | ០២ | ៧៥នាក់ | ៤០នាក់ |
| ខេត្តព្រៃវែង | ០១ | ៣៣នាក់ | |
| ខេត្តព្រះសីហនុ | ០១ | ៣០នាក់ | ០៣នាក់ |
| ខេត្តបន្ទាយមានជ័យ | ០៧ | ៣៣២នាក់ | ១៥៤នាក់ |
| ខេត្តព្រះវិហារ | ០១ | ៤៤នាក់ | ២២នាក់ |
| ខេត្តកោះកុង | ០៣ | ៥១នាក់ | |
| ខេត្តកំពង់ឆ្នាំង | ០៣ | ១៧៣នាក់ | ៧៧នាក់ |
| **សរុប** | **១១៨វគ្គ** | **៥.៨៦៣នាក់** | **១.៥១៧នាក់** |

ក្រៅពីនេះ សាលាបណ្ឌិត្យសភានគរបាលកម្ពុជា បានបើកវគ្គបណ្តុះបណ្តាល បំប៉នសមត្ថភាពមន្ត្រីនគរបាលជានារីមកពីបណ្តារាជធានី ខេត្ត ទាំង ២៤ លើជំនាញប្រឆាំងការជួញដូរមនុស្ស និងបញ្ហាបយេនឌ័រ បាន ៧០នាក់ ក្នុងរយៈពេល ៣ខែ ។

## ២. សិក្ខាសាលា

ការងារសិក្ខាសាលាក្នុងឆ្នាំ២០១២កន្លងទៅនេះ ស្ថាប័នពាក់ព័ន្ធនៅថ្នាក់ជាតិនិងរាជធានី-ខេត្ត បានសហការជាមួយអង្គការដៃគូបើកសិក្ខាសាលា ស្តីពីច្បាប់បង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ការលើកកម្ពស់សុវត្ថភាពចំណាកស្រុក និងទេសន្តរប្រវេសន៍ ទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារ សុវត្ថិភាពកុមារក្នុងវិស័យទេសចរណ៍ និងកិច្ចការពារកុមារពីការកេងប្រវ័ញ្ចផ្លូវភេទ លើកកម្ពស់សេវាកម្មច្បាប់សម្រាប់កុមាររងគ្រោះដោយការជួញដូរមនុស្ស និងការរំលោភបំពាន លិខិតុបករណ៍សិទ្ធិមនុស្ស ស្តង់ដារអន្តរជាតិនិងសិទ្ធិពលករទេសន្តរប្រវេសន៍ ចែករំលែកបទពិសោធន៍ ល្អៗទប់ស្កាត់អំពើជួញដូរមនុស្ស រៀបចំផែនទីចង្អុលបង្ហាញប៉ាន់ប្រមាណសេវាការពារកុមារ និងការរៀបចំផែនការសកម្មភាពសម្រាប់អនុវត្តឆ្នាំ២០១២-២០១៣ និងការបញ្ជ្រាបយេនឌ័រ និងទេសន្តរប្រវេសន៍ទៅក្នុងផែនការអភិវឌ្ឍន៍ សរុបបានចំនួន**៥០**វគ្គ សិក្ខាកាមចំនួន **៣,២៦៥**នាក់ (ស្រី**៩៥២**នាក់) ក្នុងនោះមាន ៖

តារាងវគ្គសិក្ខាសាលា៖

| ស្ថាប័នអនុវត្ត | ចំនួនវគ្គ | ចំនួនសិក្ខាកាមសរុប | សិក្ខាកាមជានារី |
|---|---|---|---|
| លេខាធិការដ្ឋានជាតិដឹកនាំ ប.ជ.រ.ព.ភ | ០៣ | ២៥៤នាក់ | ១០៩នាក់ |
| អគ្គស្នងការនគរបាល/ក្រសួងមហាផ្ទៃ | ០២ | ១១២នាក់ | ២១នាក់ |
| ក្រសួងអប់រំ យុវជន និងកីឡា | ០៣ | ៣៥៩នាក់ | ៤៩នាក់ |
| ក្រសួងទេសចរណ៍ | ០៨ | ៣២៤នាក់ | ១៣២នាក់ |
| ក្រសួងកិច្ចការនារី | ០៣ | ២៩០នាក់ | ១០៧នាក់ |
| ក្រុមការងារកិច្ចការយុត្តិធម៌ | ០៥ | ១៨៤នាក់ | ៦៩នាក់ |
| ក្រុមការងារកិច្ចការកុមារ | ០២ | ២៤៦នាក់ | ៦០នាក់ |
| ក្រុមប្រឹក្សាជាតិដើម្បីកុមារ | ០២ | ១១៣នាក់ | ៨០នាក់ |
| រាជធានីភ្នំពេញ | ០១ | ២៣៦នាក់ | ៤១នាក់ |
| ខេត្តស្វាយរៀង | ០៤ | ១៧១នាក់ | ៦៤នាក់ |
| ខេត្តបន្ទាយមានជ័យ | ០៦ | ២៦៩នាក់ | ៥៨នាក់ |
| ខេត្តសៀមរាប | ០១ | ៤៣នាក់ | ២៥នាក់ |
| ខេត្តព្រៃវែង | ០១ | ៨១នាក់ | ១៧នាក់ |
| ខេត្តតាកែវ | ០១ | ៨៥នាក់ | ០៦នាក់ |
| ខេត្តកំពង់ចាម | ០១ | ៣៧នាក់ | ១៧នាក់ |
| ខេត្តកំពង់ស្ពឺ | ០១ | ៦២នាក់ | ២៩នាក់ |
| ខេត្តកណ្តាល | ០១ | ៦៥នាក់ | ២៨នាក់ |
| អង្គការសកម្មភាពដើម្បីកុមារ | ០១ | ៨៦នាក់ | ១៧នាក់ |
| អង្គការCARAM | ០១ | ១០៦នាក់ | ៨៦នាក់ |
| អង្គការUNWOMEN | ០១ | ១៣២នាក់ | |
| អង្គការទស្សនៈពិភពលោក | ០១ | ៧០នាក់ | |
| អង្គការLSCW | ០១ | ២៥នាក់ | ១៣នាក់ |

| សរុប | ៥០វគ្គ | ៣ .២៦៥នាក់ | ៩៥២នាក់ |
|---|---|---|---|

## III-**តារាងប្រៀបធៀបសកម្មភាព** (រយៈពេល០៣ឆ្នាំ)

ដើម្បីមានមូលដ្ឋានក្នុងការវាយតម្លៃ យើងអាចប្រៀបធៀបលទ្ធផលនៃកិច្ចប្រតិបត្តិការក្នុងឆ្នាំ២០១២ នេះ ទៅនឹងឆ្នាំ ២០១០និង២០១១ ដូចខាងក្រោម ៖

ក-ការងារបង្ការ-ទប់ស្កាត់

| ចំនួនប្រជាជនដែលបានទទួលការអប់រំទប់ស្កាត់ការឆ្លងដែនខុសច្បាប់ | | | ផ្សេងៗ |
|---|---|---|---|
| ២០១០ | ២០១១ | ២០១២ | ប្រជាជនព្យាយាមឆ្លងដែនខុសច្បាប់ដែលត្រូវសមត្ថកិច្ចទប់ស្កាត់បានកាន់តែច្រើន |
| ៦២៩នាក់ | ៤.៩២៣នាក់ | ៦០,៣៤៧នាក់ | |

ខ. ការកំណត់ជនដែលសង្ស័យថាជាមេខ្យល់ដើម្បីស្រាវជ្រាវសារតាជាតិ

| ក្តាប់បានមេខ្យល់រកស៊ីនាំមនុស្សឆ្លងដែន | | | ផ្សេងៗ |
|---|---|---|---|
| ២០១០ | ២០១១ | ២០១២ | ជនដែលសង្ស័យថាជាមេខ្យល់នាំពលករចេញដោយខុសច្បាប់ត្រូវបានសមត្ថកិច្ចស្រាវជ្រាវកំណត់មុខសញ្ញាបានជាបន្តបន្ទាប់ ។ |
| ១៣១នាក់ | ៦២នាក់ | ៣៧នាក់ | |

គ-ការងារផ្សព្វផ្សាយ

| ចំនួនមនុស្សដែលបានចូលរួមផ្សព្វផ្សាយ | | | ផ្សេងៗ |
|---|---|---|---|
| ២០១០ | ២០១១ | ២០១២ | |
| ២២.២៧២នាក់ | ៧២៨.០៦០នាក់ (ស្រី២៤២,៩១០ នាក់) | ៥១៦,៣៩៧នាក់ (ស្រី២២១,១៧៧ នាក់) | ចំនួនអ្នកចូលរួមក្នុងការផ្សព្វផ្សាយជាងកន្លះលាននាក់ បានយល់ដឹងអំពីការជួញដូរមនុស្ស |

ឃ-ការងារបណ្តុះបណ្តាល

| ចំនួនមនុស្សដែលបានចូលរួមបណ្តុះបណ្តាល | | | | | | | | | ផ្សេងៗ |
|---|---|---|---|---|---|---|---|---|---|
| ២០១០ | | | ២០១១ | | | ២០១២ | | | |
| លើក | រួម | ស្រី | លើក | រួម | ស្រី | លើក | រួម | ស្រី | |
| ៣១ | ១.៣៤៨ នាក់ | ១៦៤ នាក់ | ៦០០ | ៥២.១០៨ នាក់ | ១៨.២៩៩ នាក់ | ១០៦ | ៤,២៨៤ នាក់ | ១,២៦៦ នាក់ | ការបណ្តុះបណ្តាលបានតិចជាង២០១១ |

ង-ការងារសិក្ខាសាលា

| ចំនួនមនុស្សដែលបានចូលរួមសិក្ខាសាលា | | | | | | | | | ផ្សេងៗ |
|---|---|---|---|---|---|---|---|---|---|
| វគ្គ | ២០១០ | | វគ្គ | ២០១១ | | វគ្គ | ២០១២ | | |
| | រួម | ស្រី | | រួម | ស្រី | | រួម | ស្រី | |
| ៩វគ្គ | ៨១៣ នាក់ | ១១៣ នាក់ | ៣៥វគ្គ | ២.៤៥១ នាក់ | ៧៩៥ នាក់ | ៨៤វគ្គ | ៣,០៧៥ នាក់ | ៨៧៧ នាក់ | ច្រើនជាងឆ្នាំ២០១១ |

ច-តួលេខចំណាកស្រុក

| ចំនួនមនុស្សធ្វើចំណាកស្រុកដែលបានរាយការណ៍ពីបណ្តាខេត្ត | | | | | | ផ្សេងៗ |
|---|---|---|---|---|---|---|
| ២០១០ មានចំនួន | | ២០១១ មានចំនួន | | ២០១២ មានចំនួន | | |
| រួម | ស្រី | រួម | ស្រី | រួម | ស្រី | |
| ៩៥.១០៦នាក់ | ៣៧.០៩៨ នាក់ | ១៤២.៤៩៤ នាក់ | ៥៥.៦៨៤ នាក់ | ១៤២.០៦៥ នាក់ | ៥៩.៨២០ នាក់ | ចំនួននេះគ្របដណ្តប់ទាំងនៅក្នុងនិងទៅក្រៅប្រទេស |

ឆ-តួលេខទេសន្តរប្រវេសន៍ដែលអាជ្ញាធរប្រទេសជិតខាងបញ្ជូនមកវិញ

| ២០១០ | | ២០១១ | | ២០១២ | | |
|---|---|---|---|---|---|---|
| ថៃ | វៀតណាម | ថៃ | វៀតណាម | ថៃ | វៀតណាម | ឡាវ |
| ១២៦.៤៦៧ នាក់ | ៥៨៦ នាក់ | ១១៨.១៣៣ នាក់ | ៦៥៨ នាក់ | ១២៣,២៦១នាក់ (តិចជាង២០១០ ច្រើនជាង ២០១១) | ២៥៩នាក់ (តិចជាងឆ្នាំមុនៗ) | ៨៦នាក់ (របត់ថ្មី) |

ឈ-<u>ការងារបង្ក្រាបបទល្មើស</u>

| បទល្មើស | ឆ្នាំ២០១០ | | | ឆ្នាំ២០១១ | | | ឆ្នាំ២០១២ | | | ផ្សេងៗ |
|---|---|---|---|---|---|---|---|---|---|---|
| | ចំនួនករណី | ជនសង្ស័យ | | ចំនួនករណី | ជនសង្ស័យ | | ចំនួនករណី | ជនសង្ស័យ | | |
| | | រួម | ស្រី | | រួម | ស្រី | | រួម | ស្រី | |
| ជួញដូរមនុស្ស | ៦៥ | ១០២ | ២២ | ៧១ | ៩៩ | ២២ | ៥៣ | ៧៥ | ១៤ | រូបភាពនៃការជួញដូរ ប្រែប្រួល និង ពិបាក កំណត់ អត្តសញ្ញាណ |
| អាជីវកម្មផ្លូវភេទ | ៩៥ | ១៤០ | ៥៧ | ១២៣ | ១៥៦ | ៥៦ | ៨០ | ៩០ | ២៩ | |
| សរុប | ១៦០ | ២៤២ | ៧៩ | ១៩៤ | ២៥៥ | ៧៨ | ១៣៣ | ១៦៥ | ៤៣ | |

ញ-<u>ការសង្គ្រោះជនរងគ្រោះ</u>

| រងគ្រោះដោយអំពើ | ឆ្នាំ២០១០ | | | ឆ្នាំ២០១១ | | | ឆ្នាំ២០១២ | | | ផ្សេងៗ |
|---|---|---|---|---|---|---|---|---|---|---|
| | រួម | អាយុ-១៥ | ១៥-១៧ | រួម | អាយុ-១៥ | ១៥-១៧ | រួម | អាយុ-១៥ | ១៥-១៧ | |
| ជួញដូរមនុស្ស | ២៦៤ | ១៦ | ៤០ | ១២១ | ២៨ | ៩៣ | ២៧៨ | ២៦ | ៤៥ | ជនរងគ្រោះជាកុមារ ថយចុះ ។ |
| អាជីវកម្មផ្លូវភេទ | ៤២២ | ៧១ | ៦៩ | ៩២ | ៨៤ | ០៨ | ១៨០ | ៦៧ | ១៦ | |
| សរុប | ៦៨៦ | ៨៧ | ១០៩ | ២១៣ | ១១២ | ១០១ | ៤៥៨ | ៩៣ | ៦១ | |

ដ-<u>ការងារផ្តន្ទាទោស</u> (ក្នុងរឿងក្តីជួញដូរមនុស្ស និងអាជីវកម្មផ្លូវភេទ)

| ២០១០ | | ២០១១ | | ២០១២ | | ផ្សេងៗ |
|---|---|---|---|---|---|---|
| ចំនួនករណី | ផ្តន្ទាទោស | ចំនួនករណី | ផ្តន្ទាទោស | ចំនួនករណី | ផ្តន្ទាទោស | |
| ១៣៨ | ២១៥នាក់ | ១១២ | ១៨២នាក់ | ២២៧ | ៣០០នាក់ | ចំណាត់ការតុលាការប្រសើរជាងឆ្នាំមុនៗ |

IV-**<u>ការតាមដាន ត្រួតពិនិត្យ</u>** :

ក្នុងឆ្នាំ២០១២នេះ លេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិបានពង្រឹងសកម្មភាពតាមដានត្រួត ពិនិត្យ ដោយចាត់តាំងក្រុមតាមដានត្រួតពិនិត្យការអនុវត្តសកម្មភាពរបស់លេខាធិការដ្ឋានរាជធានី- ខេត្ត តាមសេចក្តីសម្រេចរបស់លេខាធិការដ្ឋានលេខ០៩២សសរ ចុះថ្ងៃទី១១ ខែតុលា ឆ្នាំ២០១២។ មាន០៦ក្រុម ដែលក្រុមនីមួយៗដឹកនាំដោយអនុប្រធានលេខាធិការដ្ឋានមួយរូប រួមជាមួយប្រធាននិងអនុប្រធានក្រុមការងារមួយដែលមកពីបណ្តាក្រសួងពាក់ព័ន្ធនិងអង្គការមិនមែនរដ្ឋាភិបាល ។

នៅក្នុងអំឡុងពេលចុះត្រួតពិនិត្យ យើងបានទទួលលទ្ធផលដូចខាងក្រោម៖

**១. លទ្ធផលនៃការត្រួតពិនិត្យ**

១-១.<u>ខេត្តដែលមានដីកា ឬសេចក្តីសម្រេចស្តីពីការបង្កើតគណៈកម្មាធិការ និងលេខាធិការដ្ឋាន ប.ជ.រ.ព.ភ ៖</u>

សរុបចំនួន:២៤រាជធានី-ខេត្ត ក្នុងនោះមាន៖

រាជធានីភ្នំពេញ, កំពង់ស្ពឺ, កោះកុង, ព្រះសីហនុ, ក្រចេះ, ស្ទឹងត្រែង, រតនៈគីរី, ឧត្តរមានជ័យ, សៀមរាប, ព្រះវិហារ, កំពង់ធំ, កំពត, កែប, តាកែវ, កណ្តាល, កំពង់ចាម, កំពង់ឆ្នាំង, ព្រៃវែង, ស្វាយរៀង, បន្ទាយមានជ័យ, ពោធិ៍សាត់, បាត់ដំបង, ប៉ៃលិន និងមណ្ឌលគីរី (កែសម្រួលជាថ្មី)។

១-២.<u>មានការិយាល័យការងារ៖</u>

សរុបចំនួន:១០ខេត្ត ក្នុងនោះមាន៖

កោះកុង, ព្រះសីហនុ, សៀមរាប, ព្រះវិហារ, កំពង់ធំ, តាកែវ, កណ្ដាល, ស្វាយរៀង, បន្ទាយមានជ័យ, បាត់ដំបង។

➢ **ខេត្តមិនទាន់បានបង្កើត (ក្នុងអំឡុងពេលចុះត្រួតពិនិត្យ)**

សរុបចំនួន៖ **១៤រាជធានី- ខេត្ត** ក្នុងនោះមាន៖

រាជធានីភ្នំពេញ, កំពង់ស្ពឺ, មណ្ឌលគីរី, ក្រចេះ, ស្ទឹងត្រែង, រតនៈគីរី, ឧត្ដរមានជ័យ, កំពត, កែប, កំពង់ចាម, កំពង់ឆ្នាំង, ព្រៃវែង, ពោធិ៍សាត់, ប៉ៃលិន។

**១-៣.ផែនការសកម្មភាពសម្រាប់អនុវត្តរបស់លេខាធិការដ្ឋាន៖**

សរុបចំនួន៖**២៣រាជធានី-ខេត្ត** ក្នុងនោះមាន

រាជធានីភ្នំពេញ, កំពង់ស្ពឺ, កោះកុង, ព្រះសីហនុ, មណ្ឌលគីរី, ក្រចេះ, ស្ទឹងត្រែង, សៀមរាប, ព្រះវិហារ, កំពង់ធំ, កំពត, កែប, តាកែវ, កណ្ដាល, កំពង់ចាម, កំពង់ឆ្នាំង, ព្រៃវែង, ស្វាយរៀង, បន្ទាយមានជ័យ, ពោធិ៍សាត់, បាត់ដំបង, ប៉ៃលិន,ឧត្ដរមានជ័យ ។

➢ **ខេត្តមិនទាន់មាន**

សរុបចំនួន៖ **០១ខេត្ត** ក្នុងនោះគឺ ខេត្តរតនៈគីរី ។

**១-៤. មានមន្ត្រីអចិន្ត្រៃយ៍ប្រចាំការ៖**

សរុបចំនួន៖**១៤រាជធានី-ខេត្ត** ក្នុងនោះមាន

រាជធានីភ្នំពេញ, កោះកុង(០៣នាក់), ក្រចេះ(០១នាក់), ស្ទឹងត្រែង, សៀមរាប(០១នាក់), កំពង់ធំ(០២នាក់), កំពត(០១នាក់), កែប(០១នាក់), តាកែវ(០៣នាក់), កណ្ដាល, កំពង់ឆ្នាំង, ស្វាយរៀង(០២នាក់), បន្ទាយមានជ័យ(០៣នាក់), ប៉ៃលិន(០១នាក់)។

➢ **ខេត្តមិនទាន់មានមន្ត្រីប្រចាំការ (ក្នុងអំឡុងពេលចុះត្រួតពិនិត្យ)**

សរុបចំនួន៖**១០ខេត្ត** ក្នុងនោះមាន

កំពង់ស្ពឺ, ព្រះសីហនុ, មណ្ឌលគីរី, រតនៈគីរី, ឧត្ដរមានជ័យ, ព្រះវិហារ, កំពង់ចាម, ព្រៃវែង, ពោធិ៍សាត់, បាត់ដំបង។

**១-៥. កិច្ចប្រជុំទៀងទាត់៖**

សរុបចំនួន៖ **០៧ ខេត្ត** ក្នុងនោះមាន

កោះកុង, ព្រះសីហនុ, ព្រះវិហារ, តាកែវ, កណ្ដាល, ស្វាយរៀង, ប៉ៃលិន។

➢ **ខេត្តដែលរាយការណ៍ថាប្រជុំមិនបានទៀងទាត់៖**

សរុបចំនួន៖**១៧ រាជធានី-ខេត្ត** ក្នុងនោះមាន

រាជធានីភ្នំពេញ, កំពង់ស្ពឺ, មណ្ឌលគីរី, ក្រចេះ, ស្ទឹងត្រែង, រតនៈគីរី, ឧត្ដរមានជ័យ, សៀមរាប, កំពង់ធំ, កំពត, កែប, កំពង់ចាម, កំពង់ឆ្នាំង, ព្រៃវែង, បន្ទាយមានជ័យ, ពោធិ៍សាត់, បាត់ដំបង។

**១-៦.មានកំណត់ហេតុកិច្ចប្រជុំ និងមានការតាមដានត្រួតពិនិត្យ៖**

សរុបចំនួន៖ **០៨រាជធានី-ខេត្ត** ក្នុងនោះមាន

រាជធានីភ្នំពេញ, កោះកុង, ព្រះសីហនុ, សៀមរាប, កំពត, តាកែវ, កណ្ដាល, បន្ទាយមានជ័យ។

➢ **ខេត្តដែលរាយការណ៍ថាមិនបានធ្វើទៀងទាត់៖**

សរុបចំនួន៖ **១៦ ខេត្ត** ក្នុងនោះមាន

កំពង់ស្ពឺ,មណ្ឌលគីរី, ក្រចេះ, ស្ទឹងត្រែង, រតនៈគីរី, ព្រះវិហារ, កំពង់ធំ, កែប, កំពង់ចាម, កំពង់ឆ្នាំង, ព្រៃវែង, ស្វាយរៀង, ពោធិ៍សាត់, បាត់ដំបង, ប៉ៃលិន, ឧត្ដរមានជ័យ ។

**១-៧. មានសមាសភាពអង្គការចូលរួម៖**

សរុបចំនួន៖ **១៥រាជធានី-ខេត្ត** ក្នុងនោះមាន

រាជធានីភ្នំពេញ, កោះកុង, ព្រះសីហនុ, សៀមរាប, ព្រះវិហារ, កំពង់ធំ, កំពត, កំពង់ចាម, កំពង់ឆ្នាំង, ព្រៃវែង, ស្វាយរៀង, បន្ទាយមានជ័យ, ពោធិសាត់, បាត់ដំបង, ប៉ៃលិន។

**អង្គការដៃគូមាន៖**

Winrock International, សម្ព័ន្ធខ្មែរជំរឿន, លីកាដូ, វេណាលេ, ទឹកចិត្តម្តាយ, CARE, HCC, -AFESIP- មូលនិធិសុម៉ាលីម៉ម, មួប់តាប៉ាង, KWCD, Bigc, Child Wise, ILO, IJM, UN Women, Woldvision, សហគមន៍អភិវឌ្ឍន៍កុមារ, Plan International, ការីតាស, HOM , ពុទ្ធសាសនាដើម្បីអភិវឌ្ឍន៍ CARAM, សមាគមស្ត្រីកម្ពុជា សមាគមភ្នំស្រី CCJAP, CWCC, VCAO, DCO, COCD, OEC, LAC, សមាគមនារីកម្ពុជាដើម្បីសន្តិភាពនិងអភិវឌ្ឍន៍ (CWPD), Child Fund បន្ទាយស្រី សន្តិសេនា តំណក់ទឹកពន្លឺកុមារ កម្ពុជាក្តីសង្ឃឹម និងអង្គការគ្រួសារថ្មី ។

**សកម្មភាពអង្គការដៃគូ៖**ស្តារនីតិសម្បទាជនរងគ្រោះ ផ្តល់សេវាកម្មផ្លូវច្បាប់ ទទួលពាក្យបណ្តឹង អប់រំ,ផ្សព្វផ្សាយពីបញ្ហាចំណាកស្រុកដោយខុសច្បាប់ បណ្តុះបណ្តាលជំនាញដើម្បី បង្កើតមុខរបរ ព្យាបាលជម្ងឺ រៀបចំកិច្ចប្រជុំប្រចាំខែ(អាហារសំរ៉ន់) ផ្សព្វផ្សាយវេទិកាទិវា១២ធ្នូ វេទិកាសាធារណៈ សំភារៈការិយាល័យ,...។

- **ខេត្តមិនទាន់មានអង្គការចូលរួម៖**

សរុបចំនួន៖០៩ ខេត្ត ក្នុងនោះមាន៖

កំពង់ស្ពឺ ក្រចេះ, មណ្ឌលគីរី, ស្ទឹងត្រែង, ឧត្តរមានជ័យ, កែប, តាកែវ, កណ្តាល, រតនៈគីរី ។

### ១-៨. ការចូលរួមធ្វើសកម្មភាពតាមក្រុម ឬតាមយុទ្ធសាស្ត្រ៖

| យុទ្ធសាស្ត្រ | អង្គភាព-អង្គការ ស្ថាប័ន | សកម្មភាព និងលទ្ធផល |
|---|---|---|
| ការបង្ការ ទប់ស្កាត់ | -គណៈបញ្ជាការឯកភាព<br>-ស្នងការដ្ឋាននគរបាល<br>-នគរបាល,<br>កងរាជអាវុធហត្ថ<br>-អង្គការមិនមែនរដ្ឋាភិបាល<br>-<br>មន្ទីរជុំវិញខេត្ត(សមាសភាពលេខាធិការដ្ឋាន) | -បង្ក្រាប-ទប់ស្កាត់-អាជីវកម្មផ្លូវភេទ លើស្ត្រីនិងកុមារ-លក់-បញ្ជាំង និងចែកចាយរូបភាពអាសអាភាស, ផ្សព្វផ្សាយតាមទូរទស្សន៍, វិទ្យុ,<br>-បណ្តុះបណ្តាលកុមារ ក្នុងវិស័យទេសចរណ៍ ។<br>-ចុះត្រួតពិនិត្យតាមដាន លើយុទ្ធនាការប្រមូលសិស្សបោះបង់ចោលការសិក្សា |
| កិច្ចការពារជនរងគ្រោះ | -គណៈបញ្ជាការឯកភាព<br>-ស្នងការដ្ឋាននគរបាល<br>-មន្ទីរសង្គមកិច្ចខេត្ត<br>-មន្ទីរការងារខេត្ត<br>-អង្គការដៃគូរ | -តាមដានផ្តល់ព័ត៌មាន, ជួយអន្តរាគមន៍<br>-ផ្សព្វផ្សាយ -អប់រំ, បណ្តុះបណ្តាល,<br>-ជួយជនរងគ្រោះ, និងធ្វើសមាហរណកម្មជនរងគ្រោះ<br>-ទទួលនារីរងគ្រោះ<br>-ស្តារនីតិសម្បទា សមាហរណកម្មជួយដល់កុមារសុំទានមកពីប្រទេសថៃ វៀតណាម<br>-ណែនាំជនចំណាកស្រុកឆ្លងដែនខុស ច្បាប់<br>-កំណត់អត្តសញ្ញាណជនរងគ្រោះ |

| | | |
|---|---|---|
| ការអនុវត្តច្បាប់ | -គណៈបញ្ជាការឯកភាព<br>-ស្នងការដ្ឋាននគរបាល<br>-កងរាជអាវុធហត្ថ<br>-អង្គការ | -កសាងសំណុំរឿង,<br>បញ្ជូនជនល្មើសទៅសាលា ដំបូង<br>-តាមដាន គ្រប់គ្រងជនល្មើស<br>-បង្កើនចំណេះដឹង បច្ចេកទេសស៊ើប អង្កេត |
| កិច្ចការយុត្តិធម៌ | -ទីចាត់ការកិច្ចការច្បាប់<br>-សាលាដំបូងខេត្តរាជធានី-ខេត្ត | -សហការជាមួយសមត្ថកិច្ចពាក់ព័ន្ធ<br>ដើម្បីធ្វើការផ្តន្ទាទោសជនល្មើស<br>-មានបន្ទប់សវនាការដោយឡែក<br>(មានរបាំងការពារកុមារ និងជនសង្ស័យ) |
| កិច្ចសហប្រតិបត្តិការអន្តរជាតិ | -គណៈបញ្ជាឯកភាពរដ្ឋបាលរាជធានីភ្នំពេញ<br>-អង្គការដៃគូ<br>-លេខាធិការដ្ឋានខេត្តជាប់ព្រំដែន | -សម្របសម្រួល ប្រជុំ សិក្ខាសាលារួមគ្នាជាមួយប្រទេសជិតខាង |
| កិច្ចការកុមារ | -លេខាធិការដ្ឋានខេត្ត | -ជួយផ្តល់សេវាកម្មដល់កុមាររងគ្រោះ<br>ដោយសារអំពើជួញដូរមនុស្ស<br>-អប់រំ, បណ្តុះបណ្តាលវិជ្ជាជីវៈដល់កុមាររងគ្រោះ<br>-ផ្សព្វផ្សាយច្បាប់ពី TIP ដល់គ្រួសារ ដើម្បីអប់រំដល់សិស្ស និងកុមារឲ្យយល់ ដឹងពីការរំលោភបំពានផ្លូវភេទលើកុមារ និងអំពើហឹង្សាក្នុងគ្រួសារ ។ |
| ការងារទេសន្តរប្រវេសន៍ | សហការជាមួយក្រសួង ស្ថាប័ន អង្គការ និងបញ្ច្រាបក្នុងវេទិកា ឃុំ សង្កាត់ | ផ្សព្វផ្សាយការយល់ដឹងអំពីកលល្បិចជនល្មើស ភាពរងគ្រោះរបស់ជនចំណាកស្រុកខុសច្បាប់ តាមមេខ្យល់ តាមប្រព័ន្ធមិនស្របច្បាប់ ។ |

២-.<u>គោលការណ៍ណែនាំ៖</u>

**- ខេត្តមានគ្រោងថវិកាសម្រាប់ធ្វើសកម្មភាព៖**

សរុបចំនួន ១០ខេត្ត ក្នុងនោះមាន៖

សៀមរាប, ព្រះវិហារ, កំពង់ធំ, កណ្តាល, កំពង់ឆ្នាំង, ស្វាយរៀង, បន្ទាយមានជ័យ, បាត់ដំបង, តាកែវ, និងឧត្តរមានជ័យ ។

**-ខេត្តមិនទាន់ស្នើថវិកាបានសម្រាប់ធ្វើសកម្មភាព៖**

សរុបចំនួន ១៤ ខេត្ត ក្នុងនោះមាន៖

រាជធានីភ្នំពេញ, កំពង់ស្ពឺ, កោះកុង, មណ្ឌលគីរី, ក្រចេះ, ស្ទឹងត្រែង, កំពត, កែប, កំពង់ចាម, ព្រៃវែង, ពោធិ៍សាត់, ប៉ៃលិន, ព្រះសីហនុ, និងខេត្តរតនៈគីរី ។

៣-.<u>ការប្រមូលរបាយការណ៍៖</u>

**ទទួលបានពីមន្ទីរ-អង្គភាពជុំវិញរាជធានី-ខេត្ត៖**

- រដ្ឋបាលមូលដ្ឋានខណ្ឌ ស្រុក
- មន្ទីរជុំវិញរាជធានី-ខេត្ត

- សមាជិកលេខាធិការដ្ឋាន
- តាមរយៈទូរស័ព្ទ ។

៤-.**<u>អនុវត្តតាមផែនការបានទៀងទាត់៖</u>**

មានចំនួន**១៦ខេត្ត**មាន៖

កំពង់ស្ពឺ, កោះកុង, ព្រះសីហនុ, ឧត្តរមានជ័យ, សៀមរាប, ព្រះវិហារ, កំពង់ធំ, កំពត, កែប, តាកែវ, កណ្តាល, កំពង់ឆ្នាំង, ស្វាយរៀង, បន្ទាយមានជ័យ, ពោធិ៍សាត់, បាត់ដំបង ។

-.**<u> មិនបានអនុវត្តទៀងទាត់តាមផែនការ៖</u>**

មានចំនួន**០៨រាជធានី-ខេត្ត** ក្នុងនេះមាន

រាជធានីភ្នំពេញ, មណ្ឌលគីរី, ក្រចេះ, ស្ទឹងត្រែង, កំពង់ចាម, ព្រៃវែង, ប៉ៃលិន, រតនៈគីរី ។

៥-.**<u> ភាពងាយស្រួល៖</u>**

- ខេត្តភាគច្រើនមានការបង្កលក្ខណៈងាយស្រួលពីគណៈអភិបាលខេត្ត
- មានផែនការសកម្មភាពជាតិ និងផែនការខេត្តសម្រាប់អនុវត្ត
- មានមូលដ្ឋានគតិយុត្តច្បាស់លាស់
- កិច្ចសហការបង្ក្រាបបទល្មើសបានល្អ
- រាល់កិច្ចប្រជុំមានការចូលរួមពីបណ្តាអង្គភាពពាក់ព័ន្ធបានទៀងទាត់
- មានការចូលរួមពីអាជ្ញាធរគ្រប់ថ្នាក់ និងអង្គការមិនមែនរដ្ឋាភិបាលក្នុងការអនុវត្តភារកិច្ច និងផ្តល់ពត៌មាន ។

**<u>៦. ភាពប្រឈម៖</u>**

- ខេត្តមួយចំនួន មិនទាន់យកចិត្តទុកដាក់ចំពោះការបង្កើតគណៈកម្មាធិការដឹកនាំប.ជ.រ.ព.ភ និងលេខាធិការដ្ឋានខេត្តឲ្យបានជាក់លាក់ និងមិនទាន់មានមន្ត្រីប្រចាំការធ្វើការងារ និងមិនមានការិយាល័យច្បាស់លាស់នៅឡើយ
- ធនធានមនុស្ស មានកំរិតទាំងការយល់ដឹង ទាំងការទទួលខុសត្រូវ
- កិច្ចប្រជុំមិនទៀងទាត់
- បញ្ជូនសមាសភាពជំនួសមកចូលរួមប្រជុំ ឬវគ្គបណ្តុះបណ្តាល មិនមានសិទ្ធិសម្រេច
- ការផ្លាស់ប្តូរតួនាទីមន្ត្រីក្នុងអង្គភាព ពាក់ព័ន្ធដល់សមាសភាពក្នុងលេខាធិការដ្ឋានខេត្ត
- សមាជិកលេខាធិការដ្ឋាន មិនបានយល់ដឹងខ្ពស់អំពីតួនាទី និងភារកិច្ចរបស់ខ្លួន
- លេខាធិការដ្ឋានខេត្ត ឬមន្ទីរខ្លះមិនទាន់ចេះសហការជាមួយ NGOs ដើម្បីប្រើប្រាស់កម្លាំងសរុប
- ខេត្តខ្លះមានភូមិសាស្ត្រស្មុគ្រស្មាញ ក្តាប់សភាពការណ៍ពលករឆ្លងដែនមិនបានច្បាស់
- របាយការណ៍ប្រមូលមិនបានទៀងទាត់ និងផ្ញើមកលេខាធិការដ្ឋានជាតិក៏មិនទៀងទាត់
- ខ្វះថវិកាចុះបង្ក្រាបបទល្មើស
- ការផ្ទេរបទល្មើសរំលោភទៅឲ្យការិយាល័យព្រហ្មទណ្ឌ នាំឲ្យដាច់ព័ត៌មាន មិនមានភាពរលូនក្នុងការងារ ប.ជ.រ.ព.ភ
- ជនល្មើសប្រើរូបភាពជាអ្នកទេសចរណ៍ ដើម្បីប្រព្រឹត្តបទល្មើស
- ក្រុមហ៊ុនជ្រើសរើសពលករមិនបានទាក់ទងជាមួយអាជ្ញាធរមូលដ្ឋាន
- ការផ្សព្វផ្សាយអំពីការងារ ប.ជ.រ.ព.ភ មិនបានធ្វើដល់ទីជនបទដាច់ស្រយាល
- អាជ្ញាប័ណ្ណរបស់មន្ទីរទេសចរណ៍ខេត្តមិនផ្តល់ភាពអនុគ្រោះដល់មន្ត្រីអនុវត្តច្បាប់ក្នុងការត្រួតពិនិត្យបទល្មើស ។

- ប្រជាពលរដ្ឋមានការយល់ដឹងទាប ចំពោះកិច្ចសហការជាមួយអាជ្ញាធរមូលដ្ឋាន
- ខ្វះមេធាវីសម្រាប់ជាជំនួយផ្លូវច្បាប់ដល់ជនរងគ្រោះ ក្នុងអំពើជួញដូរមនុស្ស ។

### ៧-.សំណូមពរដែលបានស្នើឡើងដោយរាជធានី ខេត្តក្នុងពេលចុះត្រួតពិនិត្យះ

- សុំឲ្យមានកញ្ចប់ថវិកាដាច់ដោយឡែកមួយ ដែលទំលាក់ចេញពីលេខាធិការដ្ឋានថ្នាក់ជាតិ សម្រាប់យកមកអនុវត្តការងារ ប.ជ.រ.ព.ភ ខេត្ត
- គួរមានបណ្តាញគណៈកម្មាធិការ ប.ជ.រ.ព.ភ ដល់ថ្នាក់ស្រុក និងឃុំ ដែលជាអ្នកអនុវត្តផ្ទាល់ជាមួយប្រជាពលរដ្ឋ ។
- សំណូមពរឲ្យមានការផ្សព្វផ្សាយដល់ពលករចំណាកស្រុកឲ្យបានទូលំទូលាយ
- ស្នើសុំបណ្តុះបណ្តាលអំពីច្បាប់ និងជំនាញដល់: មន្ត្រីអនុវត្តច្បាប់ សមាជិក និង មន្ត្រីលេខាធិការដ្ឋាននៅថ្នាក់ក្រោមជាតិ
- សុំបញ្ចូល បទល្មើសរំលោភ មកក្រោមការិយាល័យប្រឆាំងការជួញដូរមនុស្ស ជាអ្នកអនុវត្តវិញ
- ស្នើដោះស្រាយអំពីបញ្ហាទេសន្តរប្រវេសន៍ ឲ្យមានឯកសារទទួលស្គាល់ជាផ្លូវការ (ថៃ-កម្ពុជា) ។
- សុំផ្តល់សម្ភារៈសម្រាប់បំរើការងារនៅថ្នាក់ក្រោមជាតិ
- ស្នើពិនិត្យ និងបំពេញបន្ថែមឡើងវិញលើចំណុចចន្លោះប្រហោងនៃបទដ្ឋានគតិយុត្ត ដែលកំពុងស្ថិតនៅជាធរមាន
- ក្រុមការងារតាមដានត្រួតពិនិត្យថ្នាក់ជាតិ សូមឲ្យចុះមកពិនិត្យតាមខេត្តយ៉ាងតិចមួយដងក្នុងមួយឆ្នាំ ។
- ជួយជម្រុញឲ្យមានការផលិតIEC ថ្មីៗបន្ថែមទៀត ។
- ជម្រុញឲ្យមានការចូលរួមពីអង្គការដៃគូ ដើម្បីធ្វើសកម្មភាព ប.ជ.រ.ព.ភ រួមគ្នា
- ស្នើឲ្យមានទស្សនកិច្ចផ្លាស់ប្តូរបទពិសោធន៍រវាងខេត្តនិងខេត្តឲ្យមានការរីកចំរើន
- សូមបន្តតាមដាន និងដោះស្រាយករណីពលករទៅធ្វើការនៅប្រទេសម៉ាឡេស៊ី
- សុំបង្កើតមណ្ឌលអប់រំ បណ្តុះបណ្តាលសម្រាប់ជនរងគ្រោះ
- សូមជម្រុញឲ្យក្រុមហ៊ុន ដែលមានអាជ្ញាប័ណ្ណជ្រើសរើសពលករធ្វើការទំនាក់ទំនង និង រាយការណ៍ដល់អាជ្ញាធរ និងសមត្ថកិច្ចមូលដ្ឋានឲ្យបានដឹងពីពត៌មាន និងទិន្នន័យពលករដែលខ្លួនជ្រើសរើសក្នុងភូមិសាស្ត្រនៃសមត្ថកិច្ចខេត្តនីមួយៗ ។

### ៨-.សន្និដ្ឋានលើលទ្ធផលនៃការតាមដានត្រួតពិនិត្យ ថ្នាក់ក្រោមជាតិះ

ផ្អែកលើលទ្ធផលដែលទទួលបានក្នុងអំឡុងពេលនៃការចុះតាមដានត្រួតពិនិត្យ អាចធ្វើការសន្និដ្ឋានបានថា ថ្នាក់ដឹកនាំគណៈកម្មាធិការដឹកនាំ ប.ជ.រ.ព.ភ រាជធានី-ខេត្ត ស្ទើរតែទាំងអស់បានខិតខំប្រឹងប្រែងយកចិត្តទុកដាក់បំពេញភារកិច្ចរបស់ខ្លួន ។ តែទោះបីជាយ៉ាងនេះក្តី ក៏ទាមទារឲ្យមានការយកចិត្តទុកដាក់បន្ថែមទៀត ពីលេខាធិការដ្ឋានថ្នាក់ជាតិ ជាពិសេសៈ

- ការពង្រឹងរចនាសម្ព័ន្ធនៃយន្តការគ្រប់ថ្នាក់ ដោយធានាឲ្យមានលិខិតបទដ្ឋានគតិយុត្តិសម្រាប់ការចាត់តាំងរៀបចំរចនាសម្ព័ន្ធ ទាំងគណៈកម្មាធិការ ទាំងលេខាធិការដ្ឋាន មានមន្ត្រីទទួលខុសត្រូវជាក់លាក់ មានទីកន្លែងសម្រាប់អនុវត្តការងារជាប្រចាំ មានការគាំទ្រសម្ភារៈ ថវិកាសម្រាប់ដំណើរការកិច្ចប្រជុំឲ្យបានទៀងទាត់ មានការតាមដានត្រួតពិនិត្យ មានរបាយការណ៍ការងារ និងលទ្ធផលដែលត្រូវផ្ញើមកថ្នាក់ជាតិឲ្យបានទៀងទាត់ ដើម្បីបូកសរុប សន្និដ្ឋានវាយតម្លៃ និងលើកទិសដៅឲ្យបានត្រឹមត្រូវ ។

• ការពង្រឹងសមត្ថភាពបច្ចេកទេសការងារ និងការយល់ដឹងឲ្យបានទូលំទូលាយដល់មន្ត្រីអនុវត្ត និងលេខាធិការដ្ឋានទាំងមូលដើម្បីធានាប្រសិទ្ធភាពនៃការដឹកនាំ និងធ្វើឲ្យសម្រេចទិសដៅនៃការប្រឆាំងការជួញដូរមនុស្ស ។

លទ្ធផលនៃការតាមដានត្រួតពិនិត្យខាងលើនេះក៏បានឆ្លុះបញ្ចាំងលើលទ្ធផល ការវាយតម្លៃ និងទិសដៅរួមរបស់គណៈកម្មាធិការជាតិផងដែរ ។

## V-**ការសន្និដ្ឋាន វាយតម្លៃលើលទ្ធផលសកម្មភាពឆ្នាំ ២០១២** :

ក្នុងឆ្នាំ២០១២កន្លងទៅនេះ គណៈកម្មាធិការជាតិដឹកនាំ ប.ជ.រ.ព.ភ បានធ្វើឲ្យសម្រេចនូវសកម្មភាពជាច្រើនគួរកត់សម្គាល់ ដែលកំណត់បាននូវចំណុចខ្លាំង ភាពប្រឈម និងចំណុច សេសសល់មួយចំនួនដូចខាងក្រោម ៖

***ក. ចំណុចខ្លាំង:***

1. រាជរដ្ឋាភិបាលកម្ពុជាមានការប្តេជ្ញាចិត្តខ្ពស់ ប្រឆាំងអំពើជួញដូរ និងអំពើកេងប្រវ័ញ្ចលើមនុស្ស ដោយចាត់ទុកថាជាបទឧក្រិដ្ឋ និងបានកសាងច្បាប់ គោលនយោបាយ បទដ្ឋានគតិយុត្តិពាក់ព័ន្ធទាំងឡាយ ព្រមទាំងបង្កើតជាយន្តការថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិដើម្បីអនុវត្តច្បាប់ និងគោលនយោបាយទាំងនោះ យ៉ាងសកម្មនៅគ្រប់កម្រិត។
2. រាជរដ្ឋាភិបាលកម្ពុជា ដែលមានលេខាធិការដ្ឋានគណៈកម្មាធិការជាតិ ប.ជ.រ.ព.ភ ជាសេនាធិការ បានបំពេញតួនាទីជាយន្តការជាតិប្រឆាំង និងបង្ក្រាបនូវអំពើជួញដូរមនុស្សនៅក្នុងប្រទេស ក្នុងអនុតំបន់ ក្នុងតំបន់ និងជាអន្តរជាតិ ដោយមានផែនការសកម្មភាពជាតិ និងយុទ្ធសាស្ត្រច្បាស់លាស់ សម្រាប់ឆ្នាំ២០១១-២០១៣ និងបន្តទៀត ។
3. មានការសិក្សាស្រាវជ្រាវច្បាស់លាស់អំពីទំនោរ ភាពប្រែប្រួល នៃបទល្មើសជួញដូរមនុស្ស នៅកម្ពុជា ដែលបាន និងកំពុងជ្រកក្រោមរូបភាពទេសន្តរប្រវេសន៍ ដើម្បីជាមូលដ្ឋានក្នុងការកំណត់ទិសដៅសកម្មភាពសម្រាប់ជំហានបន្ត ។
4. គណៈកម្មាធិការជាតិដឹកនាំ ប.ជ.រ.ព.ភ បានសម្រេចបង្កើតក្រុមការងារទេសន្តរប្រវេសន៍បន្ថែមទៀតក្នុងលេខាធិការដ្ឋានជាតិ ដើម្បីឆ្លើយតប និងសម្របសម្រួលដោះស្រាយបញ្ហាដែលកើតមានជុំវិញចំណាកស្រុក ឬទេសន្តរប្រវេសន៍ការងារ ដើម្បីលើកកម្ពស់សុវត្ថិភាព ការគោរពសិទ្ធិ និងផលប្រយោជន៍របស់ពលករទេសន្តរប្រវេសន៍កម្ពុជា ។
5. បានសហការគ្នាក្នុងក្រុមការងារទេសន្តរប្រវេសន៍ដែលជាក្រុមការងារអន្តរវិស័យ ចុះសិក្សា និងវាយតម្លៃចំណុចខ្លាំង និងចំណុចខ្វះខាត ឬភាពប្រឈមរបស់លេខាធិការដ្ឋានជាតិ និងថ្នាក់ក្រោមជាតិ ដើម្បីដាក់ទិសដៅកែលំអ និងពង្រឹង ។
6. បានប្រមូលសរុបដកពិសោធន៍ការងារជាបន្តបន្ទាប់ ទាំងការងារទេសន្តរប្រវេសន៍ (ក្នុង និងក្រៅ ប្រទេស) ការងារតាមដានត្រួតពិនិត្យ និងបានផ្តល់ពត៌មានត្រឡប់ឲ្យលេខាធិការដ្ឋានថ្នាក់ក្រោមជាតិ បានដកពិសោធន៍ និងយកចិត្តទុកដាក់ រៀបចំយុទ្ធសាស្ត្រកែលំអការដឹកនាំ និងអនុវត្ត ។
7. បានទទួលការគាំទ្រធនធាន និងកិច្ចសហការកាន់តែច្រើន ពីអង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិ លើការផ្តល់ពត៌មាន ការអនុវត្តសកម្មភាព និងការពិគ្រោះយោបល់ដើម្បីរួមគ្នាប្រឆាំងការជួញដូរមនុស្ស ។

8. មានកិច្ចសហការល្អជាមួយអង្គការដៃគូដែលមានជំនាញបច្ចេកទេស ក្នុងការពង្រឹងសមត្ថភាពមន្ត្រីអនុវត្តច្បាប់ និងអ្នកពាក់ព័ន្ធ ដោយជម្រុញការរៀបចំឯកសារសម្រាប់បណ្តុះបណ្តាល (មន្ត្រីជួរមុខ និងមន្ត្រីឯកទេស) និងធ្វើការបណ្តុះបណ្តាលសមត្ថកិច្ច ព្រះរាជអាជ្ញា ចៅក្រម និងអ្នក ពាក់ព័ន្ធបានមួយចំនួនបន្ថែមទៀត ។
9. ការបំពេញបន្ថែម ចំណុចខ្វះចន្លោះក្នុងបទដ្ឋានច្បាប់ និងជម្រុញឲ្យមានកំណត់ពន្យល់អំពីច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ គោលនយោបាយការពារសាក្សីនិងជនរងគ្រោះ ការវិភាគទៅលើរឿងក្តី ការគ្រប់គ្រងមណ្ឌលកំសាន្តទេសចរណ៍សម្រាប់មនុស្សពេញវ័យ ការធ្វើប្រកាសរួមពាក់ព័ន្ធអធិការកិច្ចទេសចរណ៍ និងនគរបាល ទេសចរណ៍ ....ជាដើម បានជួយដល់ការអនុវត្តច្បាប់ ឲ្យរឹតតែមានប្រសិទ្ធិភាពមួយកម្រិតទៀត ។
10. ការអប់រំផ្សព្វផ្សាយគ្រប់រូបភាពដល់ប្រជាពលរដ្ឋ អំពីច្បាប់ បទដ្ឋានគតិយុត្តិ ឧបាយកលជន ល្មើស ការធ្វើចំណាកស្រុកដោយសុវត្ថិភាព កិច្ចការពារជនរងគ្រោះបានផ្តល់ការយល់ដឹងដល់ប្រជាពលរដ្ឋគ្រប់មជ្ឈដ្ឋានដោយផ្ទាល់ បានប្រមាណជាជាងកន្លះលាននាក់ និងបានដកហូតពលកម្មកុមារពីទម្រង់ ធ្ងន់ធ្ងររាប់ពាន់នាក់ថែមទៀត ។
11. ការអនុវត្តគោលនយោបាយភូមិឃុំមានសុវត្ថិភាព គឺជាគន្លឹះក្នុងការប្រមូលកម្លាំងមូលដ្ឋានឲ្យធ្វើសកម្មភាពព្រមគ្នាឆ្លើយតបទៅនឹងបទល្មើស រួមទាំងបទល្មើសជួញដូរមនុស្សផងដែរ នៅថ្នាក់មូលដ្ឋាន ។
12. ការអនុវត្តច្បាប់របស់កម្លាំងសមត្ថកិច្ច និងតុលាការ ក្នុងការបង្ក្រាបបទល្មើសពាក់ព័ន្ធអំពើជួញដូរមនុស្ស ការជួយដល់ជនរងគ្រោះ និងការផ្តន្ទាទោសជនល្មើស មានភាពជឿនលឿនល្អប្រសើរ ។
13. កិច្ចសហប្រតិបត្តិការអន្តរជាតិកាន់តែល្អប្រសើរ និងបានជម្រុញឲ្យមានការចុះហត្ថលេខាលើសេចក្តីកែសម្រួលកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលកម្ពុជា និងរដ្ឋាភិបាលសាធារណរដ្ឋសង្គមនិយមវៀតណាមស្តីពីកិច្ចសហប្រតិបត្តិការប្រឆាំងការជួញដូរមនុស្ស ការឈានទៅពិនិត្យខ្លឹមសារអនុស្សរណៈនៃការយោគយល់គ្នារវាង (កម្ពុជា-ម៉ាឡេស៊ី) និងត្រៀមពិនិត្យកែសម្រួលនិងបំពេញបន្ថែមលើអនុស្សរណៈយោគយល់គ្នា រវាង ព្រះរាជាណាចក្រកម្ពុជា និងថៃ ។

***<u>ខ. ចំណុចសេសសល់ និងភាពប្រឈម:</u>***

ទន្ទឹមនឹងចំណុចខ្លាំងដូចបានរៀបរាប់ខាងលើ ក៏នៅមានចំណុចសេសសល់ និងភាពប្រឈមមួយចំនួន ដែលយើងពិនិត្យឃើញ និងត្រូវបំពេញបន្ថែមមានជាអាទិ៍ ៖

1. បញ្ហាក្នុងទេសន្តរប្រវេសន៍ការងារ ទាំងតាមប្រព័ន្ធស្របច្បាប់ ទាំងមិនតាមប្រព័ន្ធរៀបរយតាមច្បាប់ទៅក្រៅប្រទេស នៅតែជាភាពប្រឈមដែលត្រូវដោះស្រាយឲ្យបានសមស្រប និងត្រូវមាននីតិវិធីក្នុងការគ្រប់គ្រងឲ្យបានល្អប្រសើរ...។
2. មិនទាន់កំណត់ច្បាស់លាស់អំពីស្ថាប័នទទួលខុសត្រូវលើការកំណត់អត្តសញ្ញាណជនរងគ្រោះដោយការជួញដូរមនុស្ស នាំឲ្យមានភាពប្រឈមក្នុងប្រតិបត្តិការវែកមុខរកមុខសញ្ញាជួញដូរមនុស្សឆ្លងដែន។
3. ស្ថាប័នពាក់ព័ន្ធ មិនទាន់បានយល់ដឹង និងអនុវត្តនីតិវិធីជំនួយផ្នែកច្បាប់ឲ្យគ្នាទៅវិញទៅមក រវាងប្រទេសក្នុងសហគមន៍អាស៊ាន លើរឿងក្តីព្រហ្មទណ្ឌ ដើម្បីពង្រឹងសហប្រតិបត្តិការក្នុងការជួយជនរងគ្រោះនៅឡើយ ។

4. ការឆ្លើយតបផ្នែកយុត្តិធម៌ព្រហ្មទណ្ឌដែលពាក់ព័ន្ធនឹងអំពើជួញដូរមនុស្សតាមគោលការណ៍ណែនាំរបស់អាស៊ាននៅមានកម្រិត ដែលចាំបាច់ត្រូវពង្រឹងក្របខណ្ឌច្បាប់ ឯកទេសកម្ម កិច្ចសហប្រតិបត្តិការ ការគ្រប់គ្រងជនរងគ្រោះដែលត្រូវធ្វើជាសាក្សីក្នុងការផ្ដល់ភស្តុតាង ។
5. ជាទូទៅកិច្ចសហប្រតិបត្តិការអន្តរជាតិពាក់ព័ន្ធនឹងអំពើជួញដូរមនុស្ស លើផ្នែកប្រតិបត្តិការ ផ្នែកច្បាប់ ឬតុលាការ នៅមានកំរិត។
6. មិនទាន់មានច្បាប់ស្ដីអំពី អំពើរត់ពន្ធមនុស្ស និងបទដ្ឋានគតិយុត្តិពាក់ព័ន្ធមួយចំនួន សម្រាប់ជាវិធានការច្បាប់ចំពោះបទល្មើសពាក់ព័ន្ធអំពើរត់ពន្ធមនុស្ស ។
7. មិនទាន់មាននីតិវិធីដើម្បីបានផ្ដល់នីតិសម្បទា ដល់មណ្ឌលដែលជួយគាំទ្រដល់ជនរងគ្រោះដោយអំពើជួញដូរមនុស្សនៅឡើយ ។
8. មិនមានទិន្នន័យពាក់ព័ន្ធនឹងកិច្ចការផ្ដន្ទាទោស ទៀងទាត់ប្រចាំខែ ត្រីមាស ឆមាស ឆ្នាំ ដែលជាឧបសគ្គក្នុងការបូកសរុប និងវាយតម្លៃ និងជះឥទ្ធិពលដល់ប្រសិទ្ធភាពនៃកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលក្នុងការប្រឆាំងការជួញដូរមនុស្ស ។
9. មន្ទីរស្ថាប័នពាក់ព័ន្ធក្នុងក្រុមការងារ និងលេខាធិការដ្ឋានថ្នាក់ក្រោមជាតិមួយចំនួន នៅយឺតយ៉ាវក្នុងការធ្វើរបាយការណ៍ និងបញ្ជូនមកលេខាធិការដ្ឋានជាតិ ឲ្យបានទៀងទាត់និងទាន់ពេលវេលា ដើម្បីឆ្លុះបញ្ចាំងអំពីលទ្ធផល និងស្នាដៃដែលបានអនុវត្ត ។
10. ក្រុមការងារទាំង០៧ របស់លេខាធិការដ្ឋានជាតិ និងលេខាធិការដ្ឋាន ថ្នាក់ក្រោមជាតិមួយចំនួន នៅមានភាពប្រឈមលើបញ្ហាធនធានមនុស្ស ថវិកា សម្ភារៈ និងមធ្យោបាយ សម្រាប់ការអនុវត្តភារកិច្ចឲ្យមានប្រសិទ្ធភាព ។

***គ. <u>សន្និដ្ឋាន វាយតម្លៃ:</u>***

ពិនិត្យលើចំណុចខ្លាំង ចំណុចសេសសល់និងចំណុចប្រឈម ដែលបានឆ្លុះបញ្ចាំង និងរៀបរាប់ខាងលើនេះ យើងអាចទាញជាការសន្និដ្ឋាន និងវាយតម្លៃបានដូចខាងក្រោម ៖

- ➢ មានផែនការសកម្មភាពជាតិនិងផែនការរាជធានីខេត្ត ស្ដីពីការបង្ក្រាបការជួញដូរមនុស្ស ការរត់ពន្ធ ការធ្វើអាជីវកម្មពលកម្មលើមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទលើស្ត្រីនិងកុមារ គឺជាផែនទីបង្ហាញផ្លូវយ៉ាងសំខាន់សម្រាប់ឲ្យគ្រប់ស្ថាប័នពាក់ព័ន្ធអនុវត្តស្របតាមស្ថានភាព និងភូមិសាស្ត្រជាក់ស្ដែង ។
- ➢ វិធានការច្បាប់ និងវិធានការជំនាញ គឺជាអាវុធដ៏មុតស្រួចសម្រាប់បង្ក្រាបបទល្មើស និងផ្ដន្ទាទោសជនល្មើស ប៉ុន្តែមិនមានន័យថាអាចគ្រប់ដណ្ដប់ទៅលើវិសាលភាពនៃគ្រប់ទម្រង់បទល្មើសមិនឲ្យកើតឡើងនោះទេ ។ ជាក់ស្ដែងក្នុងឆ្នាំកន្លងទៅ សភាពការណ៍បទល្មើសថយចុះ សកម្មភាពបង្ក្រាបបទល្មើស និងការផ្ដន្ទាទោសបានប្រសើរឡើងជាងឆ្នាំមុន តែបទល្មើសជួញដូរមនុស្សនៅតែកើតមាន តាមទម្រង់ផ្សេងៗ ។ ចំណុចសំខាន់គឺធ្វើយ៉ាងណាកុំឲ្យប្រជាពលរដ្ឋរងគ្រោះដោយអំពើជួញដូរមនុស្ស ។
- ➢ វិធានការដែលប្រសើរ គឺបង្កើនប្រសិទ្ធភាពក្នុងកិច្ចសហប្រតិបត្តិការពីគ្រប់ស្ថាប័ន និងអង្គភាពពាក់ព័ន្ធ គ្រប់កម្រិត និងទូលំទូលាយគ្រប់វិស័យក្នុងប្រទេស និងជាមួយប្រទេសពាក់

NATIONAL COMMITTEE TO LEAD S.T.S.L.S.

ព័ន្ធ សម្រាប់ជាយុទ្ធសាស្ត្រប្រើប្រាស់កម្លាំងសរុប ធនធានសរុប ដើម្បីប្រសិទ្ធភាព ក្នុងការលុបបំបាត់អំពើជួញដូរមនុស្ស ការរត់ពន្ធ និងការធ្វើអាជីវកម្មពលកម្ម និងផ្លូវភេទ ។

## VI- ទិសដៅសម្រាប់អនុវត្តឆ្នាំ២០១៣ :

១- ផ្សព្វផ្សាយរបាយការណ៍បូកសរុបការងារបង្ការ-ទប់ស្កាត់ និងបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ របស់គណ:កម្មាធិការជាតិប.ជ.រ.ព.ភ ឆ្នាំ២០១២ និងទិសដៅឆ្នាំ២០១៣ ។

២- ជម្រុញការអនុវត្តផែនការសកម្មភាព របស់ក្រុមការងារទាំង០៧របស់លេខាធិការដ្ឋាន ជាតិ និងរបស់លេខាធិការដ្ឋានរាជធានី-ខេត្តសម្រាប់ឆ្នាំ២០១២-២០១៣ **និងជម្រុញស្នើសុំឲ្យមានកញ្ចប់ថវិកាសម្រាប់ធ្វើសកម្មភាព ដោយមិនបាច់រង់ចាំជំនួយពីខាងក្រៅដែលមានទំនោរកាន់តែកាត់បន្ថយទៅ** ។

៣- យកចិត្តទុកដាក់អនុវត្ត កែលំអ និងពង្រឹងបន្ថែមរាល់ចំណុចខ្វះខាតដែលបានរកឃើញក្នុងឆ្នាំ២០១២ តាមរយ:ការសិក្សាស្វែងយល់ ការតាមដានត្រួតពិនិត្យ ទាំងការផ្តល់អនុសាសន៍របស់ក្រសួងការបរទេសសហរដ្ឋអាមេរិក ។

៤- ពង្រឹងរចនាសម្ព័ន្ធនៃយន្តការគ្រប់ថ្នាក់ ការដឹកនាំ របៀបរបបការងារ ការយល់ដឹង និងសមត្ថភាពមន្ត្រីទទួលខុសត្រូវក្នុងលេខាធិការដ្ឋានថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដើម្បីធានាប្រសិទ្ធិភាពនៃការអនុវត្ត ។

៥- រៀបចំសិក្ខាសាលាថ្នាក់ជាតិ ស្តីពីការគ្រប់គ្រងលំហូរពលករទេសន្តរប្រវេសន៍នៅកម្ពុជា ដើម្បីកំណត់យុទ្ធសាស្ត្រគ្រប់គ្រងលំហូរពលករទេសន្តរប្រវេសន៍ និងការរក្សាកម្លាំងពលកម្មអភិវឌ្ឍន៍ជាតិ និងកាត់បន្ថយភាពរងគ្រោះដោយការកេងប្រវ័ញ្ចគ្រប់រូបភាព ។

៦- បន្តជម្រុញដោះស្រាយបញ្ហាទេសន្តរប្រវេសន៍ការងារ ដែលកំពុងកើតមានក្នុងទម្រង់ស្របច្បាប់ និងមិនស្របច្បាប់ និងពង្រឹងការតាមដានត្រួតពិនិត្យទីភ្នាក់ងារជ្រើសរើសឯកជនបង្កើនការទទួលខុសត្រូវ ចំពោះសុវត្ថិភាព សិទ្ធិ និងផលប្រយោជន៍ស្របច្បាប់របស់ពលករ ។

៧. ពិនិត្យពិភាក្សាឲ្យបានល្អិតល្អន់ លើរាល់ខ្លឹមសារនៃអនុស្សរណ: កិច្ចព្រមព្រៀងទ្វេភាគី ពហុភាគីក្នុងគោលដៅប្រឆាំងការជួញដូរមនុស្ស និងការពារប្រជាពលរដ្ឋពីអំពើជួញដូរ ការរត់ពន្ធ និងការធ្វើកេងប្រវ័ញ្ចគ្រប់រូបភាព មុននឹងសម្រេចចុះហត្ថលេខា ក្នុងនោះក៏មានអនុស្សរណ: បញ្ជូនពលការិនីជាជំនួយការមេផ្ទះទៅប្រទេសម៉ាលេស៊ីជាថ្មីទៀតផងដែរ។

៨- ពង្រឹងកិច្ចសហប្រតិបត្តិការឲ្យកាន់តែល្អប្រសើរ គ្រប់ផ្នែក គ្រប់វិស័យ នៅគ្រប់កម្រិត ទាំងក្នុងរាជរដ្ឋាភិបាល អង្គការដៃគូមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិ ទីភ្នាក់ងារអង្គការសហប្រជាជាតិ ដែលមានគោលដៅរួមគ្នា និងប្រទេសពាក់ព័ន្ធ ដើម្បីកំណត់យុទ្ធសាស្ត្រជាក់លាក់ និងអនុវត្តឲ្យមានប្រសិទ្ធិភាព ក្នុងការបង្ការ ទប់ស្កាត់ ការការពារជនរងគ្រោះ និងការផ្តន្ទាទោសជនល្មើសនៃអំពើជួញដូរមនុស្ស ការជួញដូរពលកម្ម និងផ្លូវភេទ ។

៩-ក្រសួង ស្ថាប័នពាក់ព័ន្ធ យកចិត្តទុកដាក់សហការជម្រុញផ្សព្វផ្សាយ អប់រំ ប្រជាជនគោលដៅមុខសញ្ញា ដើម្បីលើកកម្ពស់យល់ដឹងជាសាកលអំពីបញ្ហាជួញដូរមនុស្ស និងបញ្ហាទេសន្តរប្រវេសន៍ការងារ និងដើម្បីបង្ការ-ទប់ស្កាត់ភាពរងគ្រោះដោយអំពើជួញដូរនិងការកេងប្រវ័ញ្ចគ្រប់រូបភាព ។

១០- បន្តចុះតាមដានត្រួតពិនិត្យ គាំទ្រ និងពង្រឹងបន្ថែមទៀតលើសកម្មភាពក្រុមការងារទាំង៧ និងលេខាធិការដ្ឋានគ្រប់ថ្នាក់ ដើម្បីជាសេនាធិការដ៏រឹងមាំក្នុងការដឹកនាំ និងអនុវត្តឲ្យបានជោគជ័យនូវយុទ្ធសាស្ត្រ និងផែនការសកម្មភាពជាតិ ។

១១-បន្តយកចិត្តទុកដាក់លើការបណ្តុះបណ្តាល ពង្រឹងសមត្ថភាពមន្ត្រីអនុវត្តច្បាប់គ្រប់ផ្នែក គ្រប់កម្រិត និងអ្នកពាក់ព័ន្ធ អំពីច្បាប់ស្តីពីការបង្រ្កាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ច្បាប់ពាក់ព័ន្ធ និងជំនាញឯកទេសក្នុងការបង្ក្រាប ការចោទប្រកាន់ និងការផ្តន្ទាទោសជនល្មើសជួញដូរមនុស្ស ដើម្បីឲ្យចំណាត់ការកាន់តែសុក្រឹត្យ។

១២-លើកកម្ពស់ការអនុវត្តគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាពឲ្យបានល្អ ទៅថ្នាក់មូលដ្ឋាន សំដៅកៀរគរការចូលរួមពីប្រជាពលរដ្ឋគ្រប់ស្រទាប់ក្នុងសង្គម ឲ្យការបង្ការ-ទប់ស្កាត់បានជាមុន និងបង្រ្កាបបទល្មើសជួញដូរមនុស្ស ដែលអាចកើតមានក្រោមរូបភាពផ្សេងៗ ជាពិសេសជម្រុញផ្សព្វផ្សាយទប់ស្កាត់ជាមុន អំពើបៀតបៀន និងការរំលោភបំពានផ្លូវភេទលើ កុមារក្នុងវិស័យទេសចរណ៍ និងការធ្វើដំណើរ ។

១៣-ពង្រឹងសមត្ថកិច្ចមូលដ្ឋាន សមត្ថកិច្ចការពារព្រំដែន និងសហការឲ្យបានល្អជាមួយសមត្ថកិច្ចប្រទេសជិតខាង យកចិត្តទុកដាក់សហការបង្ការ បង្រ្កាបបទល្មើសជួញដូរមនុស្ស និងការរត់ពន្ធមនុស្សឆ្លងកាត់ ព្រំដែនគោក ព្រំដែនទឹក និងព្រំដែនអាកាស ។

១៤-បន្តជម្រុញការផ្តល់នីតិសម្បទា ឲ្យដល់មណ្ឌលអង្គការដែលជួយគាំទ្រដល់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស ។

១៥- ពង្រឹងកិច្ចសហការទ្វេភាគី និងពហុភាគី ក្នុងអនុតំបន់ ក្នុងតំបន់ និងអន្តរជាតិ ជម្រុញអនុវត្តកិច្ចព្រមព្រៀង និងអនុស្សរណៈនានាឲ្យមានប្រសិទ្ធិភាព ជាពិសេសក្នុងការបង្រ្កាបបទឧក្រិដ្ឋឆ្លងដែនពាក់ព័ន្ធអំពើជួញដូរមនុស្ស ការផ្លាស់ប្តូរព័ត៌មាន កិច្ចសហការបង្រ្កាប និងអនុវត្តនីតិវិធីជំនួយផ្លូវច្បាប់ឲ្យគ្នាទៅវិញទៅមក ។

រាជធានីភ្នំពេញ, ថ្ងៃទី ១៨ ខែ កុម្ភៈ ឆ្នាំ២០១៣

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**ប្រធានគណៈកម្មាធិការជាតិដឹកនាំ ប.ជ.រ.ព.ភ**

NATIONAL COMMITTEE TO LEAD S.T.S.L.S

ស ខេង

**ចម្លងជូន**

-ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
-សមាជិកគណៈកម្មាធិការជាតិដឹកនាំ ប.ជ.រ.ព.ភ
-សមាជិកលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិដឹកនាំ ប.ជ.រ.ព.ភ
-គណៈកម្មាធិការដឹកនាំ និងលេខាធិការដ្ឋានប.ជ.រ.ព.ភ រាជធានី/ខេត្ត
-អង្គការដៃគូអភិវឌ្ឍន៍
"ដើម្បីជូនជ្រាប"
-ឯកសារ-កាលប្បវត្តិ

# ឧបសម្ព័ន្ធ

គណៈកម្មាធិការជាតិដឹកនាំប.ជ.រ.ព.ត

លេខាធិការដ្ឋាន

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# តារាងទិន្នន័យបង្ក្រាបបទល្មើស អំពើជួញដូរមនុស្ស

(គិតពីថ្ងៃទី២៦/១២/២០១១ ដល់ថ្ងៃទី២៥/១២/២០១២) ប្រចាំឆ្នាំ២០១២

| ល.រ | នាយកដ្ឋាន រាជធានី ខេត្ត | បង្ក្រាបសរុប | | | | | | | | មាត្រា០៥ ការនាំយកអនីតិជនដោយមិនស្របច្បាប់ | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | ករណីបង្ក្រាប | ជនរងគ្រោះ | ជនល្មើស | ជនរងគ្រោះ | | | ជនល្មើស | | ករណីបង្ក្រាប | ជនរងគ្រោះ | | | ជនល្មើស | |
| | | | | | -15 | 15-17 | 18 | ប | ស | | -15 | 15-17 | 18 | ប | ស |
| 1 | នាយកដ្ឋាន | 1 | 1 | 1 | 1 | | | 1 | | | | | | | |
| 2 | រាជធានីភ្នំពេញ | 5 | 22 | 6 | 4 | 6 | 12 | 6 | | 2 | 1 | 3 | | 2 | |
| 3 | សៀមរាប | 1 | 5 | 2 | | 1 | 4 | 1 | 1 | | | | | | |
| 4 | បន្ទាយមានជ័យ | 11 | 50 | 16 | 1 | 5 | 44 | 14 | 2 | 1 | | 1 | | 1 | |
| 5 | កណ្តាល | 1 | 10 | 2 | | 1 | 9 | 1 | 1 | | | | | | |
| 6 | បាត់ដំបង | 7 | 82 | 11 | 2 | 16 | 64 | 11 | | | | | | | |
| 7 | ព្រះសីហនុ | 3 | 27 | 3 | 1 | | 26 | 2 | 1 | 1 | 1 | | | 1 | |
| 8 | កំពង់ឆ្នាំង | 2 | 10 | 2 | | | 10 | 1 | 1 | | | | | | |
| 9 | កំពង់ចាម | 3 | 13 | 3 | 2 | 1 | 10 | 2 | 1 | 2 | 1 | 1 | | 2 | |
| 10 | កំពង់ស្ពឺ | 1 | 2 | 2 | | 1 | 1 | | 2 | | | | | | |
| 11 | ព្រះវិហារ | 1 | 1 | 1 | 1 | | | | 1 | | | | | | |
| 12 | កំពត | | | | | | | | | | | | | | |
| 13 | ស្ទឹងត្រែង | | | | | | | | | | | | | | |
| 14 | កែប | | | | | | | | | | | | | | |
| 15 | ក្រចេះ | | | | | | | | | | | | | | |
| 16 | តាកែវ | 1 | 1 | 1 | | 1 | | 1 | | 1 | | 1 | | 1 | |
| 17 | ប៉ៃលិន | 1 | 4 | 3 | | | 4 | 3 | | | | | | | |
| 18 | ពោធិ៍សាត់ | | | | | | | | | | | | | | |
| 19 | ព្រៃវែង | | | | | | | | | | | | | | |
| 20 | ស្វាយរៀង | 4 | 13 | 8 | 10 | | 3 | 5 | 3 | 1 | 2 | | | | 1 |
| 21 | រតនៈគិរី | 1 | 1 | 1 | | 1 | | | 1 | | | | | | |
| 22 | មណ្ឌលគិរី | | | | | | | | | | | | | | |
| 23 | កោះកុង | 2 | 11 | 4 | 1 | 6 | 4 | 4 | | | | | | | |
| 24 | កំពង់ធំ | 3 | 7 | 3 | 1 | 2 | 4 | 3 | | 2 | 1 | 1 | | 2 | |
| 25 | ឧត្តរមានជ័យ | | | | | | | | | | | | | | |
| 26 | PMឆ្លងប្រទេស | 5 | 18 | 6 | 2 | 4 | 12 | 6 | | 1 | | 2 | | 1 | |
| | សរុបរួម | 53 | 278 | 75 | 26 | 45 | 207 | 61 | 14 | 11 | 6 | 9 | | 10 | 1 |

| ល.រ | នាយកដ្ឋាន រាជធានី ខេត្ត | មាត្រា១០ ការនាំចេញដោយមិនស្របច្បាប់ដោយមានគោលដៅ | | | | | | មាត្រា១១ ការនាំយកចេញដោយមិនស្របច្បាប់សម្រាប់នាំឆ្លងដែន | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | ករណីបង្ក្រាប | ជនរងគ្រោះ | | | ជនល្មើស | | ករណីបង្ក្រាប | ជនរងគ្រោះ | | | ជនល្មើស | |
| | | | -15 | 15-17 | 18 | ប | ស | | -15 | 15-17 | 18 | ប | ស |
| 1 | នាយកដ្ឋាន | | | | | | | | | | | | |
| 2 | រាជធានីភ្នំពេញ | | | | | | | 1 | | 1 | 12 | 2 | |
| 3 | សៀមរាប | | | | | | | 1 | | 1 | 4 | 1 | 1 |
| 4 | បន្ទាយមានជ័យ | 1 | | 1 | | 1 | | 9 | 1 | 3 | 44 | 12 | 2 |
| 5 | កណ្តាល | | | | | | | 1 | | 1 | 9 | 1 | 1 |
| 6 | បាត់ដំបង | | | | | | | 7 | 2 | 16 | 64 | 11 | |
| 7 | ព្រះសីហនុ | | | | | | | 1 | | | 18 | 1 | |
| 8 | កំពង់ឆ្នាំង | | | | | | | 2 | | | 10 | 1 | 1 |
| 9 | កំពង់ចាម | | | | | | | 1 | 1 | | 10 | | 1 |
| 10 | កំពង់ស្ពឺ | | | | | | | 1 | | 1 | 1 | | 2 |
| 11 | ព្រះវិហារ | | | | | | | | | | | | |
| 12 | កំពត | | | | | | | | | | | | |
| 13 | ស្ទឹងត្រែង | | | | | | | | | | | | |
| 14 | កែប | | | | | | | | | | | | |
| 15 | ក្រចេះ | | | | | | | | | | | | |
| 16 | តាកែវ | | | | | | | | | | | | |
| 17 | ប៉ៃលិន | | | | | | | 1 | | | 4 | 3 | |
| 18 | ពោធិ៍សាត់ | | | | | | | | | | | | |
| 19 | ព្រៃវែង | | | | | | | | | | | | |
| 20 | ស្វាយរៀង | 1 | 8 | | 1 | 3 | | 2 | | | 2 | 2 | 2 |
| 21 | រតនៈគិរី | | | | | | | | | | | | |
| 22 | មណ្ឌលគិរី | | | | | | | | | | | | |
| 23 | កោះកុង | | | | | | | 2 | 1 | 6 | 4 | 4 | |
| 24 | កំពង់ធំ | | | | | | | 1 | | 1 | 4 | 1 | |
| 25 | ឧត្តរមានជ័យ | | | | | | | | | | | | |
| 26 | PMឆ្លងប្រទេស | 1 | | 1 | | 1 | | 3 | 2 | 1 | 12 | 4 | |
| | សរុបរួម | 3 | 8 | 2 | 1 | 5 | | 33 | 7 | 31 | 198 | 43 | 10 |

| ល.រ | នាយកដ្ឋាន រាជធានី ខេត្ត | មាត្រា១២ ការជ្រើសរើសដោយមិនស្របច្បាប់សម្រាប់កេងប្រវ័ញ្ច | | | | | | មាត្រា១៤ =(១៣) អំពើលក់ដូរ-មនុស្ស | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | ករណីបង្ក្រាប | ជនរងគ្រោះ | | | ជនល្មើស | | ករណីបង្ក្រាប | ជនរងគ្រោះ | | | ជនល្មើស | |
| | | | -15 | 15-17 | 18 | ប | ស | | -15 | 15-17 | 18 | ប | ស |
| 1 | នាយកដ្ឋាន | | | | | | | | | | | | |
| 2 | រាជធានីភ្នំពេញ | | | | | | | | | | | | |
| 3 | សៀមរាប | | | | | | | | | | | | |
| 4 | បន្ទាយមានជ័យ | | | | | | | | | | | | |
| 5 | កណ្តាល | | | | | | | | | | | | |
| 6 | បាត់ដំបង | | | | | | | | | | | | |
| 7 | ព្រះសីហនុ | | | | | | | 1 | | | 8 | | 1 |
| 8 | កំពង់ឆ្នាំង | | | | | | | | | | | | |
| 9 | កំពង់ចាម | | | | | | | | | | | | |
| 10 | កំពង់ស្ពឺ | | | | | | | | | | | | |
| 11 | ព្រះវិហារ | | | | | | | 1 | 1 | | | | 1 |
| 12 | កំពត | | | | | | | | | | | | |
| 13 | ស្ទឹងត្រែង | | | | | | | | | | | | |
| 14 | កែប | | | | | | | | | | | | |
| 15 | ក្រចេះ | | | | | | | | | | | | |
| 16 | តាកែវ | | | | | | | | | | | | |
| 17 | ប៉ៃលិន | | | | | | | | | | | | |
| 18 | ពោធិ៍សាត់ | | | | | | | | | | | | |
| 19 | ព្រៃវែង | | | | | | | | | | | | |
| 20 | ស្វាយរៀង | | | | | | | | | | | | |
| 21 | រតនៈគិរី | | | | | | | | | | | | |
| 22 | មណ្ឌលគិរី | | | | | | | | | | | | |
| 23 | កោះកុង | | | | | | | | | | | | |
| 24 | កំពង់ធំ | | | | | | | | | | | | |
| 25 | ឧត្តរមានជ័យ | | | | | | | | | | | | |
| 26 | PMឆ្លងប្រទេស | | | | | | | | | | | | |
| | សរុបរួម | | | | | | | 2 | 1 | | 8 | | 2 |

| ល.រ | នាយកដ្ឋាន រាជធានី ខេត្ត | មាត្រា១៥ អំពើលក់-ដូរមនុស្ស ដោយមានគោលដៅ | | | | | | មាត្រា១៦ អំពើលក់-ដូរមនុស្ស សម្រាប់នាំឆ្លងដែន | | | | | | មាត្រា១៧ ការដឹកជញ្ជូន ដោយមានគោលដៅ | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | ករណីបង្ក្រាប | ជនរងគ្រោះ | | | ជនល្មើស | | ករណីបង្ក្រាប | ជនរងគ្រោះ | | | ជនល្មើស | | ករណីបង្ក្រាប | ជនរងគ្រោះ | | | ជនល្មើស | |
| | | | -15 | 15-17 | 18 | ប | ស | | -15 | 15-17 | 18 | ប | ស | | -15 | 15-17 | 18 | ប | ស |
| 1 | នាយកដ្ឋាន | | | | | | | | | | | | | | | | | | |
| 2 | រាជធានីភ្នំពេញ | | | | | | | | | | | | | | | | | | |
| 3 | សៀមរាប | | | | | | | | | | | | | | | | | | |
| 4 | បន្ទាយមានជ័យ | | | | | | | | | | | | | | | | | | |
| 5 | កណ្តាល | | | | | | | | | | | | | | | | | | |
| 6 | បាត់ដំបង | | | | | | | | | | | | | | | | | | |
| 7 | ព្រះសីហនុ | | | | | | | | | | | | | | | | | | |
| 8 | កំពង់ឆ្នាំង | | | | | | | | | | | | | | | | | | |
| 9 | កំពង់ចាម | | | | | | | | | | | | | | | | | | |
| 10 | កំពង់ស្ពឺ | | | | | | | | | | | | | | | | | | |
| 11 | ព្រះវិហារ | | | | | | | | | | | | | | | | | | |
| 12 | កំពត | | | | | | | | | | | | | | | | | | |
| 13 | ស្ទឹងត្រែង | | | | | | | | | | | | | | | | | | |
| 14 | កែប | | | | | | | | | | | | | | | | | | |
| 15 | ក្រចេះ | | | | | | | | | | | | | | | | | | |
| 16 | តាកែវ | | | | | | | | | | | | | | | | | | |
| 17 | ប៉ៃលិន | | | | | | | | | | | | | | | | | | |
| 18 | ពោធិ៍សាត់ | | | | | | | | | | | | | | | | | | |
| 19 | ព្រៃវែង | | | | | | | | | | | | | | | | | | |
| 20 | ស្វាយរៀង | | | | | | | | | | | | | | | | | | |
| 21 | រតនៈគិរី | | | | | | | | | | | | | | | | | | |
| 22 | មណ្ឌលគិរី | | | | | | | | | | | | | | | | | | |
| 23 | កោះកុង | | | | | | | | | | | | | | | | | | |
| 24 | កំពង់ធំ | | | | | | | | | | | | | | | | | | |
| 25 | ឧត្តរមានជ័យ | | | | | | | | | | | | | | | | | | |
| 26 | PM ផ្ទៃប្រទេស | | | | | | | | | | | | | | | | | | |
| | **សរុបរួម** | | | | | | | | | | | | | | | | | | |

| ល.រ | នាយកដ្ឋាន រាជធានី ខេត្ត | មាត្រា១៨ អំពើនាំឆ្លងដែន | | | | | | មាត្រា២១ ការចាប់ពង្រត់-ការឃុំឃាំង រឺ បង្ខាំង | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | ករណីបង្ក្រាប | ជនរងគ្រោះ | | | ជនល្មើស | | ករណីបង្ក្រាប | ជនរងគ្រោះ | | | ជនល្មើស | |
| | | | -15 | 15-17 | 18 | ប | ស | | -15 | 15-17 | 18 | ប | ស |
| 1 | នាយកដ្ឋាន | | | | | | | | | | | | |
| 2 | រាជធានីភ្នំពេញ | | | | | | | | | | | | |
| 3 | សៀមរាប | | | | | | | | | | | | |
| 4 | បន្ទាយមានជ័យ | | | | | | | | | | | | |
| 5 | កណ្តាល | | | | | | | | | | | | |
| 6 | បាត់ដំបង | | | | | | | | | | | | |
| 7 | ព្រះសីហនុ | | | | | | | | | | | | |
| 8 | កំពង់ឆ្នាំង | | | | | | | | | | | | |
| 9 | កំពង់ចាម | | | | | | | | | | | | |
| 10 | កំពង់ស្ពឺ | | | | | | | | | | | | |
| 11 | ព្រះវិហារ | | | | | | | | | | | | |
| 12 | កំពត | | | | | | | | | | | | |
| 13 | ស្ទឹងត្រែង | | | | | | | | | | | | |
| 14 | កែប | | | | | | | | | | | | |
| 15 | ក្រចេះ | | | | | | | | | | | | |
| 16 | តាកែវ | | | | | | | | | | | | |
| 17 | ប៉ៃលិន | | | | | | | | | | | | |
| 18 | ពោធិ៍សាត់ | | | | | | | | | | | | |
| 19 | ព្រៃវែង | | | | | | | | | | | | |
| 20 | ស្វាយរៀង | | | | | | | | | | | | |
| 21 | រតនៈគិរី | | | | | | | | | | | | |
| 22 | មណ្ឌលគិរី | | | | | | | | | | | | |
| 23 | កោះកុង | | | | | | | | | | | | |
| 24 | កំពង់ធំ | | | | | | | | | | | | |
| 25 | ឧត្តរមានជ័យ | | | | | | | | | | | | |
| 26 | PM ផ្ទៃប្រទេស | | | | | | | | | | | | |
| | **សរុបរួម** | | | | | | | | | | | | |

| ល.រ | នាយកដ្ឋាន រាជធានី ខេត្ត | មាត្រា៣៤ ការទិញពេស្យាចារកុមារ | | | | | មាត្រា៣៥ អំពើអូសទាញ ពេស្យាចារកុមារ | | | | | | ជនរងគ្រោះ បញ្ជូនទៅ | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | ករណីបង្ក្រាប | ជនរងគ្រោះ | | ជនល្មើស | | ករណីបង្ក្រាប | ជនរងគ្រោះ | | | ជនល្មើស | | | | |
| | | | -15 | 15-17 | ប | ស | | -15 | 15-17 | 18 | ប | ស | សគ | អគ | គ្រស |
| 1 | នាយកដ្ឋាន | 1 | 1 | | 1 | | | | | | | | | 1 | |
| 2 | រាជធានីភ្នំពេញ | 2 | 3 | 2 | 2 | | | | | | | | 14 | | 8 |
| 3 | សៀមរាប | | | | | | | | | | | | | | 5 |
| 4 | បន្ទាយមានជ័យ | | | | | | | | | | | | | | 50 |
| 5 | កណ្តាល | | | | | | | | | | | | | | 10 |
| 6 | បាត់ដំបង | | | | | | | | | | | | 68 | | 14 |
| 7 | ព្រះសីហនុ | | | | | | | | | | | | 8 | | 19 |
| 8 | កំពង់ឆ្នាំង | | | | | | | | | | | | | | 10 |
| 9 | កំពង់ចាម | | | | | | | | | | | | | | 13 |
| 10 | កំពង់ស្ពឺ | | | | | | | | | | | | | | 2 |
| 11 | ព្រះវិហារ | | | | | | | | | | | | | | 1 |
| 12 | កំពត | | | | | | | | | | | | | | |
| 13 | ស្ទឹងត្រែង | | | | | | | | | | | | | | |
| 14 | កែប | | | | | | | | | | | | | | |
| 15 | ក្រចេះ | | | | | | | | | | | | | | |
| 16 | តាកែវ | | | | | | | | | | | | | | 1 |
| 17 | ប៉ៃលិន | | | | | | | | | | | | | | 4 |
| 18 | ពោធិ៍សាត់ | | | | | | | | | | | | | | |
| 19 | ព្រៃវែង | | | | | | | | | | | | | | |
| 20 | ស្វាយរៀង | | | | | | | | | | | | | 9 | 4 |
| 21 | រតនៈគិរី | | | | | | 1 | | 1 | | | 1 | | | 1 |
| 22 | មណ្ឌលគិរី | | | | | | | | | | | | | | |
| 23 | កោះកុង | | | | | | | | | | | | | | 11 |
| 24 | កំពង់ធំ | | | | | | | | | | | | | | 7 |
| 25 | ឧត្តរមានជ័យ | | | | | | | | | | | | | | |
| 26 | PM ផ្ទៃប្រទេស | | | | | | | | | | | | 10 | | 8 |
| | **សរុបរួម** | **3** | **4** | **2** | **3** | | **1** | | **1** | | | **1** | **100** | **10** | **168** |

**សគៈ មន្ទីរសង្គមកិច្ចរាជធានី-ខេត្ត** **អគៈ អង្គការក្រៅរដ្ឋាភិបាល** **គ្រសៈ គ្រួសារ ឬ អាណាព្យាបាល**

គណៈកម្មាធិការជាតិដឹកនាំប.ជ.រ.ព.ត

លេខាធិការដ្ឋាន

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# តារាងទិន្នន័យបទល្មើសបង្ក្រាប អំពើធ្វើអាជីវកម្មផ្លូវភេទ

(គិតពីថ្ងៃទី២៦/១២/២០១១ ដល់ថ្ងៃទី២៥/១២/២០១២) ប្រចាំឆ្នាំ ២០១២

| ល.រ | នាយកដ្ឋាន រាជធានី ខេត្ត | បង្ករបសរុប | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| | | ករណីប្រទះ | ជនរងគ្រោះ | ជនល្មើស | អាយុជនរងគ្រោះ | | | ជនល្មើស | |
| | | | | | -15 | 15-17 | 18 | ប | ស |
| 1 | នាយកដ្ឋាន | 4 | 6 | 4 | 2 | 1 | 3 | 2 | 2 |
| 2 | រាជធានីភ្នំពេញ | 28 | 80 | 34 | 13 | 10 | 57 | 20 | 14 |
| 3 | សៀមរាប | 7 | 28 | 9 | 23 | 2 | 3 | 6 | 3 |
| 4 | បន្ទាយមានជ័យ | 4 | 6 | 4 | 3 | | 3 | 3 | 1 |
| 5 | កណ្ដាល | 6 | 8 | 6 | 6 | 2 | | 6 | |
| 6 | បាត់ដំបង | 8 | 10 | 8 | 5 | | 5 | 6 | 2 |
| 7 | ព្រះសីហនុ | 4 | 11 | 4 | 2 | | 9 | 2 | 2 |
| 8 | កំពង់ឆ្នាំង | 2 | 2 | 2 | 2 | | | 2 | |
| 9 | កំពង់ចាម | 2 | 2 | 3 | 2 | | | 3 | |
| 10 | កំពង់ស្ពឺ | | | | | | | | |
| 11 | ព្រះវិហារ | | | | | | | | |
| 12 | កំពត | 1 | | 1 | | | | | 1 |
| 13 | ស្ទឹងត្រែង | | | | | | | | |
| 14 | កែប | | | | | | | | |
| 15 | ក្រចេះ | 1 | 3 | 1 | | | 3 | | 1 |
| 16 | តាកែវ | 1 | 1 | 1 | 1 | | | 1 | |
| 17 | ប៉ៃលិន | | | | | | | | |
| 18 | ពោធិ៍សាត់ | 3 | 8 | 3 | 2 | | 6 | 2 | 1 |
| 19 | ព្រៃវែង | 1 | 4 | 2 | | | 4 | 1 | 1 |
| 20 | ស្វាយរៀង | | | | | | | | |
| 21 | រតនៈគិរី | | | | | | | | |
| 22 | មណ្ឌលគិរី | | | | | | | | |
| 23 | កោះកុង | | | | | | | | |
| 24 | កំពង់ធំ | | | | | | | | |
| 25 | ឧត្ដរមានជ័យ | | | | | | | | |
| 26 | PMផ្ទៃប្រទេស | 8 | 11 | 8 | 6 | 1 | 4 | 7 | 1 |
| | សរុបរួម | 80 | 180 | 90 | 67 | 16 | 97 | 61 | 29 |

| ល.រ | មាត្រា២១ | | | | | | មាត្រា២៦ =(២៨៤) | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ការចាប់ពង្រត់ ការឃុំឃាំងរឺ បង្ខាំង | | | | | | សញ្ញារកម្ម | | | | សញ្ញារកម្ម (មានអនិតិជន) | | | | | |
| | ករណីប្រទះ | ជនរងគ្រោះ | | | ជនល្មើស | | ករណីប្រទះ | ជនរងគ្រោះ | ជនល្មើស | | ករណីប្រទះ | ជនរងគ្រោះ | | | ជនល្មើស | |
| | | -15 | 15-17 | 18 | ប | ស | | 18 | ប | ស | | -15 | 15-17 | 18 | ប | ស |
| 1 | | | | | | | | | | | | | | | | |
| 2 | | | | | | | 2 | 7 | | 2 | | | | | | |
| 3 | | | | | | | | | | | 2 | | 2 | 3 | 1 | 3 |
| 4 | | | | | | | 1 | 3 | | 1 | | | | | | |
| 5 | | | | | | | | | | | | | | | | |
| 6 | | | | | | | | | | | | | | | | |
| 7 | | | | | | | | | | | | | | | | |
| 8 | | | | | | | | | | | | | | | | |
| 9 | | | | | | | | | | | | | | | | |
| 10 | | | | | | | | | | | | | | | | |
| 11 | | | | | | | | | | | | | | | | |
| 12 | | | | | | | | | | | | | | | | |
| 13 | | | | | | | | | | | | | | | | |
| 14 | | | | | | | | | | | | | | | | |
| 15 | | | | | | | | | | | | | | | | |
| 16 | | | | | | | | | | | | | | | | |
| 17 | | | | | | | | | | | | | | | | |
| 18 | | | | | | | 1 | 6 | | 1 | | | | | | |
| 19 | | | | | | | | | | | | | | | | |
| 20 | | | | | | | | | | | | | | | | |
| 21 | | | | | | | | | | | | | | | | |
| 22 | | | | | | | | | | | | | | | | |
| 23 | | | | | | | | | | | | | | | | |
| 24 | | | | | | | | | | | | | | | | |
| 25 | | | | | | | | | | | | | | | | |
| 26 | | | | | | | | | | | | | | | | |
| សរុបរួម | | | | | | | 4 | 16 | | 4 | 2 | | 2 | 3 | 1 | 3 |

| ល.រ | មាត្រា២៧ =(២៨៨) | | | | | | មាត្រា២៨ =(២៨៩) | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | សញ្ញារកម្ម (ស្ថានទម្ងន់ទោស) | | | | | | សញ្ញារកម្ម (ទាក់ទងនឹងពេស្យាចារកុមារ) | | | | | |
| | ករណីប្រទះ | ជនរងគ្រោះ | | | ជនល្មើស | | ករណីប្រទះ | ជនរងគ្រោះ | | | ជនល្មើស | |
| | | -15 | 15-17 | 18 | ប | ស | | -15 | 15-17 | 18 | ប | ស |
| 1 | 1 | | | 2 | | 1 | 1 | | 1 | 1 | | 1 |
| 2 | 1 | | 1 | 1 | | 2 | 5 | 2 | 9 | 23 | 3 | 6 |
| 3 | | | | | | | | | | | | |
| 4 | | | | | | | | | | | | |
| 5 | | | | | | | | | | | | |
| 6 | | | | | | | | | | | | |
| 7 | 1 | | | 3 | | 1 | | | | | | |
| 8 | | | | | | | | | | | | |
| 9 | | | | | | | | | | | | |
| 10 | | | | | | | | | | | | |
| 11 | | | | | | | | | | | | |
| 12 | 1 | | | | | 1 | | | | | | |
| 13 | | | | | | | | | | | | |
| 14 | | | | | | | | | | | | |
| 15 | | | | | | | | | | | | |
| 16 | | | | | | | | | | | | |
| 17 | | | | | | | | | | | | |
| 18 | | | | | | | | | | | | |
| 19 | 1 | | | 4 | 1 | 1 | | | | | | |
| 20 | | | | | | | | | | | | |
| 21 | | | | | | | | | | | | |
| 22 | | | | | | | | | | | | |
| 23 | | | | | | | | | | | | |
| 24 | | | | | | | | | | | | |
| 25 | | | | | | | | | | | | |
| 26 | 1 | | | 4 | | 1 | | | | | | |
| សរុបរួម | 6 | | 1 | 14 | 1 | 7 | 6 | 2 | 10 | 24 | 3 | 7 |

| ល.រ | នាយកដ្ឋាន រាជធានី ខេត្ត | មាត្រា៣២ =(២៩៣) | | | | | | មាត្រា៣៩ | | | | | | មាត្រា៤១ | | | | | | មាត្រា៤២ | | | | | មាត្រា៤៣ =(២៤៦) | | | | | ជនរងគ្រោះ បញ្ជូនទៅ | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | ការផ្ដល់ទីកន្លែង សម្រាប់ធ្វើពេស្យាចារ | | | | | | រូបភាព និង សម្ភារៈអាសអាភាស | | | | | | រូបភាព និង សម្ភារៈអាសអាភាសនៃកុមារ | | | | | | អំពើរួមភេទជាមួយអនីតិជន អាយុក្រោម១៥ឆ្នាំ | | | | | អំពើអាសប្រឆាំងនឹងអនីតិជន អាយុក្រោម១៥ឆ្នាំ( ប្រទូសកេរខ្មាស) | | | | | | | |
| | | ករណីបង្ក្រាប | ជនរងគ្រោះ | | | ជនល្មើស | | ករណីបង្ក្រាប | ជនរងគ្រោះ | | | ជនល្មើស | | ករណីបង្ក្រាប | ជនរងគ្រោះ | | | ជនល្មើស | | ករណីបង្ក្រាប | ជនរងគ្រោះ | | ជនល្មើស | | ករណីបង្ក្រាប | ជនរងគ្រោះ | | ជនល្មើស | | | | |
| | | | -15 | 15-17 | 18 | ប | ស | | -15 | 15-17 | 18 | ប | ស | | -15 | 15-17 | 18 | ប | ស | | -15 | 15-17 | ប | ស | | -15 | 15-17 | ប | ស | សត | អក | គ្រស |
| 1 | នាយកដ្ឋាន | | | | | | | | | | | | | | | | | | | 2 | 2 | | 2 | | | | | | | | | 6 |
| 2 | រាជធានីភ្នំពេញ | 5 | | | 25 | 2 | 4 | 1 | | | 1 | 1 | | 2 | | | | 2 | | 8 | 8 | | 8 | | 4 | 3 | | 4 | | 61 | | 19 |
| 3 | សៀមរាប | | | | | | | | | | | | | | | | | | | 1 | 1 | | 1 | | 4 | 22 | | 4 | | 9 | | 19 |
| 4 | បន្ទាយមានជ័យ | | | | | | | | | | | | | | | | | | | | | | | | 3 | 3 | | 3 | | | | 6 |
| 5 | កណ្ដាល | | | | | | | | | | | | | | | | | | | 1 | 1 | | 1 | | 5 | 5 | 2 | 5 | | | 1 | 10 |
| 6 | បាត់ដំបង | 1 | | | 3 | | 1 | 2 | | | 2 | 2 | | | | | | | | 3 | 3 | | 2 | 1 | 2 | 2 | | 2 | | 6 | 1 | 6 |
| 7 | ព្រះសីហនុ | 1 | | | 6 | | 1 | | | | | | | | | | | | | 2 | 2 | | 2 | | | | | | | 3 | | 2 |
| 8 | កំពង់ឆ្នាំង | | | | | | | | | | | | | | | | | | | 2 | 2 | | 2 | | | | | | | | | 2 |
| 9 | កំពង់ចាម | | | | | | | | | | | | | | | | | | | 2 | 2 | | 3 | | | | | | | | 1 | 1 |
| 10 | កំពង់ស្ពឺ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| 11 | ព្រះវិហារ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| 12 | កំពត | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| 13 | ស្ទឹងត្រែង | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| 14 | កែប | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| 15 | ក្រចេះ | 1 | | | 3 | | 1 | | | | | | | | | | | | | | | | | | | | | | | 3 | | |
| 16 | តាកែវ | | | | | | | | | | | | | | | | | | | | | | | | 1 | 1 | | 1 | | | | 1 |
| 17 | បៃលិន | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| 18 | ពោធិសាត់ | | | | | | | | | | | | | | | | | | | 1 | 1 | | 1 | | 1 | 1 | | 1 | | 7 | | 1 |
| 19 | ព្រៃវែង | | | | | | | | | | | | | | | | | | | | | | | | | | | | | | | 4 |
| 20 | ស្វាយរៀង | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| 21 | រតនៈគិរី | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| 22 | មណ្ឌលគិរី | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| 23 | កោះកុង | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| 24 | កំពង់ធំ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| 25 | ឧត្ដរមានជ័យ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| 26 | PM ឧត្តរមានជ័យ | | | | | | | 1 | | 1 | | 1 | | | | | | | | 6 | 6 | | 6 | | | | | | | | | 11 |
| | **សរុបរួម** | 8 | | | 37 | 2 | 7 | 4 | | 1 | 3 | 4 | | 2 | | | | 2 | | 28 | 28 | | 28 | 1 | 20 | 37 | 2 | 20 | | 89 | 3 | 88 |

សគៈ មន្ទីរសង្គមកិច្ចរាជធានី-ខេត្ត

អភៈ អង្គការក្រៅរដ្ឋាភិបាល

គ្រសៈ គ្រួសារ ឬ អាណាព្យាបាល

# សកម្មភាពផ្សេងៗ
# របស់លេខាធិការដ្ឋាន
# នៃ
# គណៈកម្មាធិការជាតិដឹកនាំ
# ប.ជ.រ.ព.ភ




សកម្មភាពប្រជុំធ្វើផែនការ សកម្មភាព បជរពភ ថ្នាក់ខេត្ត




ប្រជុំពិភាក្សាជាមួយដៃគូអភិវឌ្ឍន៍ លើការងារប្រឆាំងការជួញដូរមនុស្ស




ពិធីចុះអនុស្សរណៈរវាង លេខាធិការដ្ឋានជាតិនៃគណៈកម្មការជាតិដឹកនាំ បជរពគ
និង អង្គការ វីនរ៉ក់




សកម្មភាពទស្សនកិច្ចសិក្សាតាមបណ្តាក្រុមហ៊ុនជ្រើសរើសពលករ




សកម្មភាពចុះស្វែងយល់អំពីស្ថានភាព និងសាកសួរសុខទុក្ខ ពលករចំណាកស្រុក
នៅខេត្តព្រៃវែង






សកម្មភាពចុះត្រួតពិនិត្យ
តាមដានការងារទេសន្តប្រ
វេសន៍តាមបណ្តាច្រក
ព្រំដែន ខ្មែរ-ថៃ



កិច្ចសន្ទនារវាងក្រុមការងារទេសន្តរប្រវេសន៍ និង ក្រុមការងារទី៦-៨ រដ្ឋសភា ស្តីពី
បញ្ហាទេសន្តរប្រវេសន៍ និង ការជួញដូរមនុស្ស



ជំនួបរវាងគណប្រតិភូកម្ពុជា
និងរដ្ឋាភិបាលប្រទេស
ម៉ាឡេស៊ី ស្តីពី
បញ្ហាពលករកម្ពុជានៅ
ប្រទេសម៉ាឡេស៊ី



ជំនួបជាមួយស្ថានទូត
ព្រះរាជាណាចក្រកម្ពុជា
ប្រចាំប្រទេសម៉ាឡេស៊ី




សកម្មភាពចុះពិនិត្យការងារតាមក្រុមហ៊ុន នៅប្រទេសម៉ាឡេស៊ី





សម្មភាព
សួរសុខទុក្ខ
ពលករកម្ពុជា
នៅប្រទេស
ម៉ាឡេស៊ី

សកម្មភាពចុះ
តាមដានត្រួត-
ពិនិត្យការងារ
លេខាធិការដ្ឋាន
ថ្នាក់ខេត្តទាំង
២៤ រាជធានី-ខេត្ត






កិច្ចប្រជុំបូកសរុបការងារលេខាធិការដ្ឋានថ្នាក់ជាតិនិងលើកទិសដៅឆ្នាំ២០១៣



សកម្មភាពឆ្លង
របាយការណ៍
ឆ្នាំ ២០១២

ឧបត្ថម្ភដោយ: